ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Apr-2017, 14:20
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៣៧៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ
លោក នីកូឡូ ប៉ុងស៍*(Mr. Niccolo PONS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង
កញ្ញា សុង ឆវ័ន្ត
លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*
លោក ត្រាវីស ហ្វារ*(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ
លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*
លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក អ៊ុំ ស៊ុនឡាយ (2-TCCP-1014) | ខ្មែរ |
| លោក ផន ថុល (2-TCP-933) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក អ៊ុច ស៊ុនឡាយ** (2-TCCP-1014)

សួរបន្តដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្តើមពី ....................ទំព័រ ៣

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ១២

សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ១៥

**ការសួរសំណួរទៅសាក្សី៖ លោក ផន ថុល** (2-TCP-933)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ២៤

សួរដោយលោក ត្រាវីស ហ្វារ ផ្តើមពី ....................ទំព័រ ២៧

សួរដោយលោកស្រី ទី ស៊ីនណា ផ្តើមពី ....................ទំព័រ ៥៥

សួរដោយលោក វិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ៦៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្ម និងសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ បញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-933 ពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខអូរកន្សែង។ ហើយបុគ្គលិកអង្គការ ធី.ភី.អូ ដែលអង្គុយក្បែរដើមបណ្ដឹងរដ្ឋប្បវេណីនៅថ្ងៃនេះគឺលោក ប៊ុន លឹមហ្សួរ។

ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

[០៩:០៤:០៣]

ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក អ៊ុច ស៊ុនឡាយ។ នៅក្នុងអំឡុងពេលនៃការថ្លែងទុក្ខសោកនេះ មានបុគ្គលិកអង្គការ ធី.ភី.អូ គឺលោក ប៊ុន លឹមហ្សួរ អង្គុយក្បែរដើមបណ្ដឹងរដ្ឋប្បវេណី។ ដើមបណ្ដឹងរដ្ឋប្បវេណី និងបុគ្គលិកអង្គការ ធី.ភី.អូ មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

នៅថ្ងៃនេះដែរមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-933 សាក្សីបានបញ្ជាក់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយ នៅចំពោះមុខតាដំបងដែកនាកាលពីព្រឹកមិញនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦។

[០៩:០៥:៤៣]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះ វិលមុខ មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំង

សំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។

[០៩:០៦:៥៩]

**លោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរមេធាវីការពារក្ដី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

**ស៖** ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ។ ខ្ញុំមានសំណួរបន្តិចបន្តួចទៀតដែលត្រូវសួរលោកនៅព្រឹកនេះ<តំណាងឲ្យសហព្រះរាជអាជ្ញា>។ ម្សិលមិញ នៅពេលដែលយើងឈប់សម្រាកនោះ លោកបានបញ្ជាក់ថា អ្នកភូមិម្នាក់បានប្រាប់លោកអំពីការសម្លាប់ប្រពន្ធនិងកូនៗរបស់លោក ក៏ដូចជាការ<សម្លាប់ស្ត្រី និងក្មេងៗផ្សេងទៀត គឺ>ឈ្មោះ ថុល <ដែល>បានឃើញការសម្លាប់នេះដោយផ្ទាល់ភ្នែក<>។ ហើយអ្នកភូមិម្នាក់ដែលបានប្រាប់លោកអំពីការសម្លាប់នេះ គឺថាបានរៀបរាប់ថា ក្មេងៗខ្លះព្យាយាមរត់គេចចេញនៅពេលដែលគេ<ហៀបនឹង>សម្លាប់។ ហើយអ្នកដែលប្រាប់លោក ថាក្មេងៗព្យាយាមរត់គេចខ្លួននេះ តើបុគ្គល<ដែលឈ្មោះ ថុល>នេះ បានឃើញឧក្រិដ្ឋកម្មនេះដោយផ្ទាល់ភ្នែកដែរ ឬក៏អត់ទេ?

**លោក អ៊ុច ស៊ុនឡាយ៖**

**ឆ៖** បាទ សូមអរគុណ។ សូមគោរពលោកប្រធាននៃអង្គចៅក្រម។ អ្នកភូមិម្នាក់ហ្នឹងឈ្មោះ ថុល ជាអ្នកដែលបររទេះគោដឹកក្រុមគ្រួសារ ចៅកាត់វៀតណាមនេះទៅកន្លែងពិឃាត។ គាត់ក៏បានឃើញ គាត់មានការញ័រចំប្រប់ គាត់បានលបលួច លួចមើល មិនបានមើលពេញទាំងអស់ទេ ដោយពួកប្រធានកងឈ្លបមានឈ្មោះ អ៊ុក តាំងហ៊ីន ដេញអត់ឲ្យមើលបានអស់ឡើយ។ ដូច្នេះកូនក្មេងទាំងអស់នោះ ត្រូវពួកមេពជ្ឈឃាដដេញចាប់ប្រផាប់ពភីង ទក់វាលព្រៃស្មៅ និងគ្រែងទាំងអស់នោះដើម្បីចាប់បោក សម្លាប់ចោលនៅក្នុងរណ្ដៅក្រោមដើមក្តុល នៅក្បាលកោះទ្រង់ ឃុំកោះទ្រង់ សង្កាត់កោះទ្រង់ ខេត្តក្រចេះ គឺទល់មុខខេត្តក្រចេះ។ ខ្ញុំបាទបានទទួលព័ត៌មានតែពីលោក ថុល ហ្នឹង បានតែប៉ុន្មឹងទេ។ បាទ សូមអរគុណ។

[០៩:០៩:២៤]

**ស៖** លោកទើបតែនិយាយថា កូនក្មេងនោះគឺជាកូនង៉ែតទេ។ ចុះកូនលោកវិញនោះ នៅពេល

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹងមានអាយុប៉ុន្មានដែរ នៅពេលដែលគេសម្លាប់ក្មេងៗនោះ?

**ឆ៖** បាទ សូមអរគុណ។ នៅពេលដែលគេសម្លាប់កូនក្មេងនោះ កូនខ្ញុំបាទនោះមានបីនាក់គឺប្រុសពីរនាក់ ស្រីមួយនាក់។ កូនច្បងឈ្មោះ សុធីរ៉ា អាយុ៨ឆ្នាំ កើតឆ្នាំ៧០មកទល់នឹង៧៨។ កូនបន្ទាប់ឈ្មោះ សុធីរៈ កើតឆ្នាំ ១៩៧៥។ រីឯកូនប្អូនឈ្មោះ សុធីតា ប្រហែលជាជាង១ខួបប៉ុណ្ណោះទេបាទ ជាស្រី។ សូមអស់យោបល់។

**ស៖** ចុះលោកដឹងទេថា ហេតុអ្វីបានជាប្រពន្ធ និងកូនៗរបស់លោកនេះក្លាយជាគោលដៅនៃការសម្លាប់នេះ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបាទដឹងថា ប្រពន្ធ និងកូនខ្ញុំហ្នឹងពិតជាគោលដៅសំខាន់របស់ពួកមេដឹកនាំ ប៉ុល ពត ហ្នឹងហើយដែលត្រូវសម្លាប់ ពីព្រោះម្តាយក្មេងឈ្មោះ វៀង ធីបេ ហ្នឹងជាកូនកាត់វៀតណាម ហើយយកទៅបាត់យូរហើយ។ ដោយឡែកប្រពន្ធ និងកូនហ្នឹង គឺជាចៅកាត់វៀតណាមទៀត គឺពិតជាមិនអាចគេចរួចពីការតាមចាប់សម្លាប់របស់ពួកមេពជ្ឈឃាដទាំងអស់ហ្នឹងទេ។ ទី១ ដោយសារប្រវត្តិរូបយើងនៅភូមិឃុំ គេដឹងច្បាស់ថាយើងធ្វើគ្រូបង្រៀនមែន ជនជាតិខ្មែរមែន ប៉ុន្តែយើងយកប្រពន្ធកូនជាចៅកាត់ ជាកូនកាត់វៀតណាមបាទ។ ខ្ញុំបាទដឹងតែប៉ុណ្ណឹងទេ។ អរគុណ សូមចប់។

[០៩:១១:៤២]

**ស៖** លោកដឹងទេថា -- លោកមានដឹងអ្វីបន្ថែមពីលើការដែលគេយកប្រពន្ធ និងកូនៗរបស់លោកទៅសម្លាប់នេះដែរទេ?

**ឆ៖** បាទ សូមអរគុណ។ ការដែលខ្ញុំបាទដឹង គឺខ្ញុំបានហ្នឹងដឹងយូរថ្ងៃខែហើយដែរ តែអត់មានលទ្ធភាព ឬវិធីអី ឬអ្វីដើម្បីនឹងដោះស្រាយដោយភាពទញ់ទាល់ក្នុងគំនិត និងរត់ទៅណាក៏មិនរួចដែរ ពីព្រោះមើលឃើញថា ពួកគណៈសហករណ៍នេះតាមដានប្រវត្តិមនុស្សរស់នៅ អានេះកូនអ្នកនេះ កូនអ្នកនោះអី គឺពួកគេហ្នឹងតាមដានទាំងយប់ទាំងថ្ងៃ។ អ៊ីចឹងទេ ខ្ញុំបាទដឹងតែប៉ុណ្ណឹង។ ដូច្នេះភាពតក់ស្លុតភាពភ័យព្រួយ និងក្តុកក្តួលក្នុងចិត្តហ្នឹង គឺមានតែទឹកភ្នែកប៉ុណ្ណោះ ដែលហៅថាជួយរំដោះពីក្នុងរូបរាងកាយយើងឱ្យផុតពីទុក្ខសោកខ្លះ។ ពេលខ្លះយើងតឹងទ្រូងអួលណែនដូចគេកាប់ថ្លើមប្រមាត់ ចុកពើតផ្សាទាំងអស់ មិនអាចរ៉ាយរ៉ាប់ប្រាប់អ្នកណាឱ្យគេជួយបាន។ ម្ល៉ោះហើយមានតែខ្លួនឯងប៉ុណ្ណោះ ដោយសារឃើញថា នេះហើយគឺជាសោកនាដកម្មសម្រាប់ខ្លួនខ្ញុំផ្ទាល់ ក៏ដូចជាប្រពន្ធនិងកូនជាទីស្រឡាញ់។ ឪពុកលោកអ្នកដ៏មានគុណជាទីស្រឡាញ់ និងជាទីគោរពបានបាត់បង់ទៅហើយ។ ដោយឡែកខ្លួនខ្ញុំផ្ទាល់នេះ

ទៀត ត្រូវគណៈសហករណ៍គេមកលួចប្រាប់ថា ឡាយ ឯងប្រយ័ត្ន ព្រោះមានឈ្មោះខ្លួនឯងហ្នឹង ង្វៀង យ៉ាំងឡាយ គឺជាខ្មែរ ហ្វៀ.បេ បង្កប់នៅក្នុងសហករណ៍ក-២នេះ។ ដូច្នេះទុក្ខព្រួយផ្ទួនៗគ្នា អស់ពីប្រពន្ធ កូន ឪពុកក្មេក ម៉ែក្មេក ឪពុកបង្កើត ហើយខ្លួនយើងហ្នឹង ពិតជាមិនអាចរស់រានមានជីវិតទេ ព្រោះដោយស្តាប់ឮសំឡេងហ្នឹងដែលគេមកខ្សឹបខ្សៀវប្រាប់។ រហូតដល់ពេលដែលចុងក្រោយថ្ងៃ០២ ធ្នូ ៧៨ ចុងឆ្នាំហើយ យើងបានឮស្នូរសំឡេងគ្រឹមៗពីនាយមក នឹកថា លោកអ្នកឯណាដែលបានមករំដោះខ្ញុំឲ្យរួចផុតពីក្រញាំនៃរបបឃោរឃៅ ព្រៃផ្សៃប្រល័យពូជសាសន៍ អន្សុតិរ្តិយនេះ សូមឆាប់អញ្ជើញមក ឆាប់មក ខ្ញុំសូមស្វាគមន៍អស់លោកអ្នកទាំងអស់នោះដោយក្តីគោរព និងកោតសរសើរបំផុត។ សូមអស់យោបល់ សូមចប់។

[០៩:១៤:៤៦]

**ស៖** លោក អ៊ុច ស៊ុនឡាយ លោកបានពន្យល់ថាប្រពន្ធរបស់លោកក្លាយជាគោលដៅនៃការសម្លាប់នេះ ដោយសារថា គាត់មានសាវតារជាតិហ្នឹងជាវៀតណាម។ ចុះលោកដឹងទេថា ហេតុអ្វីបានជាកូនៗរបស់លោកនេះ ដែលលោកមានកូនៗជាមួយប្រពន្ធជាវៀតណាម ក៏ក្លាយជាគោលដៅនៃការសម្លាប់នេះដែរ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបាទហ្នឹងច្បាស់ហើយថាប្រពន្ធ និងកូនជាវៀតណាម ដូច្នេះកូនហ្នឹង គឺជាចៅកាត់វៀតណាម ពីព្រោះទ្រឹស្តីរបស់មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង បានផ្សព្វផ្សាយទៅដល់ថ្នាក់ក្រោមទាំងអស់ថា ជីកស្មៅ ត្រូវជីកទាំងឫស បានន័យថា បើយកប្រពន្ធនិងកូនដែលជាចៅកាត់វៀតណាម អាចៅទួត ចៅលួត ចៅអីក៏ដោយ ក៏ជាវៀតណាម ជាខ្មែរកា.ហ្វៀ.បេ ទាំងអស់ដែរ។ នេះគឺដឹងច្បាស់ យល់ច្បាស់ដោយមើលឃើញ និងការតាមដានសាវតារជាតិរបស់ពួកកងឈ្លប នៅក្នុងសហករណ៍ ក-១ រហូតដល់ ក-៥ ហ្នឹងគឺអ៊ីចឹង។ សូមអស់យោបល់។

**ស៖** លោកទើបតែនិយាយអំពីគោលនយោបាយ លោកទើបតែនិយាយអំពីគោលនយោបាយដែលលោកបានឮថា "បើជីកស្មៅ ត្រូវតែជីកទាំងឫស"។ តើលោកអាចពន្យល់ទ្រឹស្តីនេះ ពាក្យស្លោកនេះ ជូនអង្គជំនុំជម្រះឲ្យលម្អិតបន្តិចបានទេ?

**ឆ៖** បាទ សូមអរគុណ។ ទោះបីខ្ញុំបាទមិនមែនជាអ្នកនយោបាយ មកពីពាក្យថា នយៈ ប្លុកនឹងឧបាយ គឺកលល្បិចកិចកលសព្វបែបយ៉ាង ក៏ពិតមែនតែខ្ញុំបានរៀនសូត្រយល់ដឹងផ្នែកវប្បធម៌ គឺយល់

ច្បាស់ថា បើថា ដឹកស្មៅដឹកទាំងឫស បានន័យថា ចង់យកស្មៅមែន តែត្រូវដឹកឲ្យអស់ឫសដែលស្មៅហ្នឹង ទៅខាងណាក៏ដោយ ឆ្វេង ស្តាំ មុខក្រោយ ឬជម្រៅប៉ុនណាក៏ដោយ។ អាហ្នឹងជាន័យអត្ថបដិរូប គឺខ្ញុំបាទយល់អ៊ីចឹង។ ដូច្នេះមើលឃើញថា ពិតជាមិនអាចគេចរួច អំពីការតាមដានគ្រប់សព្វបែបយ៉ាង នៃពួកកងឈ្លបកម្ពុជាប្រជាធិបតេយ្យហ្នឹងបានទេ។ សូមអស់ សូមចប់យោបល់។

[០៩:១៨:០០]

**ស៖** មុននេះលោកបាននិយាយថា ចារីម្នាក់ឈ្មោះ អ៊ុក តាំងហ៊ីន គឺថាជាចារីក្នុងការសម្លាប់នេះ។ តើលោកមានចាំឈ្មោះឃាតករដទៃៗទៀតដែលបានសម្លាប់ស្ត្រី និងក្មេងៗដូចដែលលោករៀបរាប់នេះបានទេ?

**ឆ៖** បាទ សូមអរគុណ។ ឈ្មោះចារីដែលជាពេជ្ឈឃាដទាំងអស់ហ្នឹង គឺយើងខ្ញុំនៅចាំបាន និងស្គាល់ ពីព្រោះអ្នកហ្នឹងរស់នៅក្នុងភូមិហ្នឹង ឃុំហ្នឹង ប៉ុន្តែធ្វើជាកងឈ្លប ប្រដាប់អាវុធឲ្យសហករណ៍ និងពួកប្រល័យពូជសាសន៍ហ្នឹង គឺមានឈ្មោះដូចតទៅដែលខ្ញុំបាទបានចាំ។ អ៊ុក តាំងហ៊ីន នេះគឺជាមេ។ បច្ចុប្បន្ននេះវត់មករស់នៅលាក់ខ្លួនពួនអាត្មានៅអរិយក្សត្រ។ ទី២ ឈ្មោះ អាដាំ មាឌទាប ស្តើង ប៉ុន្តែសក់រួញ។ ៣) ឈ្មោះ អាម៉ុង ប៉ាង មាឌស្គមខ្ពស់ តែភ្នែកធំៗ។ ៤) ឈ្មោះ អាស្រួច ហើយ៥) ហ្នឹងមានឈ្មោះ អាឈឿង។ ប៉ុន្តែអង្គជំនុំជម្រះដូចជ្រាបស្រាប់ កាលដែលចេញមុខខ្លាំង គឺតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃកម្ពុជាប្រជាធិតតេយ្យតែប៉ុណ្ណោះ។ អ្នកទាំងអស់នោះ ក៏ត្រូវបានរាជរដ្ឋាភិបាលលើកលែងទោស ដើម្បីមិនយកមកកាត់ទោសអូសដំណើរទេ ពោលគឺគោលនយោបាយដែលផ្សះផ្សាជាតិ បង្រួបបង្រួមជាតិ។ តែអ្នកទាំងអស់ហ្នឹង ខ្ញុំបាទចាំច្បាស់នៅនឹងខ្លួន ពីព្រោះធ្លាប់បានដើរហើរឃើញវាមកតាមដាន ធ្វើការងារនៅក្នុងសហករណ៍ហ្នឹង តាំងពេលព្រឹក ពេលថ្ងៃ រហូតដល់ពេលយប់ថែមទៀត។ បាទ សូមអស់ សូមចប់យោបល់។

[០៩:២០:១៨]

**ស៖** តើលោកដឹងបុគ្គលដែលឈ្មោះ អ៊ុក <តាំងហ៊ីន>, ដាំ<>, ឈឿង អ្នកទាំងហ្នឹង តើលោកដឹងថា គេមានទទួលបញ្ជាពីណាឲ្យមកសម្លាប់អ្នកទាំងនេះទេ ឬក៏អ្នកទាំងនេះ សម្លាប់មនុស្សនេះ គឺដោយសារតែគំនិតខ្លួនគេ?

**ឆ៖** បាទ សូមអរគុណ។ មិនមែនដោយគំនិតខ្លួនគេទេ។ នេះគឺមានការចាត់តាំងជាសម្ងាត់សម្ងាត់នោះ គឺទាំងយប់ទាំងថ្ងៃ។ អ្នកទាំងអស់នុ៎ងជាកងឈ្លប គឺកូនកសិករក្រថ្នាក់ក្រោមដែលគេចាត់

តាំង។ ហើយ អ៊ុក តាំងហ៊ីន នេះជាមេហ្នឹងគឺជាអ្នកឡើងឆ្នោត ទទួលគ្រប់គ្រងក្រុមសេនាជន ឬក៏កងចល័តសម្ងាត់របស់ផ្ទៃក្នុងនៃសហករណ៍ហ្នឹងតែម្តង។ មិនមានដោយគំនិតខ្លួនគេទេ គឺមានបទបញ្ជាជាសម្ងាត់ពីលើរហូតដល់ក្រោម។ សូមអស់ សូមចប់យោបល់។

**ស៖** កាលពីម្សិលមិញ នៅសក្ខីកម្មរបស់លោកពាក់ព័ន្ធទៅនឹងការសម្លាប់ប្រពន្ធ និងកូនរបស់លោក គឺថាលោកក៏បានថា មានគ្រួសារដទៃទៀតត្រូវបានសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ជាពិសេសលោកនិយាយអំពីឈ្មោះ វៀង ធីបេ <ដែលជាម្តាយក្មេករបស់លោក>, ចាយ ចាន់<វិសាល>, សា គីមណា ដែលជាប្អូនថ្លៃ<ស្រី>របស់លោក។ តើប្រពន្ធរបស់លោកជាប់សាច់ញាតិ ឬក៏មានទំនាក់ទំនងយ៉ាងម៉េចដែរ ជាមួយឈ្មោះ ចាយ ចាន់<>វិសាល នេះ?

[០៩:២២:៣២]

**ឆ៖** បាទ សូមអរគុណ។ ប្រពន្ធខ្ញុំបាទឈ្មោះ សា គីមនី ហ្នឹង សា គីមណា បងប្អូនគាត់បង្កើតហ្នឹង គេដឹងច្បាស់ថា កូនរបស់លោក ចាយ គឹមអេង ស្មៀនអ៊ី ស្មៀនឃុំជាមួយនឹងលោកស្រី វៀង ធីបេ។ ដូច្នេះគេដឹងថា ជាកូនកាត់វៀតណាមស្រេចទៅហើយ។ ដល់កូនរបស់ខ្ញុំបាទហ្នឹងទៅទៀតគេយល់ថាគឺជាចៅកាត់វៀតណាម។ ក៏ប៉ុន្តែគួរឲ្យស្តាយណាស់ ដោយសារអ្នកទាំងអស់ហ្នឹងគ្មានចេះភាសាវៀតណាមមួយម៉ាត់ទេ ពីព្រោះគាត់ធ្វើបុណ្យ ធ្វើទានជាមួយនឹងពុទ្ធសាសនិកជនខ្មែរទាំងអស់ រាល់ពេល។ គាត់និយាយតែភាសាខ្មែរ សូម្បីតែវៀតណាមនៅមួយគ្រួសារទៀត ឈ្មោះគ្នា ខ្ញុំសួរទៅថា អូនឯងដឹងគេឈ្មោះគ្នារឿងអី? គាត់ឆ្លើយថាមិនដឹងទេ ពីព្រោះគាត់អត់ចេះភាសាហ្នឹងទេ គាត់រៀនតាំងពីតូចកុមារដ្ឋាន បរិវច្ឆនដ្ឋានឡើង រហូតដល់ថ្នាក់ទី៤ ប្រឡងឌីប្លូមថែមទៀត។ ដូច្នេះគ្មានអ្វីជាមូលដ្ឋានគាត់សោះ។ ហើយខ្ញុំបាទហាក់ដូចជាបានស្ងប់ចិត្តដែរ ព្រោះឃើញថា បងប្អូនអាណិកជនវៀតណាមអីគេនាំគ្នាទៅវៀតណាមមុនសភាពការណ៍នោះ ប្រហែលពីរបីបួនខែមុន ប៉ុន្តែយើងឃើញថា ប្តីកម្ពុជាហើយកូនមុខជាគេយល់ថា មិនពាក់ព័ន្ធអីទេ។ ប៉ុន្តែផ្ទុយទៅវិញ របបនេះបែរជាចាប់សម្លាប់ កុំថាតែមនុស្សសូម្បីតែកូនអំបាតមួយ ក៏មិនឲ្យរួចដែរ។ នេះគឺវាតាមដែលពិនិត្យមើលឃើញទៅ ការតាមដានស៊ើបអង្កេតស្និតស្នាញក្រាញ់រនៀលរបស់ពួកគេនុ៎ង គឺខ្លាំងក្លាជ្រាលជ្រៅ ហើយមុតស្រួចខ្លាំងណាស់ ដាច់ខាតអ៊ីចឹងតែម្តង។ បាទ សូមអស់ សូមចប់ សូមអស់យោបល់។

**ស៖** ខ្ញុំសូមសួរលោកលម្អិតអំពីម្តាយក្មេករបស់លោក តើលោកមានព័ត៌មានអ្វីបន្ថែម ថាតើគាត់នេះ ត្រូវបានគេសម្លាប់នៅពេលណា? ហើយស្លាប់ដោយរបៀបណា លោកដឹងដែរទេ?

[០៩:២៤:៥៥]

**ឆ៖** បាទ សូមអរគុណ។ ព័ត៌មានបន្ថែមពីម្ដាយក្មេកខ្ញុំបាទឈ្មោះ វៀង ធីបេ នេះគឺក្រោយថ្ងៃ ០៧ មករា ប្រហែលជាបីបួនខែក្រោយបានដឹង។ បានដឹងថាគេហៅឈ្មោះកូនកាត់វៀតណាមហ្នឹង មកជុំគ្នានៅវត្ត ហើយបង្ខំឲ្យឡើងឡានទៅទាំងអស់គ្នា។ យកទៅសម្លាប់ចោលនៅខាងភ្នំព្រិច ផ្លូវទៅវៀត-ណាម ផ្លូវពីក្រចេះទៅឡុកនិញ។ ដោយវិធីណាគឺមិនដឹងទេ ប៉ុន្តែអ្វីទាំងអស់ត្រូវចប់ត្រឹមហ្នឹងហើយ ដោយសារមនុស្សបំផុតនៅស្លាប់ហ្នឹងហើយ ដែលអស់ អស់។ នេះគឺដឹងក្រោយតាមរយៈតៃកុងឡាន ឈ្មោះ អាង គាត់ថា ម៉ែក្មេកគ្រូឡាយឯងអីហ្នឹង គឺនៅហ្នឹងទាំងអស់។ ពួកខ្ញុំដឹកទៅដល់ភ្លាម ដេញគេឲ្យចុះព្រួសៗ។ ពួកទាហានកម្ពុជាប្រជាធិបតេយ្យហ្នឹងមកភ្ជង់ភ្លាម ឲ្យឡានបត់មកវិញភ្លាម ហើយបណ្ដើរពួកហ្នឹងឡើងទៅលើភ្នំព្រិច ដឹងធ្វើយ៉ាងម៉េចទៀត។ គាត់បានប្រាប់តែប៉ុណ្ណឹងនៅក្រោយរំដោះ ហើយទេបានដឹង។ សូមអស់ សូមចប់យោបល់។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមអានសម្រង់មួយចេញពីពីទម្រង់ព័ត៌មានបន្ថែមរបស់លោក ដើម្បីជួយរំឭកដល់ការចងចាំរបស់លោក។ គឺពាក់ព័ន្ធទៅអ្វីដែលលោកបានដឹង ទាក់ទងទៅនឹងម្ដាយក្មេករបស់លោក គឺឯកសារ E3/4845, <ERN អង់គ្លេស 01057867, បារាំង 009>--

**អ្នកបកប្រែ៖**

លោកប្រធាន សូមការអនុញ្ញាតឲ្យសហព្រះរាជអាជ្ញារងបន្ថយល្បឿនបន្តិច។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារង! ញាប់ពេក ហើយអានយឺតៗ ដើម្បីឲ្យអ្នកបកប្រែបកក្តាប់បាន ហើយបកទាន់ណា។

[០៩:២៧:០១]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ខ្ញុំចាប់ផ្ដើមសាជាថ្មី ERN អង់គ្លេស01057867, បារាំង00923036, ខ្មែរ 00613037។ លោក អ៊ុច ស៊ុនឡាយ នេះគឺជាសម្ដីរបស់លោក សូមដកស្រង់៖ “នៅចុងឆ្នាំ៧៨ ម្ដាយក្មេងរបស់ខ្ញុំ វៀង ធីបេ ដែលជាជនជាតិវៀតណាម ត្រូវឈ្លបខ្មែរក្រហមឲ្យឡើងជិះឡានសំដៅទៅវត្តក្រគរ នៅក្នុងឃុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្រគរ <ស្រុកក្រចេះ> នៅខេត្តក្រចេះ គឺគេថាឲ្យទៅត្រឡប់ទៅវៀតណាមវិញ។ ក៏ប៉ុន្តែខ្ញុំ<ដឹងក្រោយមក>ថា<គាត់ ហើយនិង>ជនជាតិវៀតណាមទាំងអស់នោះ គឺថាមិនត្រូវបានគេបញ្ជូនទៅប្រទេសវៀតណាមទេ គឺត្រូវបានយកទៅសម្លាប់នៅតាមផ្លូវ<ទៅភ្នំ៥០០០ ស្ថិតនៅក្នុងស្រុក>ស្នួល <ខេត្តក្រចេះ។" បញ្ចប់ការដកស្រង់។ លោកដើមបណ្តឹងរដ្ឋប្បវេណី តើព័ត៌មានដែលលោកបានរៀបរាប់នេះវាស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោកកំពុងតែរៀបរាប់នៅទីនេះទេ?

**លោក អ៊ុច ស៊ុនឡាយ៖**

**ឆ៖** បាទ សូមអរគុណ។ គឺពិតប្រាកដអ៊ីចឹងមែន។ ពួកឈ្លបប៉ុល ពត បានហៅឲ្យទៅជួបជុំគ្នាឡើងឡាននៅក្នុងវត្តក្រគរ ហើយដឹកចេញពីវត្តក្រគរ តម្រង់ទិសទៅខាងប្រទេសវៀតណាម ពីព្រោះមានផ្លូវមួយពីក្រចេះកាត់តាមឡូកនិញទៅវៀតណាម តាំងពីដើមមករហូតដល់បច្ចុប្បន្ននេះ។ តែទៅឈប់ត្រង់ណា យកចេញបណ្តើរពីត្រង់ណា ខ្ញុំបាទមិនបានដឹងទៀតទេ។ ហើយការដឹងហ្នឹង សូមបញ្ជាក់ជូនថា តាមរយៈអ្នកបើករថយន្តនោះ ដែលក្រោយមកគាត់បានមកនិយាយប្រាប់អ៊ីចឹង។ សូមចប់ សូមអស់យោបល់។

[០៩:២៩:១២]

**ស៖** លោកបានរៀបរាប់កាលពីម្សិលមិញ អំពីការបង្ខំឪពុកក្មេងរបស់លោកឲ្យរៀបការឡើងវិញ ក្រោយពីយកម្តាយក្មេកទៅសម្លាប់ចោលហើយ។ តើឪពុកក្មេករបស់លោកហ្នឹង បានរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យដែរឬក៏អត់ទេ?

**ឆ៖** បាទ សូមអរគុណ។ ឪពុកក្មេកខ្ញុំបាទឈ្មោះ ចាយ គឹមអេង ហៅស្មៀនអ៊ី។ គាត់ជាស្មៀនឃុំ នៅឃុំក្រចេះ ខេត្តក្រចេះ ត្រូវបានគណៈសហករណ៍ ប៉ុល ពត យកទៅបង្ខំឲ្យរៀបការជាថ្មីជាមួយនឹងឈ្មោះ មីងឡេន ដែលគាត់អាយុជិត៦០ហើយនោះ ក្នុងគូទី១១។ រាប់ពី១, ២, ៣, ៤ រហូត១១ គឺគូគាត់ ចាយ គឹមអេង (ស្មៀនអ៊ី) ជាមួយនឹង មីងឡេន។ ហើយអ្នកទាំងពីរហ្នឹងក្រោយមកក៏ត្រូវគេសម្លាប់ទៅ។ រីឯមូលហេតុយ៉ាងណានោះ គឺខ្ញុំបាទមិនបានដឹងទេ ហើយឃើញអ្នកទាំងពីរហ្នឹង គឺទទូរក្រមា១ដែលគេឲ្យហ្នឹង យំហើមភ្នែកទាំងអស់ បានន័យថាគាត់មិនស្មោះស្ម័គ្រ និងចង់រៀបការទេ ពីព្រោះប្រពន្ធមុននឹង ស្លាប់នៅក្នុងអំឡុងខែ១១អីហ្នឹង ១០, ១១ហ្នឹង ហើយមកខែ១២ បានបង្ខំឲ្យរៀបការ ហាក់ដូចជា ហៅថាចាប់បញ្ឆោក ឬក៏ប្រើវិធីដើម្បីគាបត្បៀត ដាក់សម្ពាធលើតែម្តង។ រីឯការស្លាប់របស់គាត់ហ្នឹង ខ្ញុំបាទមិនបានដឹងទេ គ្រាន់តែក្រោយមកបានឮថា គេយកស្មៀនអ៊ីហ្នឹងទៅសម្លាប់ចោល

នៅទំនប់ក្បាលទន្សោង ខាងកើតឃុំក្រគរ ស្រុកក្រចេះ ខេត្តក្រចេះ តែទីតាំងសម្លាប់ត្រង់ណាក៏ខ្ញុំបាទមិនបានដឹងដែរ។ ម្ល៉ោះហើយយើងចង់រកសាកសព ឬក៏កាកសំណល់នៃឧក្រិដ្ឋកម្មហ្នឹងមកធ្វើបុណ្យទានតាមប្រពៃណីក៏មិនបានដោយយើងមិនដឹងរកមិនឃើញ លុះបច្ចុប្បន្ននេះ។ សូមអស់ សូមចប់យោបល់។

[០៩:៣១:៣៩]

**ស៖** តើលោកដឹងទេ ហេតុអ្វីបានជាគេសម្លាប់ឪពុកក្មេករបស់លោក?

**ឆ៖** បាទ សូមអរគុណ។ ដែលតាមខ្ញុំបាទដឹង គឺទី១ គាត់ជាមន្ត្រីរាជការសម័យមុន របស់រដ្ឋាភិបាល តាំងពីសម័យ សីហនុ សម័យលន់ នល់ រហូតដល់សម័យប៉ុល ពតហ្នឹងទៀត។ គេដឹងគាត់ ថា គាត់ហ្នឹងស្មៀនឃុំ បានស្មៀនឃុំ ក្រចេះៗក្រុង អាហ្នឹងទី១។ ទី២ទៀត គឺពាក់ព័ន្ធនឹង កា.ហ្វេ.បេ គឺវៀតណាម ពីព្រោះគាត់យកប្រពន្ធវៀតណាម ដែលបានកូនមកទៅជាកូនកាត់ ហើយចៅមកទៅជាចៅកាត់នោះ។ ដូច្នេះវាមានពីរចំណុចហ្នឹង បូកផ្សំជាមួយនឹងគាត់ថា គាត់មិនអាចរស់បានទេ ដោយសារប្រពន្ធកូនចៅទាំងអស់ ត្រូវពួកប៉ុល ពត យកទៅសម្លាប់បាត់អស់ទៅហើយ តើឲ្យគាត់រស់នៅជាមួយអ្នកណា? ដូច្នេះគាត់មិនសប្បាយចិត្តជាមួយនឹងការដែលអង្គការចាប់បង្ខំឲ្យរៀបការជាមួយនឹងគូថ្មីដែលជា គេហៅថាប្រភេទជនទី៣។ វាមានទី១ គឺពេញសិទ្ធិ។ ទី២ គឺផ្ញើ ឬបញ្ញើ -- ត្រៀម។ ទី៣ គឺពលរដ្ឋផ្ញើ។ ពលរដ្ឋផ្ញើហ្នឹង គឺងាយនឹងផុយស្រួយគេយកទៅទាំងយប់ទាំងថ្ងៃ មិនអាចដឹងថ្ងៃរម៉ានជាថ្ងៃរម៉ានទេ។ នេះគឺមានមូលហេតុ និងចំណុចទាំងអស់ហ្នឹងហើយដែលយើងវាយតម្លៃថា ពិតជាគោលដៅនៃការចាប់សម្លាប់របស់កម្ពុជាប្រជាធិបតេយ្យនេះ។ បាទ សូមអស់ សូមចប់យោបល់។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី នេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយ។ លោកបាននិយាយអំពីបងប្អូនថ្លៃរបស់លោក ព្រមទាំងកូនរបស់ពួកគាត់ដែលស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះខ្ញុំចង់ឲ្យលោករៀបរាប់ ប្រសិនបើលោកចាំអំពីកាលៈទេសៈ ឬក៏ហេតុការណ៍នៃៗការស្លាប់របស់បងប្អូនថ្លៃរបស់លោក។ ខ្ញុំចង់ថាតើគេសម្លាប់ពួកគាត់នៅពេលណា? គេសម្លាប់ដោយរបៀបណា? និងតើហេតុអ្វីបានជាគេសម្លាប់ពួកគាត់? ប្រសិនបើលោកដឹង សូមលោករៀបរាប់។

[០៩:៣៤:៣០]

**ឆ៖** បាទសូមអរគុណ។ ការចាប់យកទៅកាប់សម្លាប់របស់ពួកកងឈ្លបកម្ពុជាប្រជាធិបតេយ្យនេះ គឺធ្វើជាសម្ងាត់។ គេថាមិនបាច់ចំណាយគ្រាប់រំសេវអីទេ។ សម្ងាត់យ៉ាងម៉េច? គឺឧទាហរណ៍ថាគេបញ្ជូនប្តីៗហ្នឹងឲ្យទៅកាប់បង្គោងត្នោតនៅទីឆ្ងាយ ហើយគេជម្លៀសប្រពន្ធៗនិងកូនៗអ្នកទាំងអស់ហ្នឹង

ទៅនៅកណ្តាលទឹកណោះ គឺកោះទ្រង់នោះ ដែលពិបាកនឹងទៅមក ព្រោះត្រើយម្ខាងទៀត គឺជាភូមិភាគកណ្តាល។ រីឯខាងត្រើយខេត្តក្រចេះនោះ គឺជាតំបន់៥០៥។ ដូច្នេះបើតាមផែនទីរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ គឺអត់មានឲ្យឆ្លងកាត់គ្នាបានទេ។ ដូច្នេះអំណោយផល ងាយយកទៅវ៉ៃសម្លាប់នៅទីកណ្តាលកោះ កណ្តាលទឹកហ្នឹងតែម្តង។ ហើយចង់បញ្ជាក់ជូនថា ក្រៅពីប្រពន្ធ និងកូនខ្ញុំផ្ទាល់ គឺមានសាច់ថ្លៃគឺប្អូនរបស់ សា គឹមនី ហ្នឹងឈ្មោះ សា គឹមណា។ រីឯប្តីរបស់ សា គឹមណា ហ្នឹងឈ្មោះ ជិន សាអ៊ីម ក៏ត្រូវគេយកទៅសម្លាប់ដែរ ដោយសារវាទាក់ពីកូនចៅវៀតណាម កា.ហ្សេ.បេ ហ្នឹង។ ហើយកូនរបស់ សា គឹមណា ជាមួយហ្នឹង ជិន សាអ៊ីម ហ្នឹង ឈ្មោះ សារីន, ឈ្មោះ សារៈ អីហ្នឹងក៏ត្រូវកាប់សម្លាប់ដែរ ពីព្រោះតាមទ្រឹស្តីដែលថា "ជីកស្មៅត្រូវជីកទាំងឫស" ហ្នឹង។ ដូច្នេះវាបន្តគ្នារហូត។ រហូតមកដល់ពេលនេះ ខ្ញុំអត់មានសេសសល់កូនកាលពីជំនាន់នោះទេ។ មិនមែនយកតែម្តាយទៅសម្លាប់ហើយទុកកូនឲ្យនៅទេ គឺសម្លាប់ទាំងម្តាយទាំងកូន ទាំងម្តាយទាំងកូន ដែលជាបញ្ហាមួយធ្វើឲ្យអ្នកដែលរស់នៅហ្នឹងសែនក្តុកក្តួល នៅសល់តែប៉ុន្មានខែទៀតនឹងដល់ថ្ងៃរំដោះ។ ខ្ញុំមានទុក្ខព្រួយខ្លាំងណាស់ដោយសារ រស់មិនបានឆ្លងផុតមិនរួច។ អស់ទាំងគេ គេបានឆ្លងផុតរួច ដោយឡែកខ្ញុំ និងប្រពន្ធកូន បងថ្លៃ ប្អូនថ្លៃ គឺត្រូវពួកទាហានអាវខ្មៅហ្នឹងយកទៅសម្លាប់ចោលទាំងអស់ អត់មានមេត្តាករុណា ឬមនោសញ្ចេត-នាអ្វីទេ។ ត្រង់ហ្នឹងហើយដែលខ្ញុំចង់សួរទៅមេដឹកនាំជាន់ខ្ពស់ កម្ពុជាប្រជាធិបតេយ្យ។ សួរថា ហេតុអ្វីបានជាអស់លោកមានគោលនយោបាយសម្លាប់ទាំងកូនក្មេង កូនង៉ា ទារក ទារិកាហ្នឹងអស់រលីងហ្នឹង ដើម្បីអស់លោកហ្នឹងក្លាយទៅជាព្រះអាទិទេពលើពិភពលោក ឬយ៉ាងម៉េច?

[០៩:៣៧:០៧]

**ប្រធានអង្គជំនុំ៖**

លោក១ចាំក្រោយទៅអាហ្នឹងណា កុំឲ្យវានីតិវិធីវាច្របូកច្របល់។ ចាំចុងក្រោយ អង្គជំនុំជម្រះនឹងផ្តល់សិទ្ធិដល់លោកក្នុងការថ្លែងចុងក្រោយ ហើយនិងការតាំងសំណួរចំពោះ តាមរយៈប្រធានចំពោះជនជាប់ចោទ ប្រសិនបើលោកមានបំណង។ លោកត្រៀមឆ្លើយនឹងសំណួរសិនទៅ ហើយពេលវេលាដូចជាច្រើនហើយ សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក ចូសេហ្វ អេនទ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានសំណួរបន្ថែមទៀតទេ។ សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណីដែលបានមកផ្តល់ចម្លើយនៅទីនេះ ហើយបានពិភាក្សាពីបញ្ហាដែលលោកពិបាកក្នុងការ

និយាយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

បាទ សូមអរគុណ លោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា។ ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

**ស៖** ខ្ញុំមានសំណួរមួយសួរទៅលោក លោកបានឆ្លើយថា លោកនៅតំបន់៥០៥។ តើលោកអាចរៀបរាប់អំពីរចនាសម្ព័ន្ធនៃតំបន់៥០៥ហ្នឹងបានដែរឬទេ?

[០៩:៣៨:៣៥]

**លោក អ៊ុច ស៊ុនឡាយ៖**

**ឆ៖** បាទ សូមអរគុណលោកចៅក្រម។ ខ្ញុំបាទរស់នៅតំបន់៥០៥។ តំបន់៥០៥ ហ្នឹងគឺនៅខេត្តក្រចេះហ្នឹងជាតំបន់ស្វយ័ត។ តំបន់ស្វយ័ត ហ្នឹងមិនស្ថិតនៅក្រោមការដឹកនាំនៃភូមិភាគទេ ដោយឡែក។ ហ្នឹងតាមដែលខ្ញុំបាទដឹង ពីព្រោះអ្នកដែលជាប្រធានតំបន់៥០៥ហ្នឹង ធ្លាប់រៀនសូត្រនៅលើសេកុសុមៈហ្នឹងជាមួយគ្នា ឈ្មោះ បូណាន។ តែចុងក្រោយបំផុតគាត់ ក៏ត្រូវគណៈបូព៌ាយកទៅសម្លាប់ផងដែរ។ ខ្ញុំបាទគ្រាន់តែដឹងតែពីរឿងតំបន់ស្វយ័តតែប៉ុននុ៎ងទេ រីឯរចនាសម្ព័ន្ធយ៉ាងណានោះ គឺមិនបានដឹងទេ។ សូមចប់ សូមអស់យោបល់។

**ស៖** អ៊ីចឹងលោកនិយាយថា តំបន់ស្វយ័តនេះមិននៅក្នុងចំណុះរបស់ភូមិភាគទេ។ អ៊ីចឹងលោកតើលោកដឹងដែរឬទេថា តំបន់នេះរាយការណ៍ទៅថ្នាក់ណា? តើមានអង្គភាពណាដែលនៅលើតំបន់៥០៥នេះ? អ្នកណាគេ<នៅពីលើ>តំបន់៥០៥នេះ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបាទមិនបានដឹងដល់រចនាសម្ព័ន្ធរបស់គណៈតំបន់ គណៈភូមិភាគគណៈហ្នឹងអស់ទេ តែតាមដែលដឹងក្រៅផ្លូវការ គឺដឹកនាំដោយគណៈតំបន់១។ រីឯភូមិភាគគឺផ្សេង ចុងក្រោយហើយទេ ទើបខ្ញុំបាទបានដឹងថា ពេលដែលគណៈតំបន់៥០៥ហ្នឹងគេថាក្បត់គេយក គណៈភូមិភាគឦសានយកមកដាក់។ ដល់ក្រោយមកទៀត ឮថាចាប់គណៈភូមិភាគឦសានហ្នឹងទាំងអស់ ថាពួក

ហ្នឹងក្បត់ គេយកគណៈពីភូមិភាគបូព៌ាយកមកដាក់គ្រប់គ្រងវិញទៅ។ ក្រោយមកទៀតថាបូព៌ាហ្នឹងក្បត់ គេយកពីគណៈភូមិភាគនិរតីទៅដាក់ទៀត សុទ្ធតែមុខប្លែកៗ និងនេះទាំងអស់។ ខ្ញុំបាទដឹងបានតែប៉ុណ្ណឹងបាទ។ សូមអរគុណ។

[០៩:៤១:២៥]

**ស៖** បាទ ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ គឺ<លោកបាននិយាយ>ថាលោក<បានឃើញ>ការបោសសម្អាតជាបន្តបន្ទាប់នៅក្នុងចំណោមអ្នកដឹកនាំតំបន់៥០៥។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ នេះបើសិនជាលោកចាំថាតើអ្នកណាជាប្រធានតំបន់៥០៥ នៅពេលដែលភរិយារបស់លោក ហើយនិងសមាជិកគ្រួសារ<សាច់>ថ្លៃរបស់លោកត្រូវបាន<សម្លាប់>នោះ? តើជាកម្មាភិបាលពីដើមទីតែម្តង ឬក៏ជាកម្មាភិបាលមកពីភូមិភាគពាយ័ព្យ ឬក៏ពីភូមិភាគបូព៌ា ឬក៏មកពីនិរតី <ឬកម្មាភិបាលណាផ្សេងទៀត> លោកដឹងដែរឬទេ? សូមជម្រាបជូនតុលាការ បើសិនជាដឹង។

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបាទ សូមជម្រាបជូនតុលាការថា គ្រូបង្រៀនពីសម័យមុន ដូចរូបខ្ញុំដែរនោះ គឺត្រូវបានរត់ចូលព្រៃ ហើយកសាងខ្លួនឡើងជាគណៈតំបន់៥០៥។ មានឈ្មោះដើមថា បូណាន គាត់ដូរឈ្មោះក្នុងបដិវត្តហៅថាសមមិត្ត យី តំបន់៥០៥។ ហើយប្រធានតំបន់នោះគឺលោកគ្រូឈ្មោះ សឹម សុន ហើយដូរឈ្មោះជាសមមិត្ត យ៉ែម។ ក្រោយមកគេបញ្ជូនសមមិត្ត យ៉ែម ហ្នឹងទៅធ្វើទូតនៅកូរ៉េ។ រីឯគ្រូៗមួយចំនួនទៀតដែលតែងតែរិះគន់ និងតិះដៀលខ្ញុំបាទនៅខាងក្រៅជាប្រជាពលរដ្ឋនោះត្រូវស្លាប់បានបាត់បង់ជីវិតទាំងអស់ ដោយសារថាពួកគណៈតំបន់៥០៥ហ្នឹងក្បត់ៗនឹងបដិវត្តន៍ ហៅថាធ្វើបន្សុទ្ធកម្មនៃចលនាហ្នឹងបាទ។ គេយកគណៈភូមិភាគឦសានយកទៅដាក់។ ហើយក្រោយមកទៀតប្រហែលរំលងពីរបីខែ គណៈភូមិភាគឦសានត្រូវក្បត់ទៀត គេយកពីភូមិភាគបូព៌ាទៅដាក់ទៀត។ ចុងក្រោយហើយ បានថាគណៈភូមិភាគបូព៌ាហ្នឹង គឺពួកក្បត់ ធ្វើទុក្ខទោសម្នេញប្រជាពលរដ្ឋ គេដាក់គណៈនិរតីនេះយកទៅដឹកនាំម្តងវិញ។ ខ្ញុំបាទ ដឹងបានតែប៉ុណ្ណឹងបាទ។ សូមចប់ សូមអស់យោបល់។

[០៩:៤៤:០៥]

**ស៖** បាទ សូមអរគុណដែលបានឆ្លើយបំភ្លឺទាំងអស់នេះ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់ដឹងនោះ គឺថានៅពេលដែលភរិយារបស់លោក និងកូន<ៗ>របស់លោក និងសមាជិកនៃគ្រួសារ<សាច់>ថ្លៃរបស់លោកត្រូវបានគេសម្លាប់ បើតាមលោកចាំនោះ ថាតើអ្នកណាជាប្រធានតំបន់៥០៥នៅសម័យនោះ<? តើ>កម្មាភិបាល<ដែលឈរជើងនៅពេលនោះ ជានរណា>? តើជាកម្មាភិបាលរបស់ភូមិភាគពាយ័ព្យ ឬក៏ពី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01454731



ភូមិភាគបូព៌ា ឬក៏ជាកម្មាភិបាលរបស់និរតី? ខ្ញុំចង់និយាយអំពីពេលដែលគេសម្លាប់ភរិយារបស់លោក និងក្រុមគ្រួសារ<សាច់>ថ្លៃរបស់លោក អ្នកណាជាប្រធានតំបន់ដែលលោកនៅនោះ តំបន់ស្វាយ័តហ្នឹង? <បើលោកមិនចាំ លោកអាចឆ្លើយថាមិនចាំទៅ មិនអីទេ។>

**ឆ៖** បាទ សូមអរគុណ។ ការងារចាត់តាំងថ្នាក់លើរបស់គេនោះ ខ្ញុំបាទអត់បានដឹងទាំងអស់ ប៉ុន្តែចុងក្រោយគ្រាន់តែដឹងថា គឺថាគណៈតំបន់៥០៥ហ្នឹងក្បត់។ គេដាក់គណៈតំបន់ -- ភូមិភាគពួកសាន យកទៅដាក់។ ហើយក្រោយមកទៀតថា គណៈភូមិភាគពួកសានហ្នឹង សុទ្ធតែពួកក្បត់។ គេយកពីបូព៌ា យកទៅដាក់។ ហើយក្រោយមកទៀតគណៈភូមិភាគបូព៌ាថា សុទ្ធតែពួកក្បត់ទៀត ទើបគេយកគណៈភូមិភាគនិរតីទៅដាក់។ ខ្ញុំបាទមិនដឹងថាឈ្មោះអី នៅឯណាយ៉ាងម៉េចទេ គឺដឹងតែប៉ុណ្ណឹង។ សូមចប់ សូមអស់យោបល់។

[០៩:៤៥:០០]

**ស៖** សំណួរខ្ញុំនោះ មិនមែនសួររកឈ្មោះទេ តែសំដៅលើកាលបរិច្ឆេទ។ បើខ្ញុំមិនច្រឡំទេ គឺលោកបាននិយាយថា ការសម្លាប់ប្រពន្ធរបស់លោក ហើយនិងកូន<ៗ>របស់លោកនុ៎ងបានធ្វើនៅខែកញ្ញា ឆ្នាំ១៩៧៨។ តើនៅខែកញ្ញា ឆ្នាំ១៩៧៨នេះ លោកដឹងថា នៅពេលនោះជាកម្មាភិបាលមកពីបូព៌ា ឬក៏ពាយ័ព្យ ឬក៏ពួកកម្មាភិបាលមកពីនិរតីទេ <>មកកាន់កាប់តំបន់ដែលលោកនៅនេះ តំបន់ពិសេសនេះ? ពេលនុ៎ងអ្នកមកពីខាងណា? <តើលោកយល់សំណួរខ្ញុំទេ? សំណួរពាក់ព័ន្ធនឹងកាលបរិច្ឆេទ ហើយនិងកម្មាភិបាលដែលឈរជើងនៅទីនោះ។> ខ្ញុំយល់ពីការកាប់សម្លាប់គ្នាជាបន្តបន្ទាប់ ឬការក្បត់គ្នាជាបន្តបន្ទាប់នោះហើយ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា តើនៅខែកញ្ញា ឆ្នាំ១៩៧៨នេះ នៅពេលដែលគេសម្លាប់ប្រពន្ធលោកនោះ តើអ្នកណាជាអ្នកដឹកនាំតំបន់៥០៥នេះ?

**ឆ៖** បាទសូមអរគុណ។ ការបញ្ហាសំណួរនេះ ខ្ញុំបាទយល់ពីលោកចៅក្រមមានយោបល់ហើយ តែក្នុងខែកញ្ញា តុលា វិច្ឆិកា និងធ្នូហ្នឹង គឺចុងក្រោយឈ្មោះ សមមិត្ត បឿន ទៅពីភូមិភាគនិរតី ទៅកាន់កាប់កន្លែងនុ៎ង។ សូមអរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំអស់សំណួរសួរលោកហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមសហមេធាវីការពារក្តី។ ដំបូងនេះផ្តល់ទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមានសំណួរ។ សូមអញ្ជើញ!

[០៩:៤៨:១៥]

**លោក សុន អរុណ៖**

ក្រុមមេធាវីការពារលោក នួន ជា មិនមានសំណួរទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយចុងក្រោយ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក គង់ សំអុន៖**

**ស៖** ហើយសូមជម្រាបសួរដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំបាទ គង់ សំអុន ជាសហមេធាវីជាតិរបស់លោក ខៀវ សំផន។ ខ្ញុំសូមសួរលោកសំណួរមួយចំនួន។ ជាដំបូងខ្ញុំចង់សួរលោកអំពីទីតាំងនៅក្រចេះ ទីតាំងដែលលោករស់នៅហ្នឹង ថាតើខ្មែរក្រហម ឬក៏កងទ័ពរំដោះ បានចូលកាន់កាប់នៅតំបន់ភូមិឃុំរបស់លោកហ្នឹង ពីឆ្នាំណាដែរ?

[០៩:៤៩:២៣]

**លោក អ៊ុច ស៊ុនឡាយ៖**

**ឆ៖** បាទ សូមអរគុណ។ សូមគោរពលោកប្រធាន ក៏ដូចគោរពលោកមេធាវីការពារជនជាប់ចោទដែរ។ ខេត្តក្រចេះហ្នឹងត្រូវបានរំដោះមុនគេនៅទូទាំងប្រទេស ព្រោះជំនាន់នោះរណសិរ្សសាមគ្គីសង្គ្រោះជាតិនុំង តាំងពីថ្ងៃ២៣ មីនា ពេលដែលសម្តេច សីហនុ ប្រកាសពីប៉េកាំង ក្រោយរដ្ឋប្រហារហ្នឹងឯង ១៨ មីនា ឆ្នាំ៧០។ ដូច្នេះគឺមុនដំបូងហ្នឹង គឺរំដោះខេត្តក្រចេះហ្នឹង។ ខេត្តក្រចេះរំដោះពីថ្ងៃ០៥ មីនា ១៩៧០ មុនខេត្តនានានៅទូទាំងប្រទេស។ ម្ល៉ោះហើយចលនាហ្នឹង គឺខ្លាំងខ្លា ហៅថាប្រៀបដូចទឹកបាក់ទំនប់អ៊ីចឹង។ យុវជន នារីភាគច្រើនគឺសុទ្ធតែចូលជួរទាំងអស់ រហូតដល់គ្រូបង្រៀន សាស្ត្រាចារ្យ

ជាដើម ។ល។ ដូច្នេះខ្ញុំបាទជម្រាបខ្លីថា ខ្ញុំបាទនៅខេត្តក្រចេះ គឺភូមិក្រគរ ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ។ បាទ សូមចប់ សូមអស់យោបល់។

**ស៖** បាទ សូមអរគុណ។ ម្សិលមិញលោកមានប្រសាសន៍អំពីការផ្លាស់ប្តូរពាក្យសម្តីគ្នារវាងលោក ហើយនិងគ្រូៗមួយចំនួនដែលធ្វើការជាមួយលោក ដែលថាលោកថាលោកមិនចូលបដិវត្តន៍ជាមួយទេនោះ។ តើការដែលខាងក្រុមគ្រូៗមួយចំនួនរត់ចូលបដិវត្តន៍ហ្នឹង ឆ្នាំណាដែរ លោកចាំទេ មិត្តភក្តិរបស់លោកហ្នឹងណា?

**ឆ៖** បាទ សូមអរគុណលោកមេធាវី។ មិត្តភក្តិរបស់ខ្ញុំហ្នឹង បានរត់ចូលជួរធ្វើបដិវត្តន៍ហ្នឹងតាំងពីឆ្នាំ១៩៦៨មកម្ល៉េះគឺមុនឆ្នាំ៧០ហ្នឹងទៅទៀត។ គឺពួកគេសុទ្ធតែជាសិស្សច្បង វាមច្បង គ្រូ សាស្ត្រាចារ្យនៅវិទ្យាល័យព្រះកុសមៈនោះ។ ហើយគេបានតាមដានស្រាវជ្រាវរកឈ្មោះមិត្តភក្តិដែលរួមជំនាន់ ដើម្បីពួតផ្គុំទៅជាកម្លាំង ក្នុងនោះមានតែខ្ញុំបាទម្នាក់ទេដែលបដិសេធ ហើយមិនហ៊ានចូលនឹងគេ ព្រោះខ្ញុំបាទយល់ឃើញថា ទី១ យើងក្រីក្រខ្វះខាត។ គេថាអាវណ្ណៈហ្នឹងហើយដែលគេត្រូវការ ត្រូវការវណ្ណៈអធនហ្នឹងរបស់កម្មករ កសិករហ្នឹង។ លោកឯងត្រូវដឹងណា ថាថ្ងៃពិតជារះក្រហមផ្លិនផ្លៅនៅទីខាងកើតហើយអាគក ទោះបីឯងរងាវក៏ដោយ មិនរងាវក៏ដោយក៏ថ្ងៃនៅតែរះដែរ។ បដិវត្តន៍មិនអាចធ្វើតែពាក់កណ្តាលផ្លូវ ហើយលុបចោលទេ។ ដំណេកអាចដេកពាក់កណ្តាលយប់បាន ហូបបាយអាចហូបពាក់កណ្តាលឆ្អែតបាន តែការធ្វើបដិវត្តន៍នេះ ត្រូវធ្វើឲ្យចប់ចុង ចប់ដើម...។ល។ គេបានផ្តល់--

[០៩:៥២:២៨]

**ស៖** បាទៗ សូមអរគុណ។ ខ្ញុំបាននឹងស្តាប់អ្វីដែលលោករៀបរាប់អម្បាញ់មិញនេះពីម្សិលមិញដែរ។ អ៊ីចឹងខ្ញុំសូមសួរទៅសំណួរមួយទៀត ទាក់ទងទៅនឹងកាលបរិច្ឆេទនៃការបញ្ជូនម្តាយក្មេករបស់លោក ហើយនិងកាលបរិច្ឆេទការស្លាប់ ឬក៏ត្រូវគេសម្លាប់ឪពុកក្មេករបស់លោក។ លោកចាំបានទេថា ឆ្នាំណាដែលម្តាយក្មេករបស់លោកត្រូវគេបញ្ជូនទៅវៀតណាមនុ៎ង ដែលក្រោយមកលោកថា ត្រូវគេសម្លាប់នៅតាមផ្លូវ?

**ឆ៖** បាទ សូមអរគុណ។ ឆ្នាំដែលគេចាប់ម្តាយក្មេកខ្ញុំយកទៅនេះ គឺក្នុងឆ្នាំ១៩៧៨។

**ស៖** លោកអាចចាំខែបានទេ ហើយឬក៏កាលៈទេសៈណាដែលអាចចាំថា ក្នុងចន្លោះខែណាបានទេ?

**ឆ៖** បាទ សូមអរគុណ។ ក្នុងចន្លោះខែ១០ ទៅខែ១១ ឆ្នាំ១៩៧៨។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ផងដែរ ពីម្សិលមិញថា ឪពុកក្មេករបស់លោកត្រូវបានបង្ខំឲ្យរៀបការ ហើយព្រឹកមិញនេះក៏លោកបានបញ្ជាក់ផងដែរ។ តើលោកអាចបញ្ជាក់ពីចន្លោះពេលដែលឪពុកក្មេករបស់លោកត្រូវរៀបការសាឡើងវិញបានទេ រយៈពេលប៉ុន្មានខែក្រោយពីបាត់ម្ដាយក្មេករបស់លោកទៅ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាល់ទាន់!

[០៩:៥៥:២៣]

**លោក អ៊ុំ ស៊ុនឡាយ ៖**

**ឆ៖** បាទ សូមអរគុណ។ គឺម្ដាយក្មេកខ្ញុំ ខ្ញុំប៉ាន់ស្មានថា ក្នុងខែ១០-៧៨ គេយកទៅ ហើយឪពុកក្មេកហ្នឹងត្រូវគេចាប់បង្ខំឲ្យរៀបការថែមទៀត ក្នុងរវាងខែ១១ ១៩៧៨។ ទោះបីជារៀបការហើយក៏ដោយ ក៏គេមានពួកកងឈ្លបតាមដានទៅដល់ផ្ទះដល់សម្បែងទៀត ថាតើពីរនាក់ហ្នឹងចុះសម្រុងនឹងគ្នាឬអត់? តើពីរនាក់ហ្នឹងនិយាយគ្នារឿងអីថែមទៀត ដើម្បីតាមដានសញ្ញាន់លើសញ្ជាន់ រហូតដល់ចុងក្រោយស្នៀន អ៊ី ហ្នឹងទៅយកសម្លាប់។ សូមអស់ សូមចប់យោបល់។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទសូមអរគុណ។ លោកៗដឹងពីណាពីរឿងតាមដានក្រោយពេលរៀបការហ្នឹង? មានអ្នកណានិយាយប្រាប់លោក ឬមួយក៏លោកដឹងដោយរបៀបណា?

**ឆ៖** បាទ ការដែលដឹងនេះ បញ្ជាក់ជូនថាគឺពួកកងឈ្លបហ្នឹង ត្រូវតែតាមដានមុខសញ្ញាទាំងយប់ទាំងអធ្រាត្រ។ អធ្រាត្រក៏ឮស្នូរឆ្កែព្រុះមនុស្សដើរ ទៅតាមលបស្ដាប់គ្រប់ទីកន្លែងទាំងអស់ អត់មានលោះថ្ងៃណាពេលណាទេ។ ចំណុចហ្នឹងហើយដែលខ្ញុំបាទបានដឹង ពីព្រោះសូម្បីខ្លួនខ្ញុំបាទហ្នឹង ក៏ត្រូវពួកកងឈ្លបហ្នឹងតាមដានលួចស្ដាប់នៅពេលយប់ដែរ តើធ្វើសកម្មភាពអ្វី និយាយជាមួយអ្នកណា ឬក៏យំខ្សឹបខ្សួលអីតែម្នាក់ឯង ឬយ៉ាងណា។ ដូច្នេះស្ថិតក្នុងសភាពមួយដែលគេដាក់សម្ពាធខ្លាំងណាស់ មិនអាចនឹងបរិយាយឲ្យអស់បាន។ សូមចប់ សូមអស់យោបល់។

[០៩:៥៦:២៨]

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ពីមុនបន្តិចដែរថា អ្នកដែលធ្វើជាកងឈ្លបអីហ្នឹងជាកូនចៅអ្នកស្រុក ហើយអ្នកដែលជាមានវណ្ណៈអធននៅក្នុងមូលដ្ឋានហ្នឹង។ អ៊ីចឹងខ្ញុំចង់សួរលោកថា

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកស្គាល់ឈ្មោះកងឈ្លបដែលដើរតាមដានសកម្មភាពរបស់លោកហ្នឹងដែរទេ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបាទស្គាល់ពួកកងឈ្លបទាំងអស់នេះ ពីព្រោះឃើញដើរចាត់ចែងតាមភូមិឃុំហ្នឹង មានឈ្មោះ អ៊ុក តាំងហ៊ីន ហ្នឹងជាមេដែលខ្ញុំបានជម្រាបហើយ។ មានឈ្មោះ អាដាំហ្នឹង, មានឈ្មោះ អាម៉ុង ប៉ាង ហ្នឹង និងមានឈ្មោះ អាស្រួច, អាឈឿង ថែមទៀត។ គឺក្រៅពីពួកទាំងអស់ហ្នឹងដែលធ្លាប់ឃោរឃៅ និងតាមដានពួក១៧មេសាទៅហ្នឹងក៏គេតាមដាន ហើយព្រឹកឡើងស្រាប់តែហៅយកទៅអប់រំរៀនសូត្រ បាត់ខ្លួនរហូតបណ្ដោយ។ បាទ សូមចប់ សូមអស់យោបល់។

**ស៖** បាទ សូមអរគុណ។ កងឈ្លបដែលលោករៀបរាប់អម្បាញ់មិញហ្នឹង គឺជាអ្នកបានតាមដានពីឪពុករបស់លោករៀបការដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដហើយបាទ។ សូមអស់យោបល់។

**ស៖** បើអ៊ីចឹងមានន័យថា កងឈ្លបដែលលោករៀបរាប់ឈ្មោះអម្បាញ់មិញ អ្នកហ្នឹងគឺធ្វើការតាំងពីជំនាន់៧០ រហូតមកដល់៧៨ ឬក៏៧៩។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដហើយ កងឈ្លបហ្នឹងធ្វើការតាំងពី៧០មករហូត ៧៥ហើយក៏ធ្វើការអ៊ីចឹងទៀត រហូត៧៩ហើយបានបាត់ រត់បែកខ្ញែកគ្នា។ សូមចប់ សូមអស់យោបល់។

[០៩:៥៨:៥០]

**ស៖** បាទ លោកអាចបញ្ជាក់បានទេថា ក្នុងរចនាសម្ព័ន្ធដឹកនាំថ្នាក់ពីសហករណ៍ ឃុំ រហូតដល់ស្រុក ឬតំបន់ហ្នឹងមានការផ្លាស់ប្តូរពីត្រឹមថ្នាក់ណាដែរ? ព្រោះលោកបានបញ្ជាក់មុននេះអំមិញ នៅពេលដែលលោកឆ្លើយជាមួយនឹងលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ លោកបញ្ជាក់អំពីការផ្លាស់ប្តូររហូតដល់ទៅប្អូនដងក្នុងតំបន់ស្វយ័ត៥០៥នោះ។

**ឆ៖** បាទសូមអរគុណ។ ការផ្លាស់ប្តូរហ្នឹង គឺដឹងតាមរយៈគណៈសហករណ៍ គេមកបើកមិទ្ទីងប្រជាជន ផ្សព្វផ្សាយសភាពការណ៍រៀងរាល់ថ្ងៃទី១០ ថ្ងៃ២០ និងថ្ងៃ៣០។ គេបានផ្សាយថា "នៅភូមិភាគបូព៌ា ឈ្មោះ ឈូក, ឈ្មោះ ឌឿន, ឈ្មោះ ស្រេង, ឈ្មោះ ចក្រី នេះសុទ្ធតែពួកក្បត់។ ដូច្នេះបក្សមានការឈ្លាសវៃបានដកពួកហ្នឹងចេញ ហើយដាក់ពួកនិរតីចូលមកវិញ"។ នេះដែលខ្ញុំបាទបានចាំ។ សូមចប់ សូមអស់យោបល់។

**ស៖** បាទ អ៊ីចឹងខ្ញុំសូមបញ្ជាក់សាឡើងវិញ។ សហករណ៍ ប្រធានសហករណ៍ ឬក៏គណៈសហករណ៍ដែលលោកបានឃើញតាំងពីឆ្នាំ៧០ ឬក៏៧៥ រហូតមកហ្នឹងគឺមានការផ្លាស់ប្តូរទេ កាលសម័យ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹង?

**ឆ៖** បាទ សូមអរគុណ។ ហាក់ដូចជាពុំមានការផ្លាស់ប្ដូរទេ គឺតាំងពីដើមរៀងរាបដរាបមក គឺជាលំនាំទៅអ៊ីចឹងរហូតដល់ចុងក្រោយ។ សូមចប់ សូមអស់យោបល់។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងនឹងគណៈឃុំវិញ លោកមានស្គាល់នៅក្នុងឃុំរបស់លោក គណៈឃុំហ្នឹងមានការផ្លាស់ប្ដូរយ៉ាងម៉េចដែរទេ?

[១០:០១:០៥]

**ឆ៖** បាទ សូមអរគុណ។ ដូចជាគ្មានគណៈឃុំឯណាត្រូវទទួលការផ្លាស់ប្ដូរតំណែង តួនាទីភារកិច្ចអីទេ។ ឃើញតែគណៈសហករណ៍ និងគណៈសហគមន៍តែប៉ុណ្ណោះ ដែលមកគ្រប់គ្រងស្ដួរនាំប្រជាពលរដ្ឋ។ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងគណៈស្រុក លោកមានស្គាល់គណៈស្រុកជាបុគ្គល ឬមួយក៏តាមរយៈអង្គប្រជុំណាដែលលោកបានចូលរួមទេ?

**ឆ៖** បាទ ដែលតាមខ្ញុំបាទធ្លាប់ចូលរួម គឺនៅក្នុងឆ្នាំ១៩៧៣ ពេលដែលសង្គ្រាមអាកាស២០០ យប់ ២០០ថ្ងៃ ទម្លាក់គ្រាប់បែកហ្នឹង គឺឃើញមានឈ្មោះលោកសាស្ត្រាចារ្យ ទីវ អុល ទៅបើកសន្និបាតនៅនុ៎ងមួយពេល។ ហើយគាត់ហៅអតីតគ្រូបង្រៀនទាំងអស់មកចូលរួម ឲ្យឈ្មោះថា "មហាសន្និបាតបញ្ញវន្ត"។ គឺក្រៅពីហ្នឹងមក គឺខ្ញុំបាទមិនដែលបានទៅចូលរួមស្អីឯណាធំដុំទេ មានតែប្រជុំតាមសហ-ករណ៍ ជាមួយគណៈសហករណ៍តែប៉ុណ្ណោះ។ សូមចប់ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំទាក់ទងទៅនឹងគណៈស្រុក តើបើសិនជាលោកស្គាល់ ឬក៏មានទំនាក់ទំនងជាលក្ខណៈផ្ទាល់ខ្លួន ឬជាលក្ខណៈបុគ្គលលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ?

**ឆ៖** បាទ សូមអរគុណ។ តាមរយៈដែលឆ្លងកាត់ក្នុងរបប ប៉ុល ពត ហ្នឹងឃើញមានគណៈស្រុក ឈ្មោះ បឿន មួយដែលមានការលេចធ្លោ ហើយខ្ញុំចងចាំឈ្មោះហ្នឹងបានដល់បច្ចុប្បន្នជម្រាបជូនបានប៉ុណ្ណឹងុ។ សូមអរគុណ។

**ស៖** គាត់កាន់គណៈស្រុកក្នុងស្រុកក្រគររបស់លោកហ្នឹងរហូត ឬមួយក៏មានការផ្លាស់ប្ដូរដែរ?

**ឆ៖** បាទ សូមអរគុណ។ ការដែលគេបញ្ជូនគណៈស្រុកឈ្មោះ បឿន ទៅឲ្យគ្រប់គ្រងនៅសហករណ៍នៅក្នុងឱកាសនោះ ពេលនោះឆ្នាំនោះ គឺដូចអត់មានការផ្លាស់ប្ដូរឯណាទៀតទេ រហូតដល់

កងទ័ពរណសិរ្សវៀតណាមចូលហើយស្តីបែកតែម្តង។ សូមចប់ សូមអរគុណ។

[១០:០៤:០៥]

**ស៖** បាទ សូមអរគុណ។ ដោយសារតំបន់៥០៥ ជាតំបន់ស្វយ័តដែលលោកបានជម្រាបខាងដើម។ លោកចាំពីរចនាសម្ព័ន្ធនៅក្នុងថ្នាក់តំបន់នេះទេ ការផ្លាស់ប្តូរជាច្រើនដងដែលលោកបានមានប្រសាសន៍ហ្នឹង ថាតើវាមានទំនាក់ទំនង ឬជះឥទ្ធិពលអីដល់ថ្នាក់មូលដ្ឋាននៅពេលដែលមានការផ្លាស់ប្តូរម្តងៗហ្នឹង?

**ឆ៖** បាទ សូមអរគុណ។ ការដែលផ្លាស់ប្តូរគណៈស្រុកម្តងៗនោះ ឥទ្ធិពលនិងការទទួលមកវិញហ្នឹង ចុងក្រោយហ្នឹងគឺឈ្មោះសមមិត្ត ចែត ខ្ញុំដឹងច្បាស់ថាគាត់គឺជាគ្រូបង្រៀនផ្នែកហ្វីសិកគីមី ហើយគាត់មានសីលធម៌ជាមួយនឹងកម្មាភិបាលនារីហ្នឹង រាប់សិបនាក់ ទើបគេថាខាងគណៈតំបន់ហ្នឹងក្បត់នឹងអង្គការថ្នាក់លើ។ គេយកគាត់ហ្នឹងបាត់ទៅ ហើយផ្លាស់ប្តូរមកវិញ ភូមិភាគនិរតីដែលខ្ញុំបានជម្រាបជូនលោកពីខាងដើម។ ខ្ញុំបាទដឹងប៉ុណ្ណឹង។ អរគុណ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងឪពុកក្មេករបស់លោក ខ្ញុំចង់ដឹងថាតើឪពុកក្មេករបស់លោកស្លាប់ដោយមូលហេតុអីដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ សូមអរគុណ។ ដូចខ្ញុំជម្រាបជូនខាងដើមហើយ ថាឪពុកក្មេកខ្ញុំជាស្មៀនឃុំនៅឃុំក្រចេះ គឺជាមន្ត្រីកាលពីរបប សីហនុ, លន់ នល់។ ហ្នឹងទី១ ដែលគេកត់សម្គាល់។ ហើយទី២ជាប់ខ្សែកា.ហ្សេ.បេ ដោយគាត់មានប្រពន្ធជាវៀតណាមឈ្មោះ វៀង ធីបេ ហ្នឹង ដែលជាហេតុនាំឲ្យគេយកគាត់ទៅសម្លាប់ចោលហ្នឹង។ អរគុណ សូមចប់។

**ស៖** បាទ លោកចាំពីទីតាំង កន្លែងដែលយកទៅសម្លាប់ទេ ឬមួយក៏លោកដឹងពីការសម្លាប់នេះក្រោយមកទេ លោកអាចបញ្ជាក់បានទេ?

[១០:០៦:៤១]

**ឆ៖** បាទ សូមអរគុណ។ ទីតាំង និងការដែលពួកកងឈ្លបយកគាត់ទៅសម្លាប់ ខ្ញុំបានបញ្ជាក់រួចហើយ គឺនៅទំនប់ក្បាលទន្សោង ខាងកើតឃុំក្រគរ ស្រុកក្រចេះ ខេត្តក្រចេះ ប៉ុន្តែទីតាំងត្រង់ណាមួយគោលដៅច្បាស់លាស់ ខ្ញុំបាទមិនដឹងទេ។ អរគុណ សូមចប់។

**ស៖** លោកបានបញ្ជាក់ខាងដើមអំពីពេលវេលាដែលគាត់រៀបការ ហើយក្រោយមកក៏មានការតាមដានទៅលើគាត់ជាឪពុកក្មេករបស់លោកហ្នឹង។ លោកអាចបញ្ជាក់ពេលវេលានៃការស្លាប់ចុងក្រោយ

ពេលវេលាចុងក្រោយនៃការដែលឪពុកក្មេករបស់លោកត្រូវគេយកទៅសម្លាប់ហ្នឹងបានទេ?ដែលលោកដឹងជាចុងក្រោយនោះ លោកដឹងថាគាត់ត្រូវបានយកទៅសម្លាប់ ឬក៏លោកបាត់ខ្លួនហ្នឹងនៅពេលណា?

**ឆ៖** បាទ សូមអរគុណ។ ពេលវេលានៃការរៀបការ និងពេលវេលាស្លាប់ចុងក្រោយរបស់ឪពុកក្មេកខ្ញុំបាទ ឈ្មោះស្មៀនអ៊ី ហ្នឹងគឺនៅក្នុងឆ្នាំ១៩៧៨ ឆ្នាំ១៩៧៨ គឺដាក់សម្ពាធយ៉ាងប្រញាប់ប្រញាល់ជាទីបំផុតដើម្បីរៀបការឲ្យទាន់ រៀបការឲ្យទាន់។ ដល់៧៨ហ្នឹងមានការបង្កើតនូវរណសិរ្ស ២ធ្នូ នៅឃុំជើងឃ្លូ ស្រុកស្នួល ខេត្តក្រចេះហើយ គឺសូរសំឡេងកាំភ្លើងធំរបស់កងទ័ពវៀតចូលហើយ។ ដូច្នេះគឺជានាទីចុងក្រោយហើយ ដែលពួកកងឈ្លបយកគាត់ទៅសម្លាប់ចោលនៅទំនប់ក្បាលទន្សោងដូចបានជម្រាបជូនខាងដើមទាន។ បាទ សូមចប់ សូមអស់យោបល់។

**លោក គង់ សំអុន៖**

បាទ លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណ។

[១០:០៨:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ហើយជាចុងក្រោយនេះ លោក អ៊ុច ស៊ុនឡាយ លោកអាចថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មចុងក្រោយបញ្ចប់ និងអាចមានសំណួរ បើសិនជាលោកមានបំណងតាំងសំណួរចំពោះជនជាប់ចោទ ធ្វើតាមរយៈយើងជាប្រធានអង្គជំនុំជម្រះនោះ គឺលោកអាចធ្វើបាន។ សូមអញ្ជើញបាទ!

**លោក អ៊ុច ស៊ុនឡាយ៖**

ខ្ញុំបាទ សូមគោរពលោកប្រធានអង្គជំនុំជម្រះ។ ខ្ញុំបាទសូមមានសំណួរពីរ តាមរយៈលោកប្រធានអង្គជំនុំជម្រះ ដើម្បីសួរទៅជនជាប់ចោទទាំងពីររូបដែលស្ថិតនៅក្នុងសាលសវនាការក្តី នៅខាងក្រៅក្តីក៏ដោយ សួរថាតើហេតុអ្វីបានជាគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យនេះ យកទាំងកូនក្មេងដែលមិនដឹងអី គ្មានទោសសោះនេះ យកទៅសម្លាប់ចោលយ៉ាងដូច្នេះនេះ? នេះគឺជាសំណួរទី១។

សំណួរទី២ តើហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យនេះ យកអ្នកកាន់ព្រះពុទ្ធសាសនាដូចលោកឪពុកខ្ញុំជាអាចារ្យវត្ត ចោទប្រកាន់ថាជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដោយប្រការណាមួយអ៊ីចឹង? តើអស់លោកហ្នឹងចង់ក្លាយទៅជាអាទិទេពនៅលើផែនដីនេះ ឬក៏ក្លាយជាសម្បុញ្ញពុទ្ធ ដោយគាត់គ្រាន់តែដុតធូប អត់មានធូបផង គឺមានតែដើមព្រិចដែលងាប់ៗហ្នឹង ដុត ហើយគាត់ថ្វាយបង្គំរំឭកព្រះពុទ្ធ ព្រះ

ធម៌ ព្រះសង្ឃ ត្រៃសរណគមន៍ទាំងបីតែប៉ុណ្ណោះ។ ខ្ញុំបាទមានសំណួរទាំងពីរហ្នឹង សូមឲ្យឆ្លើយប្រាប់មតិជាតិ និងអន្តរជាតិឲ្យឃើញច្បាស់។ នេះគឺជាសំឡេងចុងក្រោយរបស់ខ្ញុំបាទដែលនៅរស់ ដើម្បីប្តឹងទៅអន្តរជាតិ ក៏ដូចជាផ្សាយទូទៅពេញសកលលោក ថារបបឃោរឃៅព្រៃផ្សៃ ប្រល័យពូជសាសន៍អន្សុតិវិរ្គិយនេះ ដែលកើតមាននៅកម្ពុជា គឺពួកមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបនេះ ដែលត្រូវទទួលបន្ទុក។

ខ្ញុំបាទតែប៉ុណ្ណឹងទេបាទ។ សូមលោកប្រធាននៃអង្គចៅក្រមមេត្តាសួរក្រុមអស់នេះ ឲ្យបានឆ្លើយនូវចុងក្រោយ។ សូមចប់។

[១០:១១:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបលោក អ៊ុច ស៊ុនឡាយ ថាតាមបទប្បញ្ញត្តិនៃវិធាន២១ អនុវិធាន១ ចំណុច(ឃ)បានចែងថា នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា៖ “នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះត្រូវប្រាប់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរដល់ជនជាប់ចោទ។”

ហើយនៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់ជនជាប់ចោទទាំងពីរនាក់ ឆ្លើយបញ្ជាក់ពីការដែលខ្លួនគាត់សុំរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរ។ ហើយអង្គជំនុំជម្រះ ក៏បានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់នៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលព័ត៌មានជាក់លាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬក៏ពីសហមេធាវីការពារក្តីជនជាប់ចោទ។

ហើយនៅក្នុងសវនាការនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និងសហមេធាវីការពារក្តីជនជាប់ចោទ ត្រូវមានការទទួលខុសត្រូវក្នុងការជូនដំណឹងមកអង្គជំនុំជម្រះ ឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធិភាព ប្រសិនបើជនជាប់ចោទ បានសម្រេចចិត្តលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ ឬរបស់ភាគីពាក់ព័ន្ធ នៅក្នុងដំណាក់កាលណាមួយនៃកិច្ចដំណើរការសវនាការរឿងក្តីនេះ។

[១០:១២:៣៧]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងអំពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការយល់ព្រមឆ្លើយតបនឹងសំណួរឡើយ។ ហើយតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ទាំងច្បាប់ព្រហ្មទណ្ឌជាតិ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺអង្គជំនុំជម្រះមិនអាចមានសិទ្ធិក្នុងការបង្ខិតបង្ខំឱ្យជនជាប់ចោទឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ ឬក៏ភាគីបានឡើយ។ សូមលោកជ្រាប។

ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក អ៊ុច ស៊ុនឡាយ។ សវនាការស្តាប់សក្ខីកម្ម និងសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដែលលោកអះអាងថា បានទទួលរងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ បានដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្ម និងសេចក្តីថ្លែងរាប់របស់លោកនេះ នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលមាន ដែលលោកមានបំណងចង់ទៅបានហើយ។ ហើយសូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក ប៊ុន លឹមហួរ បុគ្គលិកអង្គការធី.ភី.អូហើយសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនា ស្ថានភាពព្យសនកម្មសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងអង្គហេតុ ការប្រព្រឹត្តទៅលើក្រុមមនុស្សគោលដៅជាក់លាក់ចំពោះជនជាតិចាម ចំពោះជនជាតិវៀតណាម និងចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បានដល់ទីបញ្ចប់ហើយ។ លោកអាចសម្រាកបានហើយ។

[១០:១៩:១០]

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនលោក អ៊ុច ស៊ុនឡាយ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅ បានហើយ។

ហើយអង្គជំនុំជម្រះ សូមបញ្ជាក់ថា នៅក្រោយពេលសម្រាកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-933 ពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខអូរកន្សែង សូមភាគីជ្រាប។ ពេលឥឡូវនេះក៏ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣២:៥៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-933 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក ផន ថុល៖**

**ផ៖** បាទ លោកប្រធាន ខ្ញុំឈ្មោះ ផន ថុល។

**ស៖** អរគុណលោក ផន ថុល។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ផ៖** ខ្ញុំកើតនៅថ្ងៃទី១៦ ខែ៦ ឆ្នាំ១៩៥០។

**ស៖** ទីកន្លែងកំណើតរបស់លោកនៅឯណា?

**ផ៖** ទីកំណើតរបស់ខ្ញុំនៅឃុំល្វើន ស្រុកស្វាយរៀង ខេត្តស្វាយរៀង។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃលោករស់នៅទីកន្លែងណា?

**ផ៖** ទីលំនៅសព្វថ្ងៃនៅភូមិ៧មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។

**ស៖** លោកប្រកបមុខរបរអីដែរសព្វថ្ងៃនេះ?

[១០:៣៦:០៦]

**ឆ៖** បាទ ខ្ញុំសព្វថ្ងៃជាសមាជិកក្រុមប្រឹក្សាស្រុក។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ម៉ី ផន។ ម្ដាយឈ្មោះ កែវ ស៊ុម។

**ស៖** ចុះភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ លោកប្រធាន ប្រពន្ធខ្ញុំឈ្មោះ ចាន់ធូ។ មានកូនប្រាំ ស្លាប់អស់ពីរ នៅសល់បី។

**ស៖** លោក ផន ថុល តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោក ខៀវ សំផន និងបុគ្គលទាំងឡាយបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ ថាតើលោករបាយការណ៍នេះពិតត្រឹមត្រូវអ៊ីចឹងមែនដែរទេ?

**ឆ៖** បាទ ពិតលោកប្រធាន។

**ស៖** ហើយលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែក ដែលនៅពីខាងកើតសាលសវនាការនេះហើយនៅ មុននឹងលោកចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** បាទ បានស្បថរួចហើយលោកប្រធាន។

[១០:៣៧:២៩]

**ស៖** បាទ អរគុណ។ ហើយតទៅនេះយើងប្រាប់អំពីសិទ្ធិ និង ករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិលោក ផន ថុល ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើការអត្ថាធិប្បាយដែលនាំឲ្យចម្លើយ ឬក៏សេចក្ដីអត្ថាធិប្បាយរបស់លោកនោះ នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ចក្នុងឋានៈជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយរបស់លោកហ្នឹងនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេត

ដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬថៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក ផន ថុល តើលោកធ្លាប់ផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង ធ្វើនៅទីកន្លែងណា លោកចាំដែរទេ?

**ឆ៖** បាទ លើកទី១ ធ្វើនៅកន្លែងសាលាកែប្រែរបស់ខ្មែរក្រហម គឺកន្លែងគុក។ យើងនិយាយដោយខ្លី។ ហើយទី២ គឺធ្វើនៅផ្ទះខ្ញុំតែម្តង។

[១០:៣៩:១៩]

**ស៖** ហើយលោកចាំទេ កាលធ្វើហ្នឹង ទាំងពីរលើកហ្នឹងនៅពេលណាដែរ?

**ឆ៖** បាទ អត់បានចាំថ្ងៃទេ លោកប្រធាន ព្រោះវាយូរពេកហើយ ឯកសារហ្នឹងក៏ខ្ញុំអត់បានតម្កល់ដែរ វាយូរពេក។

**ស៖** មិនអីទេ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មចំនួនពីរលើក កាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ បានពិនិត្យរួចហើយលោកប្រធាន។

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបាន តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុដែលស្តាប់ចម្លើយ ដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងកិច្ចសម្ភាសន៍ដែលលោកបានផ្តល់ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលលើកមុនហ្នឹង ដែលលោកថាធ្វើនៅមន្ទីរអប់រំកែប្រែ និងធ្វើនៅផ្ទះរបស់លោកនុ៎ង វាសមស្របស៊ីសង្វាក់គ្នាដែរឬទេ?

**ឆ៖** បាទ សមស្របលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយនៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងអ.វ.ក.ត អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា សួរដេញដោលសាក្សីនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសហព្រះរាជអាជ្ញារួមទាំងសហមេធាវីមុខតំណាង

ដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការ ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១០:៤១:០៧]

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ភាគីទាំងអស់។ <សូមជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ផន ថុល។>

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ខ្ញុំសូមសួរអំពីការងារលោកនៅចម្ការកៅស៊ូ ដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេត។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាលោកចាប់ផ្តើមធ្វើការនៅចម្ការកៅស៊ូពីពេលណាមកដែរ?

**លោក ផន ថុល៖**

**ផ៖** បាទ ខ្ញុំធ្វើកម្មករចម្ការកៅស៊ូនៅតាំងពីឆ្នាំ១៩៦២។

**ស៖** ហើយតើលោកអាចប្រាប់បានទេ ថាចម្ការកៅស៊ូហ្នឹង<ឈ្មោះអី ហើយ>ស្ថិតនៅទីកន្លែងណាដែរ?

**ផ៖** បាទ ចម្ការកៅស៊ូនេះស្ថិតនៅក្នុងទឹកដីនៃខេត្តរតនគិរី។

**ស៖** លោកបាននិយាយថា លោកចាប់ផ្តើមធ្វើការនៅទីនោះតាំងពីឆ្នាំ១៩៦២ តើក្រោយថ្ងៃ១៧ មេសា ៧៥ <នៅពេលដែលខ្មែរក្រហមកាន់កាប់ភ្នំពេញ> លោកនៅតែបន្តធ្វើការនៅចម្ការកៅស៊ូនោះដដែលដែរ ឬក៏អត់ទេ?

[១០:៤២:៣៣]

**ផ៖** បាទ ក្រោយ១៧ មេសា ឆ្នាំ១៩៧៥ ចម្ការកៅស៊ូត្រូវបានរំលាយ អត់មានកម្មករធ្វើទៀតទេ។

**ស៖** ខ្ញុំចង់សួរលោកពាក់ព័ន្ធទៅនឹងឯកសារ E3/5172 ដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ERN អង់គ្លេស 00272585, ខ្មែរ 00189251, បារាំង 00272592។ ហើយលោកឆ្លើយនៅត្រង់ នៅលើទំព័រនេះថា៖ “ពីឆ្នាំ៧៥ដល់៧៦ ខ្ញុំក៏បានធ្វើការជាកម្មករចម្ការកៅស៊ូម្តងទៀត <ក្រោម

ការគ្រប់គ្រងរបស់>ខ្មែរក្រហម។" តើត្រឹមត្រូវទេ ដែលថាលោកបានបន្តធ្វើការ<>នៅចម្ការកៅស៊ូហ្នឹង<ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម> ពីឆ្នាំ៧៥ ដល់៧៦?

**ឆ៖** បាទ ត្រឹមត្រូវ។ នៅក្នុងចុងឆ្នាំ១៩៧៥នេះ គឺគេបង្កើតសហជីពដើម្បីប្រមូលកម្មករចាក់ជ័រម្ដងទៀត រហូតមកដល់ឆ្នាំ៧៦ ឆ្នាំ៧៥ ឆ្នាំ៧៦។

**ស៖** នៅក្នុងអំឡុងពេលនោះ គឺនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម តើអ្នកណាជាអ្នកត្រួតត្រា គ្រប់គ្រងចម្ការកៅស៊ូ<ដែលលោកធ្វើការ>នោះ?

**ឆ៖** បាទ អ្នកគ្រប់គ្រងចម្ការកៅស៊ូនោះ គ្រាន់តែខ្ញុំដឹងថា គាត់នោះឈ្មោះ ទុំ ជាប្រធានសហជីពដែលគ្រប់គ្រងចម្ការកៅស៊ូ។

**ស៖** លោកទើបតែនិយាយថាគាត់ជាប្រធានសហជីពចម្ការកៅស៊ូ។ ចុះលោកមានបានដឹងថាគាត់មានតួនាទីអ្វីផ្សេងទៀតក្រៅពីនេះទេ?

[១០:៤៤:៥៦]

**ឆ៖** បាទខ្ញុំអត់បានដឹងថា គាត់មានតួនាទីអីផ្សេងទៀតទេ គ្រាន់តែបានឃើញគាត់ដើរគ្រប់គ្រងកម្មករចម្ការកៅស៊ូគ្រប់សហជីពនៅក្នុងរង្វង់សហជីពដែលគាត់ក្ដោបក្ដាប់។

**ស៖** ខ្ញុំសូមសួរពាក់ព័ន្ធទៅនឹងចម្លើយលោកឆ្លើយជូនមន្ត្រីស៊ើបអង្កេតម្ដងទៀត គឺនៅត្រង់ទំព័រដដែល ដែលខ្ញុំទើបលើកដកស្រង់អម្បាញ់មិញ។ អ្វីដែលលោកឆ្លើយនោះគឺថា សូមដកស្រង់៖ "ចម្ការកៅស៊ូនេះគឺគ្រប់គ្រងដោយឈ្មោះ ទុំ ដែលជា<សមាជិក>គណៈ<ភូមិភាគ ដែលជាប្រធានសហជីពចម្ការកៅស៊ូ>។" តើចំណុចនេះជួយរំឭកដល់ការចងចាំរបស់លោកដែរទេ ដែលថា ទុំ ហ្នឹងក៏ជាសមាជិកគណៈ<ភូមិភាគ>នោះដែរ?

**ឆ៖** បាទ ខ្ញុំមិនដឹងថា គាត់ធ្វើអ្វីទេ ប៉ុន្តែពេលដែលខ្ញុំធ្វើជាកម្មករនៅក្នុងសហជីពហ្នឹង គឺខ្ញុំឃើញតែគាត់ ដែលសម្រាប់ហៅចែកអង្ករ ឬសម្លៀកបំពាក់ឲ្យកម្មករចម្ការកៅស៊ូតែប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ត្រង់នេះបន្តិច។ នៅក្នុងឆ្នាំ១៩៧៦ តើគាត់មានតួនាទីអ្វីនៅក្នុងកងពល៨០១ ឬក៏ក្នុងជួរកងទ័ព<ដទៃទៀត>ដែរទេ?

**ឆ៖** បាទ ត្រង់ចំណុចនេះ ខ្ញុំអត់បានដឹងទេ។ គាត់មិនដឹងធ្វើអីទៀតទេ ខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលប្រធានបទថ្មី ខ្ញុំសួរអំពីការរៀបការរបស់លោកនៅពេលនោះ។ តើលោកអាចជម្រាបជូនតុលាការបានទេថា លោករៀបការនៅពេលណាដែរ ពេលដែលលោកធ្វើការ

នៅចម្ការកៅស៊ូនោះ?

**ឆ៖** បាទ សូមជម្រាបថា ខ្ញុំមិនមែនរៀបការនៅក្នុងចម្ការកៅស៊ូទេ គឺខ្ញុំរៀបការនៅក្នុង ហៅថា កសិករនៅក្នុងឃុំត្រពាំងច្រេស ក្នុងឆ្នាំ១៩៧២។

[១០:៤៧:២៦]

**ស៖** ប៉ុន្តែត្រឹមត្រូវដែរទេ ដែលថា<លោកនៅរួមរស់ជាមួយប្រពន្ធដដែល>ពេលដែលលោកមកធ្វើការនៅចម្ការកៅស៊ូ<>ពីឆ្នាំ៧៥ ដល់៧៦<? តើ>លោក<នៅតែរួមរស់ជាមួយប្រពន្ធដដែលនៅពេលនោះ?> ត្រឹមត្រូវដែរឬក៏អត់ទេ?

**ឆ៖** បាទ អត់មានរៀបការម្តងទៀតទេ។ គឺរៀបតែម្តងគត់ គឺនៅឃុំត្រពាំងច្រេស ស្រុកលំផាត់ ខេត្តរតនគិរី គឺនៅឆ្នាំ១៩៧២។

**ស៖** ប្រហែលជាខ្ញុំសួរសំណួរមិនបានត្រឹមត្រូវ។ ខ្ញុំមិននិយាយពីពិធីរៀបការទេ សំណួរអ៊ីចេះទេ ថាមកដល់ឆ្នាំ១៩៧៥ទៅដល់៧៦ លោកនៅតែមានប្រពន្ធដដែលហ្នឹង ហើយមកធ្វើការនៅចម្ការកៅស៊ូជាមួយលោកដែរ ឬក៏យ៉ាងណា?

**ឆ៖** បាទ ពេលដែលមកធ្វើចម្ការកៅស៊ូ គឺនៅតែប្រពន្ធខ្ញុំដដែលដែលខ្ញុំរៀបការលើកទី១ហ្នឹង។

**ស៖** ហើយប្រពន្ធរបស់លោកឈ្មោះអីដែរ?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ មឿង ចាន់ឌី។

**ស៖** ចុះលោកមានកូនដែរទេ នៅពេលដែលលោកធ្វើការនៅចម្ការកៅស៊ូ? ហើយនៅពេលហ្នឹងតើប្រពន្ធរបស់លោកមានពពោះអីដែរទេ?

**ឆ៖** បាទ នៅពេលដែលធ្វើការនៅចម្ការកៅស៊ូ យើងខ្ញុំអត់ទាន់មានកូនទេ ប៉ុន្តែដល់ចុងឆ្នាំ៧៦ ខ្ញុំបាទមានកូនមួយ ហើយកូននោះក៏ស្លាប់នៅមន្ទីរព្យាបាល។

**ស៖** សព្វថ្ងៃនេះលោកនៅតែ -- ប្រពន្ធរបស់លោក មឿង ចាន់ឌី នៅតែរួមរស់ជាមួយលោកសព្វថ្ងៃហ្នឹងដែរ ឬក៏យ៉ាងណា?

[១០:៤៩:៤៥]

**ឆ៖** បាទ សូមជម្រាបថា ក្រោយពេលរំដោះយើងទាំងពីរក៏ហៅថា បែកបាក់គ្នា ហើយខ្ញុំក៏យកប្រពន្ធថ្មីមួយទៀត ដែលឈ្មោះ ចាន់ធូ។

**ស៖** ហើយតើនៅពេលណាដែលលោកបែកគ្នាជាចុងក្រោយជាមួយ មឿង ចាន់ឌី?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** នៅក្នុងឆ្នាំ១៩៨៦។

**ស៖** ឥឡូវនេះខ្ញុំសុំចូលទៅនិយាយអំពីការចាប់ខ្លួនលោក ហើយគេបញ្ជូនលោកទៅមន្ទីរសន្តិសុខអូរកន្សែង។ សុំលោកជួយរៀបរាប់លម្អិតបន្តិចមក អំពីដំណើរការចាប់ខ្លួនរហូតដល់ពេលបញ្ជូនលោកទៅអូរកន្សែង។

**ឆ៖** នៅថ្ងៃទី១៦ ខែ៦ ឆ្នាំ១៩៧៧ វេលាម៉ោងប្រាំពីរព្រឹក ពេលដែលខ្ញុំចេញទៅធ្វើការនៅក្នុងចម្ការកៅស៊ូ ព្យាបាលកៅស៊ូ ប្រធានសហជីពបានទៅហៅខ្ញុំដល់កន្លែងការដ្ឋាន ដើម្បីប្រាប់ ហើយក៏ប្រាប់ខ្ញុំថា ឲ្យខ្ញុំនេះរៀបចំអីវ៉ាន់ដើម្បីទៅរៀនសូត្រនៅកន្លែងកែប្រែ នៅរៀនសូត្រនៅកន្លែងអង្គការ។ ហើយក្នុងនោះគឺប្រាប់ទាំងប្រពន្ធទៀត។ ដូច្នេះខ្ញុំក៏រៀបចំសម្ភារៈដែលមានជាសម្លៀកបំពាក់ ហើយមុងភួយ ឡើងឡានតែម្តងទៅ ប៉ុន្តែមិនដឹងគេយកទៅណា ទៅខាងណាៗ ក៏ខ្ញុំមិនដឹងដែរ ព្រោះអង្គការគេថាឲ្យខ្ញុំទៅកន្លែងរៀនសូត្រ តែប៉ុណ្ណឹងឯង។

[១០:៥១:៣៤]

**ប្រធានអង្គជំនុំ៖**

លោកៗ ផន ចុល លោកសុំជួយនិយាយឲ្យយឺតជាងនេះបន្តិច ព្រោះវាឆ្លងកាត់ការបកប្រែជាទៅជាភាសាបារាំង និងអង់គ្លេស វាអាចមានបញ្ហា អ្នកបកប្រែហ្នឹងគឺបកវាអត់ពេញលេញ។ ជួយៗអាចបន្ធូរបន្តិច ឲ្យវាយឺតជាងនេះបន្តិច ប្រហែលជាល្អ។ លោកនិយាយច្បាស់លាស់ណាស់ ប៉ុន្តែវាងយឺត -- វាងលឿនបន្តិច។ អរគុណ បាទ បន្តទៀតចុះ!

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកបាននិយាយថា ប្រធានសហជីពហ្នឹងហៅលោក។ <តើប្រធានសហជីពឈ្មោះ ទុំ ដែលលោកនិយាយមុននេះឬ?> ទុំ ហ្នឹងឬដែលហៅលោកថា លោកហ្នឹងត្រូវទៅចូលកន្លែងរៀនសូត្រអប់រំនុ៎ង?

**លោក ផន ចុល៖**

**ឆ៖** បាទមិនមែនទេ។ ក្នុងភូមិមួយមានប្រធានភូមិមួយ ក្នុងភូមិមួយមានប្រធានភូមិមួយ។ អ៊ីចឹង ទុំ នេះវាជាអ្នកគ្រប់គ្រងភូមិទាំងអស់នៅក្នុងចម្ការកៅស៊ូ ដែលយើងនិយាយថាសហជីព។

**ស៖** ហើយលោកក៏ទើបតែបាននិយាយថា ពេលចាប់លោកហ្នឹង គឺនៅថ្ងៃទី១៦ ខែមិថុនា <ឆ្នាំ១៩៧៧>។ តើលោកអាចជម្រាបជូនតុលាការបានទេថា ធ្វើម៉េចបានជាលោកចាំថ្ងៃខែឆ្នាំហ្នឹងបាន

ច្បាស់លាស់ម្ល៉េះ?

**ឆ៖** ពេលដែលគេចាប់ខ្ញុំ គឺនិយាយរួមថា ខ្ញុំមើលជំងឺព្យាបាល គឺខ្ញុំកំណត់ថ្ងៃច្បាស់ ហើយខ្ញុំដឹងច្បាស់ថា ពេលដែលគេហៅខ្ញុំឡើងឡាន គឺនៅថ្ងៃ១៦ ខែ៦ ឆ្នាំ១៩៧៧ នៅវេលាម៉ោងប្រាំពីរព្រឹក គឺខ្ញុំកំណត់ក្នុងចិត្តខ្ញុំច្បាស់រហូតដល់ថ្ងៃនេះ។

[១០:៥៣:៤១]

**ស៖** ចុះលោកដឹងទេ អ្នកណាបញ្ជាឲ្យគេចាប់ខ្លួនលោក ហើយបញ្ជូនលោកទៅមន្ទីរសន្តិសុខអប់រំកែប្រែអូរកន្សែងនុ៎ង?

**ឆ៖** បាទ សូមជម្រាបថា ពេលនោះគេមិនដែលប្រាប់យើងថា អ្នកនេះឲ្យយកទៅ អ្នកនោះឲ្យយកទៅ គេមិនដែលប្រាប់ទេ។ ពាក្យមួយមាត់ដែលគេតែងតែប្រើនៅក្នុងសម័យនោះ គេហៅថា "អង្គការឲ្យយើងទៅរៀន" តែប៉ុណ្ណឹង។

**ស៖** ចុះនៅពេលនោះ លោកមានបានដឹងថា មូលហេតុអីបានជាគេចាប់ខ្លួនលោក ឬក៏មានដឹងថា គេចោទប្រកាន់លោកពីបទល្មើសអីដែរទេ?

**ឆ៖** សូមជម្រាបជូនថា ពេលដែលចាប់ខ្ញុំទៅនោះ ខ្ញុំអត់បានដឹងថា ខ្ញុំមានកំហុសអីទេ ទាល់តែខ្ញុំចូលទៅដល់កន្លែងគុករបស់ ប៉ុល ពត បានគេសួរចម្លើយ បានគេប្រាប់ខ្ញុំថា មកពីសមមិត្តខុសរឿងនេះ បានគេចាប់សមមិត្តមក។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ ថាលោកធ្វើខុសហ្នឹង ខុសអី?

**ឆ៖** បាទ សូមជម្រាបថា ពេលដែលចាប់គឺខ្ញុំអត់បានដឹងទេ ប៉ុន្តែដល់គេយកខ្ញុំទៅសួរចម្លើយ ហើយក៏គេសួរខ្ញុំថា តើសមមិត្តដឹងគេចាប់សមមិត្តមកដល់សាលាកែប្រែពីទោសកំហុសអ្វីទេ? ខ្ញុំក៏ឆ្លើយចំពោះមុខអ្នកសួរចម្លើយថា ខ្ញុំអត់បានដឹងអ្វីទាំងអស់ ហើយខ្ញុំក៏មិនបានធ្វើអ្វីខុសចំពោះមុខបក្សដែរ។ ហើយដល់តែសួរ ហើយសួរមក សួរចុះសួរឡើងទៅ បានអ្នកសួរចម្លើយហ្នឹងប្រាប់ខ្ញុំវិញថា មូលហេតុដែលសមមិត្តគេចាប់មកនេះ មកសាលាកែប្រែនេះ គឺគេចោទថាសមមិត្តជា ថាពួកវណ្ណៈថ្នាក់លើ ហើយប្រើបច្ចេកទេសការ -- បច្ចេកទេសព្យាបាលចម្ការកៅស៊ូ បច្ចេកទេសព្យាបាលជំងឺកៅស៊ូនេះគឺជាបច្ចេកទេសរបស់សក្តិភូមិ គេហៅ "បច្ចេកទេសជិះយន្តហោះ"។ អ៊ីចឹងវណ្ណៈកសិករគេអត់ត្រូវការពពួកហ្នឹងទេ មកបម្រើឲ្យចម្ការកៅស៊ូ។

[១០:៥៦:១៨]

**ស៖** លោកទើបតែនិយាយថា គឺការប្រើប្រាស់ "បច្ចេកទេសដោយប្រើយន្តហោះ" <និង "បច្ចេកទេសនៃវណ្ណៈសក្តិភូមិ">។ អ៊ីចឹងសូមលោករៀបរាប់បន្តិចមើល <របៀបដែលលោកព្យាបាលជំងឺដើមកៅស៊ូ ដែល>ថាកំហុសហ្នឹងកំហុសបែបម៉េច <នៅក្នុងការយល់ឃើញរបស់>អង្គការ<ដែលគេប្រាប់លោកនៅទីនោះ>?

**ឆ៖** បាទ សូមជម្រាបថា គេមិនមែនថាខ្ញុំប្រើយន្តហោះទេ ប៉ុន្តែអង្គការហ្នឹងចោទខ្ញុំថា ពួកខ្ញុំនេះប្រើបច្ចេកទេសសក្តិភូមិ។ អាហ្នឹងគេហៅថាពួកបច្ចេកទេសជាន់ខ្ពស់ បច្ចេកទេសជិះយន្តហោះ អាហ្នឹងបានគេប្រើរបៀបហ្នឹង។ បើបច្ចេកទេសវណ្ណៈកសិករ គេមិនប្រើរបៀបហ្នឹងទេ។ អាហ្នឹងខ្ញុំសូមជម្រាបលោកអ៊ីចឹង។ ហើយគេសួរថាតើសមមិត្តនិយាយមើល ថាបច្ចេកទេសអាដែលគេចោទសមមិត្តថាបច្ចេកទេសសក្តិភូមិហ្នឹង តើវាធ្វើរបៀបយ៉ាងម៉េច? ហើយខ្ញុំក៏បានប្រាប់ដែលអ្វីដែលខ្ញុំចេះ ដែលខ្ញុំរៀន។ ខ្ញុំថាកៅស៊ូ កាលណាវាកើតជំងឺក្លូរទីស្យូម គេយកខ្លាញ់គោ ឬអង់ទីមូស៊ីន ដែលមានមកពីបរទេសយកទៅជ្រលក់បៀកដើម្បីកុំឲ្យវាឆ្លងជំងឺគ្នា។ អ៊ីចឹងដល់ខ្ញុំនិយាយអាបច្ចេកទេសដែលខ្ញុំធ្លាប់រៀនជាមួយរបស់បារាំងមក គេថាខ្ញុំហ្នឹងវាបច្ចេកទេសជិះយន្តហោះ ពពួកសក្តិភូមិជាន់ខ្ពស់។ អ៊ីចឹងហើយបានគេថាគេអត់ត្រូវការទេពពួកហ្នឹង បានគេឲ្យខ្ញុំមករៀនដើម្បីកុំឲ្យមានបញ្ហាហ្នឹងកើតឡើងចំពោះប្រជាជនទៀត។

**ស៖** ចុះ<នៅថ្ងៃនោះ> តើគេមានចាប់មនុស្សណាដទៃទៀតជាមួយនឹងលោកដែរទេ នៅពេលដែលគេចាប់ខ្លួនលោកនោះ?

[១០:៥៨:១២]

**ឆ៖** ថ្ងៃតែមួយ ពេលតែមួយហើយឡានតែមួយ ចំនួន ខ្ញុំក៏មិនបានចាំចំនួនដល់ថ្ងៃនេះដែរ ព្រោះវាយូរហើយ។ ប្រហែលជាជាង១០នាក់នៅក្នុងឡានអាហ្គាសរបស់ចិនហ្នឹង យកទៅទម្លាក់នៅកន្លែងបឹងកន្សែងហ្នឹង។

**ស៖** ហើយតើអ្នកដែលគេចាប់ខ្លួនបញ្ជូន<>ទៅជាមួយនឹងលោកហ្នឹង <>ធ្វើការអ្វីដែរ មកពីណាដែរ? លោកមិនចាំបាច់រៀបរាប់ឈ្មោះទេ ច្រើនអ៊ីចឹងគឺថាគ្រាន់តែថាមកពីណា ហើយធ្វើការអ្វីដែរ?

**ឆ៖** បាទ និយាយរួម សុទ្ធតែកម្មករសហជីព។

**ស៖** ហើយនៅថ្ងៃដែលគេចាប់ខ្លួនលោក នៅពេលហ្នឹង<តើលោកជាយោធា?> តើលោកជាសមាជិកកងទ័ពកងពល៨០១ ឬក៏លោកជាសមាជិកនៃអង្គភាពកងទ័ពណាមួយដែរ?

**ឆ៖** បាទ ខ្ញុំជាកម្មករសហជីព។

**ស៖** តើមានអ្វីកើតឡើងទៅដល់ប្រពន្ធរបស់លោក មឿង ចាន់ឌី ដែរឬទេ នៅពេលដែលគេចាប់ខ្លួនលោក?

**ឆ៖** បាទ អត់មានអ្វីកើតឡើងទេ ក្រោយពេលដែលចុះពីឡាននេះ គេគ្រាន់តែប្រាប់យើងថា ធ្វើដំណើរឲ្យត្រង់ កុំងាក ហើយកុំចូលព្រៃ ប្រយ័ត្នគេបាញ់សម្លាប់។ រហូតដល់កន្លែងដែល ផ្ទះដែលគេឃុំឃាំង។ ពេលដែលទៅដល់ គឺខាងស្រីគេដាក់ដោយឡែក ខាងបុរសគេដាក់ដោយឡែក។

[១០:៥៩:៥៩]

**ស៖** តើប្រពន្ធរបស់លោក ក៏ត្រូវបានគេចាប់ខ្លួនជាមួយនឹងលោកដែរឬអត់ទេ?

**ឆ៖** បាទ ពេលតែមួយ ថ្ងៃតែមួយ។

**ស៖** នៅក្នុងចម្លើយរបស់លោកគឺ E3/5172 <ដែលឆ្លើយជូនសហចៅក្រមស៊ើបអង្កេត>នៅភាសាអង់គ្លេសមានលេខ 00272586, ខ្មែរមានលេខ 00189252ដល់53 ហើយបារាំងមានលេខ 00272593។ លោកបាននិយាយថា ប្រពន្ធរបស់លោកមានផ្ទៃពោះនៅពេលគេចាប់ខ្លួន<គាត់> ហើយកូនស្រីរបស់លោកកើតនៅក្នុងគុក មុនឆ្នាំ៧៩។ តើចម្លើយនេះជាចម្លើយត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពេលដែលចាប់ទៅហ្នឹង គឺពោះហ្នឹងមិនទាន់ធំទេ ប្រមាណជាមួយខែទៅពីរខែទេ។ រហូតទៅដល់ ដល់ទៅគ្រប់ខែ គឺគ្រប់ខែនៅក្នុងគុក។

**ស៖** តើកូនស្រីរបស់លោកហ្នឹង នៅរស់រានមានជីវិត<ពីគុក រហូតដល់ចប់របបខ្មែរក្រហម> ដែរឬទេ?

**ឆ៖** បាទសព្វថ្ងៃវារស់ វាឈ្មោះ ថុល ឌីណា ប្ដីវានៅផ្នែកកសិកម្ម។ បច្ចុប្បន្ន គឺនៅផ្ទះជាប់ជាមួយខ្ញុំ។

**ស៖** តើលោកអាចរៀបរាប់អំពីអគារ ឬក៏កន្លែងដែលគេឃុំខ្លួនលោក ថាតើស្ថានភាពនៃការឃុំខ្លួនលោកមានលក្ខណៈបែបណា? គេដាក់ខ្នោះឃ្នាងរបៀបណាដែរ? តើលោកទៅដល់<អូរកន្សែង> ដំបូងហ្នឹង គេធ្វើយ៉ាងម៉េចដែរ?

[១១:០២:១៥]

**ឆ៖** ពេលដែលគេចាប់ខ្ញុំទៅ គេចុះពីឡាន គេឲ្យប្រពន្ធខ្ញុំទៅផ្សេង ហើយខ្ញុំ ប្រុសៗហ្នឹងមកផ្សេង។ ពេលដែលចូលទៅក្នុងផ្ទះដែលគេឃុំខ្លួនហ្នឹង គឺផ្ទះសង់អំពីឈើ ប្រក់ស្បូវ ជញ្ជាំងឫស្សី គ្រែ

ឫស្សី។ ហើយពេលទៅដល់ គឺកងសន្តិសុខរបស់វា ទាញច្រវាក់មួយខ្សែមក ចាក់សោ តម្រៀបជួរគ្នា ចាក់សោ ហើយឲ្យដឹកស្វាត់ស្វៀម។

**ស៖** តើមានអ្នកទោសប៉ុន្មាននាក់ដែរ នៅក្នុងបន្ទប់ជាមួយលោក នៅក្នុងអគារជាមួយលោកនុ៎ង?

**ឆ៖** បាទ ខ្ញុំមិនបានចាំដែរ ព្រោះវា ត្រែវាទល់គ្នា ចុងជើងទល់គ្នា ហើយចន្លោះដើរកណ្ដាល ហើយច្រវាក់ពីរខ្សែ អ៊ីចឹងមកដល់ថ្ងៃនេះ ខ្ញុំអត់បានចាំដែរ។

**ស៖** មុននេះបន្តិច លោកបាននិយាយថា គេបំបែកស្ត្រី និងបុរសផ្សេងពីគ្នា។ តើលោកដឹងថា តើប្រពន្ធលោកដែលមានផ្ទៃពោះហ្នឹង គេយកទៅទុកកន្លែងណាដែរ? ហើយគាត់ជួបប្រទះនូវស្ថានភាពបែបណាដែរ នៅពេលដែលគេយកគាត់ទៅដាក់គុកនុ៎ង?

**ឆ៖** យើងមើលឃើញផ្ទះទៅវិញទៅមក តែយើងអត់បានទទួលដំណឹងពីគ្នាទេ។

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកបន្តិច គឺចង់សួរអំពីហេតុការណ៍<ជាច្រើន>ដែលកើតឡើង<នៅពេលដែល>លោក<នៅទីនោះ>។ ឥឡូវហ្នឹងខ្ញុំចង់សួរបន្តអំពីរចនាសម្ព័ន្ធ និងការដឹកនាំនៅក្នុងគុកហ្នឹង ថាតើលោកចាំទេ<>ថាតើមន្ទីរសន្តិសុខអូរកន្សែងហ្នឹង គេមានឈ្មោះផ្លូវការហៅថា ឈ្មោះអីដែរ?

**ឆ៖** មន្ទីរ អាហ្នឹងគេហៅ គេដាក់ថា "សាលាកែប្រែ"។

**ស៖** តើលោកដឹងទេអង្គភាពអី <>ឬក៏ផ្នែកអីដែលគ្រប់គ្រង<សាលាកែប្រែ>អូរកន្សែងនោះ?

[១១:០៥:១២]

**ឆ៖** គ្រប់គ្រងនៅសាលាកែប្រែអូរកន្សែងនេះ គឺក្រោមការគ្រប់គ្រងរបស់កងពល៨០១ ដែលមានទីតាំងនៅក្នុងស្រុកវ៉ឺនសៃ។

**ស៖** ក្នុងពេលដែលលោកនៅទីនោះ តើលោកដឹងទេ <មេបញ្ជាការ>កងពល៨០១ ហ្នឹងឈ្មោះអីដែរ?

**ឆ៖** ខ្ញុំអត់បានឃើញមុខមាត់ប្រធានកងពលហ្នឹងទេ ប៉ុន្តែខ្ញុំគ្រាន់តែចាំបានចំពោះកងការពារដែលហៅថា បងធំៗ សារឿនៗ ជាប្រធានកងពល៨០១។

**ស៖** ចុះប្រធានសាលាអប់រំអូរកន្សែងហ្នឹង តើប្រធានសាលាអប់រំហ្នឹងមានឈ្មោះអ្វីដែរ?

**ឆ៖** ខ្ញុំអត់ចាំត្រកូលទេ ខ្ញុំចាំតែឈ្មោះ។ ប្រធានដឹកនាំរួមហ្នឹងឈ្មោះ សៃ ហើយបន្ទាប់មកឈ្មោះ ឆាង បន្ទាប់មកទៀតឈ្មោះ ទីម។

**ស៖** មានភ័ស្តុតាងនៅក្នុងសំណុំរឿងថា ត្រកូលរបស់ សៃ គឺឈ្មោះ <ឆោម>។ តើអាចលោក

នឹកឃើញទេថា ប្រធានមន្ទីរអប់រំហ្នឹងឈ្មោះ <ឆោម> សែ?

**ធ៖** បាទ ខ្ញុំមិនចាំត្រកូលទេ ប៉ុន្តែគេហៅថា បងសែៗ, បងឆាង និង បងទឹម។

**ស៖** មុននេះបន្តិច ខ្ញុំបានសួរលោកថា <តើលោកជាសមាជិកនៃ>កងពល៨០១ <ដែរ ឬអត់> ទេ ហើយលោកថា <លោកជាកម្មករ>នៅ<សហជីព>ចម្ការកៅស៊ូរបស់កងពលហ្នឹង។ ដូច្នេះខ្ញុំចង់ដឹងថា តើនៅពេលនុំងមានអ្នកដែលមិន<ជាសមាជិក>នៅក្នុងកងពល៨០១ហ្នឹង ត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខអូរកន្សែងហ្នឹងដែរឬទេ?

[១១:០៧:៥៥]

**ធ៖** បាទ សូមជម្រាបថា ខ្ញុំវាសហជីព ខ្ញុំមិនមែននៅកងពល៨០១ទេ។ អ៊ីចឹងខ្ញុំ ពេលដែលគេយកខ្ញុំទៅក្នុងសាលាកែប្រែនេះ គឺជាសាលាកែប្រែក្រោមការគ្រប់គ្រងរបស់កងពល៨០១ ក៏ប៉ុន្តែអ្នកដែលជាប់ឃុំឃាំងនៅក្នុងសាលាកែប្រែរបស់កងពល៨០១នេះ វាចម្រុះ។ វាមានទាំងប្រជាជន វាមានទាំងសហជីព វាមានទាំងកងទ័ព។

**ស៖** ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាជនស៊ីវិលត្រូវបានគេយកទៅឃុំនៅមន្ទីរសន្តិសុខដែលក្រោមការគ្រប់គ្រងរបស់កងពល៨០១ដែរ?

**ធ៖** អានេះជាផ្ទៃក្នុងរបស់អង្គការ យើងអត់បានដឹងទេ។ ព្រោះអីមិនដឹងថា គេមានកំហុសអីនៅតាមស្រុក នៅតាមឃុំយើងអត់ដឹងទេ ព្រោះអានេះវាជារឿងអង្គការ វាផ្ទៃក្នុងរបស់អង្គការ។ អ៊ីចឹងយើងអត់មានបានដឹងអីទាំងអស់ គ្រាន់តែបានឃើញថា ប្រជាពលរដ្ឋក្នុងមួយចំនួនក៏ត្រូវបានជាប់ឃុំនៅក្នុងសាលាកែប្រែនោះដែរ។

**ស៖** មុននេះបន្តិចលោកបាននិយាយថា មានកម្មករចម្ការកៅស៊ូ <ជាសមាជិក>កងពល៨០១ ហើយលោកបាននិយាយថា មានទាំងប្រជាជនធម្មតាដែលគេយកទៅទីនោះ។ តើលោកចង់មានន័យយ៉ាងម៉េចនៅពេលដែលលោកថា ប្រជាជនធម្មតាហ្នឹង?

**ធ៖** បាទ ខ្ញុំសូមជម្រាបថា ប្រជាជនធម្មតា គឺប្រជាជនដែលយកចេញពីភូមិ យកចេញពីឃុំនេះគេហៅថា ប្រជាជន។ រីឯកងទ័ពហ្នឹង គឺគេយកមកពីព្រំដែន គេហៅថា កងទ័ព។ អ៊ីចឹងប្រជាជនដែលជាប់ហ្នឹង គឺខ្ញុំចាំបាន គឺប្រជាជននៅស្រុកលំផាត់ ហើយប្រជាជននៅស្រុកវ៉ឺនសៃ។

[១១:០៩:៥៤]

**ស៖** តើលោកអាចប៉ាន់ប្រមាណមើល ថាមានមនុស្សប៉ុន្មាននាក់ដែរ ដែលគេឃុំនៅមន្ទីរអូរ

កន្លែងហ្នឹង នៅពេលដែលលោកទៅដល់<ដំបូង>ហ្នឹង? តើលោកអាចប៉ាន់ប្រមាណចំនួនមនុស្សឃុំនៅទីនោះបានទេ?

**ឆ៖** បាទ បើឲ្យដឹងពីចំនួនមនុស្ស ខ្ញុំអត់បានដឹងទេ ព្រោះអត់ប៉ានដើរ គេមិនឲ្យចេញ ជើងយើងនៅជាប់ច្រវាក់។

**ស៖** ខ្ញុំនឹងលើកយកប្រធានបទថ្មីមួយទៀត គឺទាក់ទងនឹងហេតុការណ៍<មួយ>ដែលលោកបានរៀបរាប់<នៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់លោក> ទាក់ទងទៅនឹងប្រជាជនចាវ៉ាយ ដែលគេយកមកឃុំនៅមន្ទីរសន្តិសុខអូរកន្សែងដែរ។ តើលោកអាចរៀបរាប់ប្រាប់តុលាការបានទេ ថាលោកចាំអ្វីខ្លះទាក់ទងទៅនឹងហេតុការណ៍ជនជាតិចាវ៉ាយនោះ?

**ឆ៖** បើនិយាយពីហេតុការណ៍គឺយើងខ្ញុំអត់បានដឹងទេ ប៉ុន្តែខ្ញុំគ្រាន់តែបានដឹងថា គេយកចាវ៉ាយមកទម្លាក់នៅខាងមុខអាផ្ទះគេដាក់ច្រវាក់ខ្ញុំហ្នឹង ទាំងឡានៗ ហើយចងខ្សែយកទៅកន្លែងផ្សេងទៀត។ អាហ្នឹងខ្ញុំបានដឹង។

**ស៖** តើលោកអាចប៉ាន់ប្រមាណទេ ថាតើមាន តើពួកគាត់ហ្នឹងមានចំនួនប្រហែលប៉ុន្មាននាក់ដែរ ដែលគេយកមកមន្ទីរ<សន្តិសុខ ឬសាលា>អប់រំអូរកន្សែងនោះ?

**ឆ៖** បើនិយាយពីចំនួនមិនបានដឹងទេ ព្រោះកន្លែងខ្លះ គេមិនឲ្យយើងទៅជិតផង ហើយម្យ៉ាងក៏យើងគ្មានសិទ្ធិចេញចូល និងដើរគ្រប់ផ្ទះដែលគេដាក់អ្នកទោសហ្នឹងទេ អត់បានដើរទេ គឺផ្ទះអ្នកណា អ្នកហ្នឹងចូល ចេញចូលបានតែផ្ទះខ្លួនឯងទេ។

[១១:១២:១៩]

**ស៖** តើលោកធ្វើយ៉ាងណាបានឃើញ តើលោកឃើញអ្នកទោសដែលលោកថា ជនជាតិចាវ៉ាយគេទម្លាក់នៅមុខកន្លែងលោកឃុំហ្នឹង លោកឃើញដោយរបៀបណាដែរ លោកអាចប្រាប់បានទេ?

**ឆ៖** បាទ សូមជម្រាបថា អាផ្ទះដែលគេដាក់អ្នកទោសហ្នឹង វាមិនមែនជាជញ្ជាំងជិតទេ គឺធ្វើឫស្សី។ អីចឹងអាឫស្សីហ្នឹងគឺវាររហែក ប៉ុន្តែគ្រាន់តែថាគេមិនឲ្យយើងចេញ។ យើងអាចលូកដៃចេញចូលបាន ប៉ុន្តែបើឲ្យយើងដើរចេញ គឺអត់បានទេ។ ប៉ុន្តែយើងមើលឃើញស្ទើរអស់ នូវទិដ្ឋភាពជុំវិញខ្លួន។

**ស៖** ខ្ញុំចង់សួរលោកអំពីចម្លើយដែលលោកផ្ដល់ជាមួយអ្នកស៊ើបអង្កេត គឺទំព័រភាសាអង់គ្លេសមានលេខ <00272587>, ខ្មែរមានលេខ 00189253 និងបារាំងមានលេខ <00272594> ហើយលោកបាននិយាយថា៖ "អ្នកទោសដែលមកដល់ថ្មីនោះ សុទ្ធតែជាជនជាតិចាវ៉ាយ នៅតាមព្រំដែនដែល

គេចាប់យកមក។ ពួកអ្នកទោសទាំងនោះមានប្រហែល១០០នាក់។” សូមបញ្ចប់ការដកស្រង់។ តើលោកអាចបញ្ជាក់បានទេ <ហេតុអ្វីបានជា>លោកថា<ប្រហែល>១០០នាក់ហ្នឹង តើវាជាការប៉ាន់ប្រមាណរបស់លោក ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ នេះជាកាប៉ាន់ស្មានរបស់ខ្ញុំទេ។ វាអត់មានការកំណត់ណាមួយទេ។

**ស៖** តើលោកអាចប្រាប់បានទេថា ក្នុងក្រុមចាវ៉ាយហ្នឹងមានតែបុរសសុទ្ធ ឬក៏មានតែស្ត្រីសុទ្ធ ឬមួយក៏មានបុរស មានស្ត្រី មានកូនក្មេងអីដែរ នៅក្នុងក្រុមនុ៎ង?

**ឆ៖** បាទ ចម្រុះគ្នា។

**ស៖** ចុះកូនក្មេង តើលោកចាំទេថាមានកូនក្មេងនៅក្នុងក្រុមជនជាតិចាវ៉ាយនោះ?

**ឆ៖** បាទ មាន។ មានក្មេងដឹកដៃ មានក្មេងព ពេលដែលខ្ញុំមើលឃើញ។

[១១:១៥:១៣]

**ស៖** ចុះស្ត្រីមានផ្ទៃពោះវិញ តើមានដែរទេ?

**ឆ៖** បាទ មាន។ ស្ត្រីមានផ្ទៃពោះមាន។

**ស៖** តើជនជាតិចាវ៉ាយនោះ គាត់ស្លៀកពាក់ សម្លៀកបំពាក់បែបណាដែរ?

**ឆ៖** បាទ សម្លៀកបំពាក់មិនស្លៀកពាក់ប៉ឹងទៅតាមប្រពៃណីជនជាតិរបស់គាត់ទេ គឺស្លៀកខោអាវធម្មតា ប៉ុន្តែគ្រាន់តែខោអាវចាស់ រហែក ប៉ះប៉ុណ្ណឹង។

**ស៖** តើលោកអាចរៀបរាប់ខោអាវ លោកអម្បាញ់មិញថាខោអាវចាស់ មានរហែក ប៉ះអីហ្នឹង តើលោករៀបរាប់ទេ ថាខោអាវចាស់ហ្នឹងវាមានលក្ខណៈបែបណាដែរ?

**ឆ៖** បាទ ពាក្យថាចាស់ហ្នឹង វាប្រលាក់ វាមានបំណះ ជាសម្លៀកបំពាក់របស់អ្នកក្រ។

**ស៖** លោកនិយាយថា ពួកគាត់ហ្នឹងជាជនជាតិភាគតិចចាវ៉ាយ។ ខ្ញុំចង់សួរថា លោកធ្វើយ៉ាងម៉េចដឹងថា គាត់ជាជនជាតិចាវ៉ាយ?

**ឆ៖** បាទ ខ្ញុំដឹងដោយសារពួកកងការពារវានិយាយ។

**ស៖** តើលោកអាចប្រាប់ឲ្យច្បាស់បានទេ ថាតើពួកកងការពារនោះប្រាប់លោកអីខ្លះ គឺថាក្រៅពីប្រាប់ថា ជាជនជាតិចាវ៉ាយហ្នឹង តើគេមាននិយាយអីប្រាប់លោកថែមទៀតទេ?

**ឆ៖** បាទ វាគ្រាន់តែនិយាយថា យប់មិញ បានបណ្ដើរពួកចាវ៉ាយចុះពីឡានប្រហែលរាប់សិបនាក់ ក្នុងនោះមានពីរគ្រឿង។ គ្រាន់តែប្រាប់តែប៉ុណ្ណឹង។ វាអត់ងងុយ វាថា អត់ងងុយល្ងាចមិញដោយ

សារយាមជនជាតិចារ៉ាយ ទើបតែចាប់មកថ្មីៗ។ វានិយាយអ៊ីចឹង មានតែប៉ុណ្ណឹងឯង។

[១១:១៧:៣២]

**ស៖** <>លោកនិយាយថា ពួកគេអត់បានដេក <តើលោកចង់សំដៅទៅលើពួកសន្តិសុខដែល> អត់បានសម្រាកហ្នឹងដោយសារតែពួកគេត្រូវ<>ដឹក<ជញ្ជូនពួកគេទាំងអស់នោះ> តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ យាមអ្នកទោស។ ព្រោះអីអ្នកទោសវាអង្គុយនៅកណ្ដាលវាល វាអត់មានផ្ទះចូល វាច្រើនគ្នាពេក។

**ស៖** តើលោកដឹងទេ អ្នកណាជាអ្នកនាំយកជនជាតិចារ៉ាយមក<មន្ទីរអប់រំ>អូរកន្សែងហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ។ គ្រាន់តែឃើញអាដំណើរវាចុះតែពីឡាន ហើយអង្គុយនៅកណ្ដាលវាល តែប៉ុណ្ណឹង។

**ស៖** តើលោកដឹងថា <ក្រុមអ្នកទោស>ជនជាតិចារ៉ាយហ្នឹងគេទុកនៅមន្ទីរ<អប់រំ>អូរកន្សែងហ្នឹង ប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ?

**ឆ៖** បាទ ខ្ញុំអត់បានចាំថ្ងៃទេ។ មិនដឹងជាប៉ុន្មានថ្ងៃ ប៉ុន្មានខែទេ ស្រាប់តែ ទុកមួយរយៈអ៊ីចឹងមក ក៏ស្រាប់តែបាត់អស់ទៅ។ ដល់ឲ្យខ្ញុំចាំថ្ងៃ គឺខ្ញុំអត់បានចាំថ្ងៃទេ។

**ស៖** តើលោកអាចប៉ាន់ប្រមាណមើលថា គេទុក ថាទុកត្រឹមតែប៉ុន្មានម៉ោង ឬក៏ប៉ុន្មានថ្ងៃ ឬក៏ប៉ុន្មានអាទិត្យដែរ?

**ឆ៖** បាទ សូមជម្រាបថា អត់ដល់មួយអាទិត្យទេ។

**ស៖** នៅពេលដែលគេយកពួកគាត់ទៅហ្នឹង តើលោកឃើញថា គេដឹកជនជាតិចារ៉ាយហ្នឹងទៅដែរឬទេ?

**ឆ៖** បាទ ខ្ញុំមើលតាមអាជញ្ជាំងរហែកហ្នឹង គឺខ្ញុំឃើញ គេចងនឹងខ្សែនីឡុងតម្រៀបជួរគ្នាចង ហើយដឹកចេញទៅ។

[១១:១៩:៥៧]

**ស៖** តើអ្នកណាដែរ ជាអ្នកបណ្ដើរពួកគាត់ចេញទៅ?

**ឆ៖** បាទ ខ្ញុំអត់បានចាំឈ្មោះទេ ប៉ុន្តែក្នុងហ្នឹងគឺកងការពារ កងសន្តិសុខរបស់សាលាកែប្រែនៅបឹងកន្សែង នៅអូរកន្សែងហ្នឹងតែម្ដង។

**ស៖** តើលោកដឹងទេថា មានអីកើតឡើងចំពោះអ្នកទោសចារ៉ាយនៅពេលដែលគេបណ្ដើរពួក

គាត់យកទៅនុ៎ង?

**ឆ៖** បាទ អត់បានដឹងទេ។

**ស៖** នៅក្នុងចម្លើយរបស់លោក<ផ្តល់ជូនអ្នកស៊ើបអង្កេត> ថាពីរបីថ្ងៃក្រោយមកទៀត គឺក្រោយពេលដែលអ្នកទោសចារ៉ាយត្រូវបានគេយកទៅ គឺ<លោកកំពុង>ធ្វើការនៅចម្ការខ្នុរ<ក្បែរទីនោះ>។ ហើយបន្ទាប់មកលោកថា លោកបានឃើញអ្វីមួយហ្នឹង។ តើលោកអាចរៀបរាប់<ជូនតុលាការ>បានទេថា តើមានអ្វីដែលលោកឃើញ<ដែរ>?

**ឆ៖** បាទ ក្រោយពេលបាត់ពីរថ្ងៃ ខ្ញុំត្រូវទៅធ្វើការនៅចម្ការខ្នុរ។ ពេលដែលខ្ញុំទៅធ្វើការនៅចម្ការខ្នុរ ខ្ញុំឃើញរណ្តៅគ្រាប់បែកមួយដែលបៀតនៅ ដែលក្បែរដើម ប្រហែលដើមដូងប្រេង។ ខ្ញុំឃើញថារណ្តៅហ្នឹងវាហើម ហើយក្នុងហ្នឹង ខ្ញុំឃើញមានឈាម ហើយមានសម្លៀកបំពាក់ មានពិល ស្បែកជើង។ ហើយខ្ញុំសន្និដ្ឋានក្នុងចិត្តថា ប្រហែលពួកចារ៉ាយនេះយកមកសម្លាប់ពីថ្ងៃមុន ពីរទៅបីថ្ងៃមុន ព្រោះដីវាហើមហើយ ក្នុងរណ្តៅគ្រាប់បែកហ្នឹង។

[១១:២២:០០]

**ស៖** តើលោកអាចប្រាប់បានទេថា ហេតុអីបានជាលោកគិតថា អ្នកដែលគេសម្លាប់នៅកន្លែងហ្នឹង ជាជនជាតិចារ៉ាយ?

**ឆ៖** ព្រោះយើងចំណាំសម្លៀកបំពាក់។ ពេលដែលចេញទៅ គឺយើងមើលសម្លៀកបំពាក់ ហើយវាបន្សល់ទុកនៅអាក្បែរមាត់រណ្តៅហ្នឹង ក៏សម្លៀកបំពាក់ហ្នឹងដដែល។

**ស៖** ដើម្បីបញ្ជាក់ឱ្យបានច្បាស់ អ៊ីចឹងលោកចង់និយាយថា ខោអាវដែលលោកឃើញនៅក្នុងរណ្តៅហ្នឹង គឺដូចគ្នានឹងខោអាវដែលលោកឃើញជនជាតិចារ៉ាយពាក់នៅពេលដែលគេឃុំខ្លួនហ្នឹង តើមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងសំណួរនេះ ព្រោះថានេះជាសំណួរនាំមុខ ដែលធ្វើឱ្យសាក្សីនិយាយអំពីអ្វីដែលគាត់មិនអាចបញ្ជាក់បាន។ គាត់ទើបតែបាននិយាយថា ឃើញគេបណ្តើរជន

ជាតិចារ៉ាយដែលគេមានខោអាវចាស់ៗ គឺគ្រាន់តែ<គាត់មើលឃើញតាមស្នាមប្រេះជញ្ជាំង> ថាឃើញពាក់ខោអាវចាស់ៗ ដែលថាខោអាវដែលអ្នកក្រពាក់។ ហើយឥឡូវគាត់មកសួរ ថាតើលោក<សាក្សី> ឃើញថាអ្នកទោសនោះពាក់ខោអាវដូចនៅក្នុងរណ្ដៅអ៊ីចឹង។ អាហ្នឹងវាជាការ<សួរ>នាំមុខ ហើយវាធ្វើឲ្យសាក្សីទាយស្មាននោះទេ។ <ដូច្នេះខ្ញុំសូមជំទាស់>។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរសំណួរឡើងវិញ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកបាននិយាយអំពីសម្លៀកបំពាក់ដែលលោកឃើញ គឺលោកឃើញនៅក្នុងចម្ការខ្នុរ ដែលធ្វើឲ្យលោកជឿថា នេះគឺជាជនជាតិចារ៉ាយ<ដែលត្រូវបានគេកប់នៅទីនោះ>។ ដូច្នេះខ្ញុំចង់សួរថា តើលោកឃើញខោអាវបែបណាដែលនៅចម្ការខ្នុរហ្នឹង ដែលធ្វើឲ្យលោកគិត<នៅក្នុងចិត្ត ដោយធ្វើការភ្ជាប់វាទៅនឹង>អ្នកទោស<>ជនជាតិចារ៉ាយ?

[១១:២៤:០៨]

**លោក ផន ថុល៖**

**ឆ៖** មានឯកសណ្ឋាន ការសម្លៀកបំពាក់របស់វា គឺវាមានពណ៌ក្រហម វាមានពណ៌ខៀវ ហើយរហែករញ៉េរញ៉ៃ។ ក្នុងហ្នឹងយើងបានសន្មតថា ពេលដែលចេញទៅ ក៏សម្លៀកបំពាក់ហ្នឹង ពេលដែលឃើញក៏សម្លៀកបំពាក់ហ្នឹងដដែល។

**ស៖** ខ្ញុំចង់សួរលោកអំពីចម្លើយដែលលោកផ្ដល់ជាមួយអ្នកស៊ើបអង្កេតគឺ ត្រង់ភាសាអង់គ្លេសមានលេខ 00272587, ខ្មែរមានលេខ 00189253 ដល់ 54 និងភាសាបារាំងមានលេខ 00272594។ លោកបាននិយាយថា៖ "នៅក្បែររណ្ដៅនោះខ្ញុំឃើញឈាម បាឡូ ខោអាវ ពិល ស្បែកជើង ដែលតាមសម្ភារៈទាំងនោះ ខ្ញុំសន្និដ្ឋានថាសាកសពទាំងនេះជាជនជាតិចារ៉ាយ។" តើលោកអាចប្រាប់បានទេ ថាដែលលោកឃើញមានបាឡូ ស្បែកជើង ឈាម ជាដើមហ្នឹង តើផ្អែកទៅលើអ្វីដែលលោកសន្និដ្ឋានថាសាកសពទាំងហ្នឹងជាជនជាតិចារ៉ាយ?

**ឆ៖** ពេលចេញដំណើរ គឺក្រុមដែលគេយកទៅហ្នឹងគឺមានស្ពាយបង្វេច មានស្ពាយបាឡូ។

**ស៖** លោកបាននិយាយថា លោកបានឃើញសម្ភារៈ តើៗលោកបានឃើញខ្មោច ឬក៏ឃើញសាកសពដែរឬទេ?

01454758



**ឆ៖** បាទ នៅក្បែរមាត់រណ្តៅគឺអត់បានឃើញសាកសពទេ ប៉ុន្តែឃើញសម្លៀកបំពាក់ដែលប្រឡាក់ទៅដោយឈាម។

[១១:២៦:១៩]

**ស៖** ឥឡូវនេះ ខ្ញុំនឹងសួរលោកបន្ថែមពីចម្លើយរបស់លោក<ផ្តល់ជូនអ្នកស៊ើបអង្កេត> គឺអង់គ្លេសមានលេខ គឺទំព័រដដែលនេះទេ។ បន្ទាប់មកពីលោកនិយាយអំពីនេះមក គឺថាលោកថា៖ "ខ្ញុំសន្និដ្ឋានថា សពទាំងនោះជាជនជាតិចារ៉ាយដែលគេដឹកយកមកសម្លាប់ទីនោះ" ហើយលោកនិយាយថា៖ "ខ្ញុំឃើញខ្មោចឡើងហើមប្រេះ"។ ថាតើលោកអាចនឹកឃើញដែរឬទេ ដែលថាលោកនិយាយថាលោកបានឃើញខ្មោច ឃើញសាកសពឡើងហើមប្រេះនៅទីនោះ?

**ឆ៖** បាទ នឹកឃើញពេលដែលខ្ញុំទៅដល់ ខ្ញុំឃើញដីវាប្រេះក្រោយបីថ្ងៃមក ឃើញដីវាហើមហើយវាធុំទៀត ស្អុយមកយើង សន្និដ្ឋានថាវាមានតែខ្មោចដែលនៅក្នុងរណ្តៅនោះ គេកប់អត់ជិត ហើយវាហើម។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើពីកន្លែងដែលលោកឃើញហ្នឹងរហូត -- ធៀបពីកន្លែងដែលលោកឃើញហ្នឹងទៅកន្លែង<>ដែលគេឃុំឃាំងខ្លួនលោកហ្នឹង តើវាមានចម្ងាយប្រហែលប៉ុន្មានដែរ?

**ឆ៖** ជាង១គីឡូដី។

**ស៖** តើកន្លែងទាំងអស់ហ្នឹងវានៅក្នុងបរិវេណ<មន្ទីរអប់រំអ្នូរ>កន្សែងហ្នឹង ឬមួយក៏វានៅក្រៅបរិវេណមន្ទីរ<អប់រំអ្នូរ>កន្សែងហ្នឹងទេ?

**ឆ៖** វានៅក្រៅបរិវេណមន្ទីរឃុំឃាំងបឹងកន្សែង ហើយបច្ចុប្បន្ននេះកន្លែងហ្នឹងវាអភិវឌ្ឍន៍ទៅជាផ្ទះថ្មអស់ហើយ។ អ៊ីចឹងយើងពិបាកសន្និដ្ឋានថា ទីតាំងហ្នឹងវាច្បាស់នៅកន្លែងណាៗ វាអត់ទេ។ ឥឡូវនិយាយរួមថាកន្លែងពិឃាដហ្នឹង វាគេឈូសឆាយទៅជាផ្ទះថ្មអស់រលីងទៅហើយ។

[១១:២៨:៤៧]

**ស៖** ខ្ញុំនឹងលើកយកប្រធានបទថ្មីមួយទៀត ប៉ុន្តែប្រធានបទនេះទាក់ទងទៅនឹងចម្ការខ្នុរដែរ។ លោកបាន<ប្រាប់យើងថា>លោកបានឃើញជនរងគ្រោះចារ៉ាយ តើលោកអាចប្រាប់បានទេ ថាលោកបានធ្លាប់ឃើញផ្ទាល់ពីការសម្លាប់មនុស្ស<ផ្សេងទៀត>នៅក្នុងចម្ការខ្នុរហ្នឹងដែរឬទេ? <បើធ្លាប់ឃើញតើលោកអាចរៀបរាប់ពីហេតុការណ៍នោះបានទេ?>

**ឆ៖** បាទ សូមនិយាយពិត និយាយត្រង់ គឺបានឃើញផ្ទាល់នឹងភ្នែក។ ខ្លួនខ្ញុំត្រូវបានគេឲ្យទៅយាមខ្ទុរ ដើម្បីហែកកុំឲ្យប្រជាពលរដ្ឋចូលក្នុងអារង្វង់ចម្ការខ្នុរហ្នឹង។ អ៊ីចឹងពេលដែលខ្ញុំយាម គឺខ្ញុំយាម គឺខ្ញុំឡើងអង្គុយលើដើមខ្នុរ គឺឃើញសម្លាប់ផ្ទាល់នឹងភ្នែកតែម្តង។

**ស៖** តើលោកអាចរៀបរាប់ពីការសម្លាប់ដែលលោកបានឃើញផ្ទាល់ភ្នែកហ្នឹងបានទេ?

**ឆ៖** បាទ ការសម្លាប់ដែលខ្ញុំឃើញផ្ទាល់នៅក្នុងចម្ការខ្នុរ ភាគច្រើន គឺវាយនឹងត្បូងចប ហើយទម្លាក់នៅក្នុងត្រង់សេ អាត្រង់សេជំនាន់ទាហានលន់នល់។

**ស៖** លោកបាននិយាយថា ភាគច្រើន ប៉ុន្តែខ្ញុំចង់សួរថា លោកអាចប្រាប់បានទេថាមានអ្នកទោសចំនួនប៉ុន្មាននាក់ដែរ ដែលលោកបានឃើញថា គេវាយសម្លាប់នឹងត្បូងចបនុ៎ង?

**ឆ៖** ខ្ញុំឃើញផ្ទាល់នឹងភ្នែកដែលខ្ញុំឃើញ និងអង្គុយលើដើមខ្នុរហ្នឹង គឺបីបួននាក់។ ហើយក្នុងហ្នឹង គឺមនុស្សដែលដើរស្ទើរតែមិនរួច ហើយជូនកាលសែងហើយ យកទៅទម្លាក់ចោល ហើយថាមុននឹងកប់ មនុស្សហ្នឹងនៅរស់ វាវាយបន្ថែម ហើយកប់ចោលនៅកន្លែងហ្នឹងទៅ។

**ស៖** តើអ្នកណាជាអ្នកប្រព្រឹត្ត? ថាតើអ្នកណាជាអ្នកសម្លាប់ដែលលោកបានឃើញនុ៎ង?

**ឆ៖** បាទ កងសន្តិសុខនៅក្នុងសាលាកែប្រែហ្នឹង។

**ស៖** តើលោកដឹងទេ ថាជនរងគ្រោះជាអ្នកណា? ប្រសិនបើលោកចាំឈ្មោះ លោកអាចប្រាប់ឈ្មោះបានទេ ប្រសិនបើលោកមិនចាំឈ្មោះ តើលោកអាចប្រាប់ថា ជាប្រភេទ<អ្នកទោស>អ្វីដែរ?

**ឆ៖** បាទ យើងមិនអាចចាំឈ្មោះបានទេ ព្រោះយើងៗជាប់ផ្ទុះ និយាយរួមថា យើងជាប់ច្រវាក់ជាប់ខ្នោះ ផ្ទុះៗរៀងខ្លួន ហើយគេត្រូវយកចេញ យកចេញអ៊ីចឹងទៅ គឺយើងមិនអាចទាក់ទងគ្នាបានទេ។ ហើយអ្នកហ្នឹងក៏មិនដឹងមកពីណាដែរ ហើយឈ្មោះអី ហើយធ្វើការអី។ អាហ្នឹងយើងអត់បានដឹងទេ។

[១១:៣២:១១]

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំត្រូវបន្តទៅប្រធានបទថ្មី ប៉ុន្តែដោយសារតែយើងដល់ពេលសម្រាកហើយ តើលោកប្រធានសម្រេចយ៉ាងដូចម្តេចដែរ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការ

សវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាកសាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤៩]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ហើយតំណាងសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅសល់ពេលវេលាតែមួយវគ្គនៃសវនាការនៅថ្ងៃរសៀនេះទេ។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំសូមបន្តលើកឡើងអំពីហេតុការណ៍មួយទៀតដែលលោកបាននិយាយនៅក្នុងកំណត់ស្តាប់ចម្លើយរបស់លោក គឺទាក់ទងទៅនឹងសន្តិសុខម្នាក់ឈ្មោះ ទីន តើលោកចាំ

ឈ្មោះនេះទេ?

[១៣:៣៣:១២]

**លោក ផន ថុល៖**

**ឆ៖** ចាំ បាទចាំ។

**ស៖** តើលោកធ្លាប់ឃើញឈ្មោះ ទីន ហ្នឹង<>សម្លាប់មនុស្សដែរឬទេ? <បើធ្លាប់ឃើញ តើអាចរៀបរាប់អំពីហេតុការណ៍ហ្នឹងបានដែរឬទេ?>

**ឆ៖** បាទ អត់ដែលទេ។

**ស៖** តើលោកចាំថា តើឈ្មោះ ទីន ហ្នឹងធ្លាប់ឲ្យលោកជួយកប់ខ្មោចមនុស្សដែរឬទេ កប់សាកសពដែរឬទេ?

**ឆ៖** បាទ ធ្លាប់។

**ស៖** តើលោកអាចរៀបរាប់អំពីហេតុការណ៍នោះ ប្រាប់តុលាការបានទេ?

**ឆ៖** ដែលខ្ញុំ ឈ្មោះវាប្រហាក់ប្រហែលគ្នា មួយ ទីម, មួយ ទីន។ ទីន ហ្នឹងគឺជាសន្តិសុខផ្ទាល់របស់សាលាកែប្រែ។ ក្រោយមានយប់មួយនោះ អ្នកជាប់នៅក្នុងសាលាកែប្រែរបស់ជនជាតិហ្នឹង ជាអ្នកជាប់នៅក្នុងសាលាកែប្រែ គឺជាជនជាតិភាគតិច ហើយក៏រត់ចេញទាំងយប់។ ព្រឹកឡើងគេរាប់ទៅវាបាត់ឈ្មោះហ្នឹង។ ដល់បាត់ឈ្មោះហ្នឹងទៅ គេចាប់ផ្ដើមសកម្មតាមដានត្រួតពិនិត្យនៅតាមដងផ្លូវនានា។ លុះដល់ប្រហែលជាម៉ោងពីរស្រាប់តែឃើញឈ្មោះហ្នឹងមកវិញ។ ដល់ឃើញឈ្មោះហ្នឹងមកវិញទៅលួមចំមុខនូវសញ្ញាឈ្មោះ ទីម ហ្នឹង។ ទីម ហ្នឹងក៏លើកកាំភ្លើងអា.ក៉េ ហ្នឹងគឺបាញ់សម្លាប់ជនជាតិហ្នឹងម្នាក់ហ្នឹងតែម្ដង នៅក្រោមដើមកំភ្លា។

[១៣:៣៤:៥៥]

**ស៖** តើលោកបានឃើញផ្ទាល់ថា ឈ្មោះ ទីន ហ្នឹងបាញ់អ្នកទោសហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានឃើញផ្ទាល់នឹងភ្នែក។

**ស៖** តើលោកដឹងទេ ថាតើអ្នកដែលត្រូវគេបាញ់ហ្នឹង គាត់ជាជនជាតិអីដែរ <ហេតុអ្វីបានជាគេបាញ់គាត់>?

**ឆ៖** ជនជាតិភាគតិច ខ្ញុំមិនដឹងថាជាជនអីទេ មិនដឹងជនជាតិអីទេ។ ជាមិនដឹងជាទំពួន ច្រៃ ឬកាវែតទេ ខ្ញុំអត់ដឹងទេ ប៉ុន្តែថាជាជនជាតិ ហើយវារត់ទៅរកបាយប្រជាជននៅជិតៗហ្នឹងស៊ី។ ដល់វា

ចេញពីភូមិប្រជាពលរដ្ឋមក វាចូលមកក្នុងសាលាកែប្រែវិញ ល្មមជួបនឹងសន្តិសុខគេតែម្តងទៅ គេបាញ់សម្លាប់តែម្តងទៅ។

**ស៖** លោកបាននិយាថា គាត់ត្រឡប់មកវិញ។ តើអ៊ីចឹង តើលោកចង់មានន័យថាគាត់ត្រឡប់មកវិញ នៅពេលដែលគាត់<នៅតាមផ្លូវ>ត្រឡប់មកមន្ទីរអប់រំកែប្រែហ្នឹងវិញ គេបាញ់គាត់ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទនេះជាការពិតហ្នឹងហើយ។ ពេលដែលគាត់ចូលមកកន្លែងកែប្រែវិញ គឺគេបាញ់គាត់។

**ស៖** តើលោកកប់សាកសពគាត់នៅកន្លែងណាដែរ?

**ឆ៖** នៅខាងលើចង្ក្រានបាយ ផ្លូវទៅគេហៅថាភូមិធ្លុយអំពិល ធ្លុយទុំនៅក្រោមដើមកំភ្លា ប៉ុន្តែឥឡូវវាទៅជាចម្ការរបស់បងប្អូន ដាំស្វាយចន្ទី យើងមិនអាចរកភ័ស្តុតាងហ្នឹងបានទេ។

**ស៖** ខ្ញុំចង់បន្តទៅហេតុការណ៍មួយទៀត គឺទាក់ទងទៅនឹងនារីម្នាក់ដែលត្រូវគេវះយកប្រមាត់។ តើលោកចាំអំពីហេតុការណ៍វះយកប្រមាត់របស់ស្ត្រីម្នាក់ទេ? ហើយប្រសិនបើលោកចាំ លោកអាចរៀបរាប់បានទេ?

[១៣:៣៧:០៤]

**ឆ៖** បាទចាំ។ នារីនោះខ្ញុំអត់បានចាំឈ្មោះទេ ប៉ុន្តែអ្នកសម្លាប់នោះឈ្មោះ ញ៉ុក ដែលជាសន្តិសុខផ្ទាល់របស់សាលាកែប្រែតែម្តង គឺយកពូថៅពុះឆ្អឹងខ្នងដើម្បីយកប្រមាត់។ ហើយប្រមាត់ហ្នឹងយកទៅដាក់នៅលើចង្ក្រានបាយ។ នោះខ្ញុំឃើញផ្ទាល់នឹងភ្នែកតែម្តង។ តែក្នុងសម្លាប់ ពេលដែលសម្លាប់ ខ្ញុំអត់បានឃើញទេ ឃើញវាយកប្រមាត់ប្រឡាក់ដោយសុទ្ធតែឈាមនៅលើដៃ ហើយប្រមាត់យកទៅចងឆ្អើរនៅលើចង្ក្រានបាយ។

**ស៖** តើលោកធ្វើយ៉ាងណាបានដឹងថាឈ្មោះ ញ៉ុក ហ្នឹងជាអ្នកវះយកប្រមាត់ពីនារីម្នាក់នោះ?

**ឆ៖** ព្រោះវានិយាយខ្លួនឯង វាទៅប្រាប់អ្នកដាំបាយសម្រាប់អ្នកទោសទាំងអស់នៅក្នុងសាលាកែប្រែហ្នឹង គឺវានិយាយខ្លួនឯង។ វាអ្នកវះ វាអ្នកកាប់ដើម្បីយកប្រមាត់ទៅឆ្អើរ។

**ស៖** តើលោកដឹងទេថា ហេតុអ្វីបានជាគេសម្លាប់វះយកប្រមាត់នារីហ្នឹង?

**ឆ៖** បាទ ខ្ញុំមិនដឹងមូលហេតុផលរបស់គេយ៉ាងម៉េចទេ ប៉ុន្តែគ្រាន់តែថា ខ្ញុំបានឃើញវាយក អាសន្តិសុខហ្នឹងវាយកប្រមាត់ទៅចូលចង្ក្រានតែម្តង តែរឿងទោសកំហុស យើងខ្ញុំអត់បានដឹងទេ។

**ស៖** ខ្ញុំចង់និយាយអំពីកំណត់ហេតុស្តាប់ចម្លើយដែលលោកបាននិយាយជាមួយអ្នកស៊ើបអង្កេត

គឺឯកសារ 00272587 ជាភាសាអង់គ្លេស ហើយភាសាខ្មែរគឺមានលេខ 00189254 ហើយបារាំងមាន លេខ 00272594ដល់95។ ហើយលោកបានរៀបរាប់អំពីហេតុការណ៍ប្រហែលនឹងអ្វីដែលបាននិយាយ ដែលថា៖ “ញ៉ុក គឺជាអ្នកនិយាយអំពីហេតុការណ៍ហ្នឹង គឺ<យកប្រមាត់ហ្នឹងទៅព្យួរ>នៅក្នុងចង្ក្រាន បាយ <ដើម្បីបំភ័យអ្នកទោសផ្សេងទៀត>។ ហើយបន្ទាប់មកទៀតគាត់និយាយថា ហេតុផលគឺ ដោយសារតែ គឺដោយសារនារីម្នាក់នោះជាកម្មករសហជីពចម្ការកៅស៊ូដែលខុសសីលធម៌ជាមួយប្រុស <ម្នាក់>។ ខ្ញុំមិនចាំឈ្មោះនារីនោះទេ ប៉ុន្តែប្ដីរបស់នាងឈ្មោះ សន (នៅរស់) សព្វថ្ងៃនៅស្ទឹងត្រែង។” សូមបញ្ចប់ការដកស្រង់។ តើលោកអាចនឹកឃើញដែរឬទេ ថាហេតុផលដែល ញ៉ុក វះប្រមាត់នារីម្នាក់ ហ្នឹង គឺដោយសារហេតុផលនេះ?

[១៣:៣៩:៥៦]

**ឆ៖** បាទ ចាំ។ ចាំគឺថាខុសសីលធម៌ជាមួយបុរស។ ហើយប្ដីនារីហ្នឹងគឺនៅខេត្តស្ទឹងត្រែង ឈ្មោះ សន ប៉ុន្តែរឿងស្លាប់ឬរស់ ខ្ញុំអត់បានដឹងទេ។

**ស៖** ឥឡូវនេះខ្ញុំបន្តទៅប្រធានបទមួយទៀត។ តើលោកចាំទេដែលថាមានអ្នកទោសវៀតណាម មួយចំនួន<ប្រហែលប្រាំ ឬប្រាំមួយនាក់> ត្រូវបានគេនាំមក មន្ទីរកែប្រែអូរកន្សែង?

**ឆ៖** បាទ អត់ចាំទេ។ អត់បានដឹងរឿងអ្នកទោសវៀតណាម។

**ស៖** ខ្ញុំចង់និយាយប្រាប់លោកអំពីព័ត៌មានមួយចំនួនដែល ឆោម សែ ដែលជាប្រធានមន្ទីរសន្តិ-សុខ<អូរកន្សែង>បាននិយាយ ហើយគាត់បានប្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺ ឯកសារ E3/405 នៅសំណួរចម្លើយ១២។ ហើយគាត់បាននិយាយដូចតទៅនេះ សូមដកស្រង់៖ “មុនឆ្នាំ៧៨បន្តិច មុនពេលដែលមានការវាយប្រហារខ្លាំងពីវៀតណាមឆ្នាំ៧៨ ខ្ញុំឃើញក្រុមវៀតណាមប្រាំមួយ<នាក់> ដែលជាជនស៊ីវិលត្រូវបានគេយកមកដាក់ឃុំខ្លួននៅ<សមរភូមិ>អូរយ៉ាដាវ គឺនៅតាមព្រំដែន ព្រោះថា ពួកទាំងអស់នេះគឺមក<ឈ្លបយកការណ៍នៅលើផ្លូវ១៩> រួមជាមួយនឹងកងទ័ពវៀតណាមដែល<ប៉ុន ប៉ង>មកវាយកម្ពុជា។ បន្ទាប់ពីការសួរចម្លើយចប់សព្វគ្រប់ហើយ គឺថ្នាក់លើសម្រេចកម្ទេចពួកទាំង អស់នេះចោល ហើយយោងទៅតាមបញ្ជារបស់<មេបញ្ជាការ>កងពល៨០១ ឲ្យបញ្ចប់ពួកទាំងអស់ នេះតែម្ដង។” សូមបញ្ចប់ការដកស្រង់។ បន្ទាប់ពីបានស្ដាប់ព័ត៌មានរបស់ ឆោម សែ តើលោកអាចនឹក ឃើញអំពីហេតុការណ៍នេះដែរឬទេ?

[១៣:៤២:១៨]

**ឆ៖** បាទ ខ្ញុំអត់បានដឹងផង។ អត់បានដឹងរឿងរៀតណាមជាមួយនឹងសម្ដីរបស់ នោម សែ នេះទេ។

**ស៖** មិនអីទេលោក សូមអរគុណចំពោះចម្លើយដែលលោកឆ្លើយនេះ។ ឥឡូវនេះខ្ញុំចង់និយាយប្រធានបទមួយទៀត អំពីការសួរចម្លើយ ហើយនិងការធ្វើទារុណកម្ម។ ខ្ញុំសូមសួរលោកជាដំបូងថា តើលោកដឹងអំពីការធ្វើទារុណកម្ម? តើក្នុងពេលសួរចម្លើយហ្នឹង គឺការសួរចម្លើយនៅអូរកន្សែងហ្នឹង គេមានប្រើទារុណកម្មទេ?

**ឆ៖** ចំពោះរូបខ្ញុំ គេគ្រាន់តែដាក់ច្រវាក់ជើង ហើយនិងចងដៃ ហើយគេសួរចម្លើយ ប៉ុន្តែទារុណកម្មគេអត់ធ្វើទេ។ ឯចំពោះអ្នកដទៃទៀតដែលសួរបន្តបន្ទាប់ពីខ្ញុំគឺទី១ គឺគេវៃ ទី២គឺគេឆក់ខ្សែភ្លើងទៅតាមអាទូរស័ព្ទរវៃដៃ។

**ស៖** តើលោកធ្វើយ៉ាងណាបានដឹងថា អ្នកទោសដទៃទៀតហ្នឹងត្រូវបានគេវៃ ឬក៏គេឆក់ខ្សែភ្លើង?

**ឆ៖** ព្រោះផ្ទះដែលសួរចម្លើយហ្នឹងគឺផ្ទះល្វែង មិនមែនដូចខ្ញុំទេ។ ខ្ញុំគេយកទៅសួរនៅកន្លែងសម្ងាត់ មានអាផ្ទះមួយតូច ដាច់ឆ្ងាយប្រហែលជា៥០ម៉ែត្រពីកន្លែងសាលាកែប្រែ។ ដែលចំពោះអ្នកដទៃដែលដាក់ខ្សែភ្លើង ហើយនិងធ្វើបាបហ្នឹង គឺគេធ្វើនៅក្នុងផ្ទះដែលក្នុងច្រវាក់តែម្ដង។

[១៣:៤៤:១០]

**ស៖** តើលោកដឹងដោយរបៀបណាដែរ?

**ឆ៖** ឃើញផ្ទាល់នឹងភ្នែក។

**ស៖** តើលោកអាចប្រាប់ទេថា ហេតុអ្វីទើបលោកអាចមើលឃើញដោយផ្ទាល់ភ្នែកនូវការធ្វើទារុណកម្ម? គឺខ្ញុំចង់សួរថា <តើលោកនៅកន្លែងណា>ទើបអាចលោកបានមើលឃើញដោយផ្ទាល់ភ្នែកស្ដាប់ឮផ្ទាល់ត្រចៀកបែបនេះ?

**ឆ៖** ដូចខ្ញុំជម្រាបពីមុនរួចហើយ ដដែលៗហើយថា សាលាកែប្រែនោះធ្វើពីជញ្ជាំងឫស្សី។ ឯជញ្ជាំងឫស្សីនោះ វាមិនមែនបិទជិតដូចជញ្ជាំងក្ដារ ឬជញ្ជាំងផ្ទះថ្មទេ វាមានជាប្រហោងរយេករយះគ្រាន់តែវាមានវិន័យមួយថាកុំឱ្យតែយើងរត់តែប៉ុណ្ណឹង។

**ស៖** តើលោកដឹងទេ អ្នកណាជាអ្នកធ្វើទារុណកម្មនៅពេលសួរចម្លើយនោះ?

**ឆ៖** បាទ ខ្ញុំអត់បានចាំឈ្មោះទេ គ្រាន់តែដឹងថាសន្តិសុខនៅក្នុងសាលាកែប្រែរបស់សាលាកែ

ប្រែនោះតែម្តង។

**ស៖** ចុះអ្នកណាជាអ្នកសួរចម្លើយលោក? ដូចលោកថា គេអត់ធ្វើទារុណកម្មលោកទេ ប៉ុន្តែអ្នកណាជាអ្នកសួរចម្លើយលោក?

**ឆ៖** អ្នកសួរចម្លើយខ្ញុំឈ្មោះ ទីន។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកបាននិយាយអំពីអ្នកទោស<កងពល>ម្នាក់ មកពីបរកែវ។ តើលោកចាំទេ អំពីអ្នកទោសកងពល ដែលត្រូវបានគេធ្វើទារុណកម្មនៅពេលសួរចម្លើយហ្នឹង? តើលោកអាចរៀបរាប់បានទេ?

[១៣:៤៦:២៧]

**ឆ៖** បាទ ចាំ។ អ្នកទោសដែលគេយកមកហ្នឹង គឺយកមកសួរចម្លើយ សរសេរប្រវត្តិរូបនៅលើគ្រែ។ ហើយដល់គេមើលម្តងហើយ វាអត់ត្រូវ អត់ត្រូវតាមការយល់របស់គេ គឺគេយកអាដង្កាប់យើងហ្នឹង គឺយករឹបភ្លៅ រហូតដល់អ្នកហ្នឹងស្រែកទាល់សន្លប់។

**ស៖** តើហេតុការណ៍ដែលលោកនិយាយអំមិញហ្នឹង វាកើតឡើងចំពោះអ្នកទោសតែម្នាក់ទេ ឬក៏កើតឡើងចំពោះអ្នកទោសច្រើននាក់ក្នុងក្រុម<>?

**ឆ៖** បាទ អ្នកទោសដែលដាក់ដង្កាប់នៅភ្លៅហើយរឹតខ្សែកៅស៊ូនេះ គឺចំពោះអ្នកទោសតែម្នាក់។

**ស៖** តើក្រោយពេលដែលគេសួរចម្លើយ ហើយធ្វើទារុណកម្មគាត់ហើយហ្នឹង តើលោកដឹងទេថាមានអីកើតឡើងចំពោះគាត់?

**ឆ៖** បាទពេលព្រឹកឡើងអត់ឃើញមនុស្សហ្នឹងផង មិនដឹងគេយកទៅណា ខ្ញុំក៏អត់ដឹងដែរ។

**ស៖** នៅពេលដែលគេសួរចម្លើយលោកផ្ទាល់ហ្នឹង តើលោកចាំទេ គេសួរសំណួរលោក គេសួរចម្លើយលោកពីអីខ្លះ?

**ឆ៖** បាទ នេះដូចខ្ញុំជម្រាបពីព្រឹកហើយ សំណួរនេះច្រំដែលទេ គឺគេសួរខ្ញុំថា "តើមានទោសអីបានគេយកសមមិត្តមកកន្លែងកែប្រែ?" ខ្ញុំក៏ឆ្លើយថា "ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំមិនដែលធ្វើអ្វីខុសចំពោះមុខបក្សទេ។ ហើយគេក៏ប្រាប់ខ្ញុំថា "មកពីសមមិត្តប្រើបច្ចេកទេសសក្តិភូមិ" វាថាបច្ចេកទេសជិះយន្តហោះ អត់ដើរនឹងជើង។ បាទ អាហ្នឹងខ្ញុំបាននិយាយម្តងហើយ។

[១៣:៤៨:៤០]

**ស៖** តើគេមានសួរអំពី សេ.អ៊ី.អា, កា.ហ្សេ.បេ ដែរទេ នៅពេលដែលសួរចម្លើយលោកនោះ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** បាទ អត់មានទេ។ គេសួរតែពីរឿងបច្ចេកទេសប៉ុណ្ណឹង។

**ស៖** ខ្ញុំចង់សួរលោកអំពីចម្លើយមួយទៀត ដែលលោកផ្តល់ជាមួយអ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេត គឺនៅត្រង់ភាសាអង់គ្លេសមានលេខ 00272585, ខ្មែរមានលេខ 00189252 និងបារាំងមានលេខ <00272593>។ គឺក្នុងចំណុចនេះ គឺលោកមិននិយាយអំពីការសួរចម្លើយទេ ប៉ុន្តែនិយាយអំពីអ្នកទោសនៅក្នុងបន្ទប់ឃុំឃាំង។ លោកបាននិយាយដូចតទៅនេះ៖ “អ្នកទោសអាចនិយាយជាមួយគ្នាទៅវិញទៅមកបាន ដូចជាសួរពីប្រវត្តិគ្រួសារ សួរសុខទុក្ខគ្នាធម្មតា តែមិនហ៊ាននិយាយពីរឿងនយោបាយទេ ដោយខ្លាចគេចោទថាជា កា.ហ្សេ.បេ និង សេ.អ៊ី.អា។” សូមបញ្ចប់ការដកស្រង់។ តើលោកអាចប្រាប់បានទេ ហេតុអ្វីបានជាលោកខ្លាចគេចោទថាជា សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ នោះ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា នៅក្នុងសាលាកែប្រែជាប់ច្រវាក់ជាមួយគ្នា គឺយើងនិយាយបានតែពីសុខទុក្ខគ្រួសារ តែរឿងផ្សេងទៀត យើងអត់និយាយបានទេ មូលហេតុដែលយើងនិយាយមិនបានខ្លាចគេចោទយើងថា យើងជាភ្នាក់ងារខ្មាំង, កា.ហ្សេ.បេ, សេ.អ៊ី.អា។ ហេតុដូចម្តេចបានខ្ញុំនិយាយរបៀបនេះ? ព្រោះថាកន្លងមក គេចោទប្រជាពលរដ្ឋដែលយកទៅសម្លាប់ គេច្រើនដូចថាខ្មាំង ភ្នាក់ងារខ្មាំង, កា.ហ្សេ.បេ, សេ.អ៊ី.អា។

[១៣:៥០:៤៥]

**ស៖** តើលោកដឹងអំពីស្ថានភាពជាក់ស្តែងថា អ្នកទោសនៅអូរកន្សែងហ្នឹង មានគេធ្លាប់ចោទប្រកាន់ថាជា សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ធ្លាប់ផង ប៉ុន្តែគ្រាន់តែឮពាក្យខាងសន្តិសុខ វានិយាយថា ភ្នាក់ងារៗ គឺយើងគ្រាន់តែឮភាសាហ្នឹង គឺយើងខ្លាចតែម្តង។

**ស៖** តើសន្តិសុខហ្នឹង គេនិយាយពីអីដែរ<ពីភ្នាក់ងារ កា.ហ្សេ.បេ, សេ.អ៊ី.អា> គឺលោកនិយាយថា លោកឮពីសន្តិសុខនោះ?

**ឆ៖** បាទ សន្តិសុខនោះវាច្រើននិយាយថា ពួកមកដែលគេសម្លាប់ហ្នឹង ច្រើនតែភ្នាក់ងារសម្ងាត់របស់ភ្នាក់ងារ សេ.អ៊ី.អា, កា.ហ្សេ.បេ។

**ស៖** តើលោកស្តាប់ឮគេនិយាយហ្នឹង គេនិយាយជាមួយសន្តិសុខគ្នាទេ ឬក៏គេនិយាយប្រាប់អ្នកទោស?

**ឆ៖** អត់, គេមិនដែលប្រាប់អ្នកទោសទេ គឺនិយាយសន្តិសុខគ្នាគេ តែគេនិយាយឮៗ គេមិន

និយាយខ្សឹបទេ។

**ស៖** ខ្ញុំចង់និយាយបន្ថែមអំពីស្ថានភាពនៅកន្លែងឃុំឃាំង។ តើលោកអាចប្រាប់បានទេថា មានអគារប៉ុន្មានដែរ ដែលគេប្រើដើម្បីឃុំអ្នកទោស?

**ផ៖** បើខ្ញុំៗ នៅចាំមិនភ្លេចទេ មានផ្ទះវែងៗហ្នឹងបី ដែលសម្រាប់ដាក់អ្នកទោសនៅកន្លែងឃុំឃាំង។

[១៣:៥២:៤៣]

**ស៖** តើលោកអាចរៀបរាប់អំពីការដាក់ខ្នោះឃ្នាងហ្នឹងបានដែរឬទេ? ហើយតើគេដាក់នៅពេលណា? គេដាក់នៅក្នុងរយៈពេលប៉ុន្មានអីដែរ<ក្នុងមួយថ្ងៃ>?

**ផ៖** ខ្ញុំអត់ដឹងរយៈពេលប៉ុន្មានទេ ប៉ុន្តែការដាក់ខ្នោះវាមានបីប្រភេទនៅក្នុងកន្លែងឃុំឃាំងមួយ គឺមានបីប្រភេទ។ ទី១ គឺដាក់ច្រវាក់ ចាក់សោ។ ទី២ គឺដាក់ខ្នោះ ធ្វើនឹងដែកសរសៃ។ ហើយទី៣ ធ្វើអំពីឈើ។

**ស៖** តើអ្នកទោសទាំងអស់ ត្រូវបានគេដាក់ខ្នោះ ឬមួយក៏គេដាក់តែអ្នកទោសមួយចំនួនទេ?

**ផ៖** គឺឲ្យតែអ្នកចូលទៅដល់ក្នុងនុ៎ង គឺគេដាក់ច្រវាក់ ដាក់ខ្នោះ និងដាក់ខ្នោះឈើទាំងអស់។

**ស៖** លោកអាចប្រាប់បានទេ នៅពេលដែលលោកជាប់ខ្នោះ ហើយចង់ទៅបន្ទប់ទឹក តើលោកធ្វើដូចម្ដេចដែរ?

**ផ៖** បាទ សូមជម្រាបថា សាលាកែប្រែអត់មានបន្ទប់ទឹកជំនាន់នោះ គឺបត់ជើង គេដាក់បំពង់ឫស្សីឲ្យ។ ឯកាលណាពេញបំពង់ឫស្សី គេឲ្យយកទៅចាក់ដោយខ្លួនឯង នៅកន្លែងក្រៅ។

**ស៖** សូមអរគុណ។ ប្រសិនបើអ្នកទោសណាម្នាក់ គាត់ធ្វើខុស<វិន័យមន្ទីរអប់រំអ្វូរកន្សែង> តើមានអីកើតឡើងចំពោះពួកគាត់ដែរ?

**ផ៖** បាទ សូមជម្រាបថា នៅក្នុងឃុំឃាំងនោះ វិន័យគេ គេបានប្រាប់យើងថា ទី១ កុំរត់ចេញ ទី២ កុំលួច។

**ស៖** លោកបានប្រាប់យើងអំពីអ្នកទោសម្នាក់ដែលរត់គេច ហើយក្រោយមកត្រូវបានគេបាញ់សម្លាប់។ ប៉ុន្តែតើលោក<ដឹងថា>មានអ្នកទោសណាផ្សេងទៀតដែល<ដែលរំលោភបំពានវិន័យ ហើយ>ទទួលលទ្ធផល ឬក៏ទទួលនូវទណ្ឌកម្ម<ដែរ ឬ>ទេ?

[១៣:៥៥:២៥]

**ឆ៖** មានអ្នកទោសមួយទៀត វានៅ វាអត់រត់ចេញទេ វានៅនឹងកន្លែង វានៅនឹងក្នុងផ្ទះកន្លែងដាក់ច្រវាក់ហ្នឹង ក៏ប៉ុន្តែពេលដែលគេឲ្យចេញទៅដកស្មៅនៅខាងមុខផ្ទះ មកវិញ វាលួចអាគ្រាប់ធូរេនដែលគេបណ្ដុះនៅក្នុងកន្ត្រកឫស្សីហ្នឹងយកទៅដុត។ ហើយដល់ពេលល្ងាចគេត្រូវយកវាទៅសម្លាប់ទាំងយប់។

**ស៖** ក្រៅពីអ្នកទោសនេះទៀត តើលោកដឹងថាមានអ្នកទោសណាផ្សេងខ្លះទៀតដែលបាត់ខ្លួនដែរ?

**ឆ៖** បាទ អត់ដឹងទេ។ ទោះបី -- ប៉ុន្តែដឹងតែថា ពួកយើងនៅក្នុងអាផ្ទះដែលគេដាក់ច្រវាក់ដាក់ខ្នោះនោះ ឲ្យតែហៅពេលយប់ គឺនាំគ្នាភ័យហើយ ព្រោះអ្នកហៅចេញពេលយប់ មិនដែលឃើញមកវិញទេ។

**ស៖** ខ្ញុំចង់សួរលោកបន្ថែមអំពីបញ្ហាសុខភាព បញ្ហាអនាម័យ <ការមើលថែទាំវេជ្ជសាស្ត្រ> ថាតើលោកដឹងទេ មានអ្នកទោសណាដែលឈឺ ហើយស្លាប់នៅមន្ទីរអប់រំអ្នកទ្បែងហ្នឹងដែរឬទេ?

**ឆ៖** បាទ មាន។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើអ្នកទោសហ្នឹងគាត់ឈឺអ្វីដែរ? មានជំងឺអ្វីដែរ? ហើយគាត់ទទួលបានការព្យាបាលដែរឬទេ? ហើយតើមានអ្វីកើតឡើងដែរចំពោះអ្នកទោសដែលឈឺនោះ?

[១៣:៥៧:៣០]

**ឆ៖** បាទ អ្នកទោសដែលឈឺនោះ ខ្ញុំឃើញនោះ គឺខ្ញុំធ្លាប់ស្គាល់ គាត់ជាកម្មករសហជីពជាមួយគ្នាដែរ។ គាត់ឈ្មោះ ធឿន កម្ពុជាក្រោម ឈឺ រាកមួល គឺគាត់ស្លាប់។ ហើយម្នាក់ទៀតឈឺដែរ ឈឺរាកមួលដែរ គឺស្លាប់នៅក្នុងច្រវាក់។ ហ្នឹងខ្ញុំឃើញផ្ទាល់នឹងភ្នែក។

**ស៖** តើពួកគាត់ទទួលបានការព្យាបាលពីគ្រូពេទ្យដែរឬទេ នៅពេលដែលគាត់ឈឺ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងដែរ។ អាហ្នឹងរឿងថ្នាំ ក៏អាហ្នឹងវាអាស្រ័យទៅលើអ្នកគ្រប់គ្រងសាលាកែប្រែ។

**ស៖** ចុះប្រពន្ធរបស់លោកដែលលោកនិយាយថា គាត់មានផ្ទៃពោះហ្នឹង តើនៅពេលដែលគាត់មានផ្ទៃពោះហ្នឹង គាត់មានទទួលបានថ្នាំពេទ្យ ឬក៏ការព្យាបាលថែទាំអីដែរឬទេ?

**ឆ៖** បាទ ពេលឆ្លងទន្លេ គឺខ្ញុំឃើញវាឲ្យពេទ្យប្រចាំសាលាកែប្រែហ្នឹងទៅរាល់ថ្ងៃ ប៉ុន្តែមិនដឹងទៅធ្វើអី ទៅចាក់ថ្នាំ ឬទៅលេបថ្នាំ ឬទៅឲ្យថ្នាំខ្មែរ ថ្នាំបូរាណអីខ្ញុំអត់ដឹងទេ។ តែឲ្យឃើញគ្រូពេទ្យហ្នឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅរាល់ព្រឹក។

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកអំពីការងារ។ តើអ្នកទោសនៅអូរកន្សែងហ្នឹង គាត់ត្រូវបានគេឲ្យធ្វើការងារអីខ្លះដែរ?

**ឆ៖** ការងារនៅក្នុងសាលាកែប្រែអូរកន្សែងហ្នឹង ទី១គឺ ដាំដំឡូង ទី២គឺដាំបន្លែ។

**ស៖** នៅក្នុងចម្លើយរបស់លោក<ដែលឆ្លើយជូនសហចៅក្រមស៊ើបអង្កេត លោក>បាននិយាយអំពី<ការ>លីឈើ តើលោកអាចរៀបរាប់បានទេ អំពីការងារលីឈើនៅអូរកន្សែង?

[១៣:៥៩:៥៦]

**ឆ៖** បាទ អាហ្នឹងវា លីឈើហ្នឹងវាគឺធ្វើតែម្ដងម្កាលទេ ព្រោះថាឲ្យអ្នកទោសទៅអារឈើនៅក្នុងព្រៃ ដើម្បីយកឈើហ្នឹងមកធ្វើផ្ទះឲ្យបញ្ចោការរបស់សាលកែប្រែហ្នឹងនៅ។

**ស៖** តើការងារដែលអ្នកទោសត្រូវធ្វើហ្នឹង ជាការងារធ្ងន់ធ្ងរដែរឬទេ?

**ឆ៖** ការងារដែលអ្នកទោសធ្វើ គឺការងារបោចស្មៅ និងអត់ប្រើនឹងចប នឹងខ្វែវទេ គឺបោចនឹងដៃ។ ហើយការដាំបន្លែ ក៏ដូចគ្នាដែរ អត់ប្រើជីមកពីណាទេ គឺប្រើជីមនុស្ស។ កាយនឹងដៃ ធ្វើនឹងដៃទាំងអស់។

**ស៖** តើអ្នកទោសមានគេតម្រូវឲ្យថា កំណត់ទំហំការងារ ឬក៏កំណត់ចំនួនការងារអីត្រូវធ្វើដែរឬទេ?

**ឆ៖** បាទ ដូចជាអត់មានទេ។ ទៅណា គឺទៅទាំងអស់គ្នា ដោយឡែកតែអ្នកដាំបាយ។ អ្នកត្រូវបោចស្មៅ បោចស្មៅ អ្នកត្រូវធ្វើដាំបន្លែ គឺដាំបន្លែ អ្នកដាំបាយ នៅដាំបាយ។

**ស៖** តើលោកធ្វើការប៉ុន្មានម៉ោងដែរនៅពេលនោះ?

**ឆ៖** បាទ នៅក្នុងសម័យ ប៉ុល ពត ដូចគ្មានម៉ោងទេ។ ព្រឹកចេញធ្វើការ ដល់ពេលបាយឲ្យមកបាយ ៗហើយទៅវិញ។ រហូតដល់ពេលយប់ ដេកបាយហើយចូលផ្ទះរៀងខ្លួនដែលកន្លែងធ្លាប់នៅ គឺនៅរៀងខ្លួន អត់មានទៅណាឆ្វេកឆ្វាចទេ។

[១៤:០២:០៧]

**ស៖** នៅក្នុងកំណត់ហេតុជាមួយសហចៅក្រមស៊ើបអង្កេតរបស់លោក គឺភាសាអង់គ្លេសមានលេខ 00272586, ខ្មែរ 00189253 និងបារាំងមានលេខ 00272594។ លោកបាននិយាយថា៖ “អ្នកទោសធ្វើការពីម៉ោងប្រាំមួយព្រឹក ដល់ម៉ោងដប់មួយថ្ងៃត្រង់ រួចសម្រាកហូបបាយ។ រួចបន្តពីម៉ោងមួយ

ដល់ម៉ោងប្រាំមួយល្ងាច សម្រាកហូបបាយក្នុងរោង រួចគេបញ្ចូលក្នុងបន្ទប់ឃុំឃាំងវិញ ដោយចាក់សោពីក្រៅ ហើយមានអ្នកយាម។" តើអ្វីដែលខ្ញុំអានហ្នឹង វាត្រូវគ្នាជាមួយនឹងការចងចាំរបស់លោកដែរឬទេ? គឺថាលោកមុននេះ លោកថាអត់មានម៉ោងពេលទេ ប៉ុន្តែក្នុងចម្លើយរបស់លោក គឺលោកបានបញ្ជាក់ពេលម៉ោង តើយ៉ាងម៉េចដែរ?

**ឆ៖** ចម្លើយវាជាការមួយត្រឹមត្រូវហើយ ប៉ុន្តែខ្ញុំនិយាយពីរឿងម៉ោង និង ពេលវេលានេះ គឺអត់មានម៉ោងទេ គឺយើងមើលថ្ងៃ ហើយយើងស្មាន គឺម៉ោងប្រាំមួយព្រឹកយើងចេញ ថ្ងៃមិនទាន់រះផុតពីដីទេ បានសេចក្តីថា យើងស្មាន ហើយរហូតដល់ថ្ងៃត្រង់ ប្រហែលម៉ោងដប់មួយ ឬម៉ោងដប់ពីរ។ បាទ ហ្នឹងយើងស្មានទេ។

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកពីអាហារ តើលោកទទួលបានរបបអាហារយ៉ាងដូចម្តេចដែរនៅអូរកន្សែង?

**ឆ៖** បាទ នៅសាលាកែប្រែអូរកន្សែងនេះ វាច្រើនតែប្រើអង្ករពោតលាយជាមួយនឹងបាយ ហើយនិងដំឡូងមី។

**ស៖** តើរបបអាហារគ្រប់គ្រាន់ដែរឬទេ សម្រាប់ការរស់នៅ ក៏ដូចសម្រាប់ការងារដែលលោកធ្វើការនោះ?

[១៤:០៤:២៦]

**ឆ៖** របបក្នុងម្នាក់គឺមួយចាន គឺមួយចានចង្កឹះដែលគេវាល់ឲ្យ ដូចអាកោអ៊ីចឹង ហើយសម្លប្អូននាក់មួយចាន។

**ស៖** តើលោកមានស្រកគីឡូដែរឬទេ? តើលោកមានស្គមទេ នៅពេលដែលលោកនៅមន្ទីរសន្តិសុខអូរកន្សែងនោះ?

**ឆ៖** សូមជម្រាបថា កន្លែងហ្នឹង កន្លែងមិនមែនកន្លែងបំប៉នជីវភាពទេ គឺជាកន្លែងគេយកទៅធ្វើទោស។ អ៊ីចឹងបានសេចក្តីថា ស្បែកខ្ញុំដែលទាញទៅ គឺនៅត្រង់ អត់លាមកវិញទេ។ យើងទាញស្បែកដៃយើង គឺស្បែកដៃគឺនៅត្រង់អ៊ីចឹង ទាល់តែយើងប្រយ៉ឹត បានទាញមកវិញ។ ហើយគីឡូ ខ្ញុំមិនដែលថ្លឹងទេ ប៉ុន្តែថាអាខោដែលយកទៅ គឺស្លៀកអត់ជាប់។

**ស៖** មុនខ្ញុំបញ្ចប់ ខ្ញុំសូមសួរពាក់ព័ន្ធទៅនឹងចម្លើយដែលលោកឆ្លើយពីខាងដើមនៅក្នុងថ្ងៃនេះ។ តើ<>លោក<ផ្តល់បទសម្ភាសន៍>បានប៉ុន្មានដង? ហើយលោកតាមខ្ញុំចាំ លោកឆ្លើយថា <>លោក

<បានផ្តល់កិច្ចសម្ភាសន៍>តែពីរដងទេ។ ទី១ គឺនៅមន្ទីរអប់រំកែប្រែរបស់ខ្មែរក្រហម គឺហើយនិងទី២ គឺនៅផ្ទះរបស់លោក។ <> អ៊ីចឹងមែនទេ?

**ផ៖** បាទ ទី១ គឺធ្វើនៅកន្លែងសាលាកែប្រែចាស់។ ហើយទី២ មកធ្វើនៅផ្ទះខ្ញុំតែម្តង។

**ស៖** ប៉ុន្តែនៅពេលដែលលោកផ្តល់ចម្លើយពីរលើកនេះ <គឺគេសម្ភាសពីអ្វីដែលបានកើតឡើង> នៅមន្ទីរសន្តិសុខអូរកន្សែង។ ត្រឹមត្រូវដែរទេ?

**ផ៖** បាទ ត្រឹមត្រូវហើយ។

[១៤:០៦:៤០]

**ស៖** ហើយហ្នឹងកិច្ចសម្ភាសន៍នេះ គឺជាកិច្ចសម្ភាសន៍មួយដែលគេធ្វើដាច់ដោយឡែកពីកិច្ចសម្ភាសន៍ដែលសម្ភាសឡើងដោយមន្ត្រីស៊ើបអង្កេតសាលាក្តីខ្មែរក្រហម។ អ៊ីចឹងទេ?

**ផ៖** បាទខ្ញុំមិនដឹងយ៉ាងម៉េចដែរ គ្រាន់តែខ្ញុំចាំថា ទី១ដោយមានជនបរទេសធ្វើនៅកន្លែងសាលាកែប្រែបឹងកន្សែង។ ហើយទី២ គឺខ្មែរសុទ្ធមកធ្វើនៅផ្ទះខ្ញុំ តែមិនដឹងតួនាទីជាស្អីទេ។ ខ្ញុំឆ្លើយជម្រាបបានប៉ុណ្ណឹង។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណចំពោះចម្លើយនេះ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ សូម មេធាវីនាំមុខសូមប្រគល់សិទ្ធិនៅក្នុងការសួរនោះជូនលោកស្រីមេធាវី ទី ស្រ៊ីនណា។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១៤:០៨:២៥]

**លោកស្រី ទី ស្រ៊ីនណា៖**

ជាបឋមនាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល

និងសូមគោរពលោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** នាងខ្ញុំឈ្មោះ ទី ស្រ៊ុនណា ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនចង់ធ្វើការតាំងសួរទៅលោក ដើម្បីឲ្យលោកជួយបំភ្លឺនូវហេតុការណ៍ដែលលោកបានជួបប្រទះនៅក្នុងគុកអូរកន្សែង។ ជាដំបូងខ្ញុំសូមធ្វើការបញ្ជាក់ឡើងវិញ ដោយសារកាលពីព្រឹកមិញ លោកបានឆ្លើយជាមួយនឹងខាងសហព្រះរាជអាជ្ញាទាក់ទងទៅនឹងបុគ្គលម្នាក់ ដែលលោកស្គាល់ឈ្មោះថា ឈ្មោះ ស្វ -- ឈ្មោះ សារឿន ដែលជាប្រធានកងពល៨០១។ តើអ៊ីចឹងមែនទេ លោក?

**លោក ផន ថុល៖**

**ឆ៖** បាទ ឈ្មោះ សារឿន ដូចដែលខ្ញុំប្រាប់ខាងសហព្រះរាជអាជ្ញាអ៊ីចឹង។

**ស៖** ខ្ញុំចង់សូមសួរលោកថា ក្រៅពីឈ្មោះ សារឿន នេះលោកមានស្គាល់អ្នកដទៃ បុគ្គលដទៃផ្សេងទៀតដែរឬទេលោក? សូមលោកជួយរៀបរាប់ជូនអង្គសវនាការទាក់ទងទៅនឹងបុគ្គលដែលលោកស្គាល់ ហើយគាត់មានតួនាទីនៅក្នុងមន្ទីរសន្តិសុខនោះដែរ ក៏ដូចជានៅកងពល៨០១។ សូមអញ្ជើញ!

[១៤:០៩:៥៧]

**ឆ៖** បាទ រវាងកងពលនិងខ្ញុំ គឺខ្ញុំមិនដែលធ្វើការទំនាក់ទំនងទេ ព្រោះថា ក្នុងសម័យនោះយើងអត់មានដើរបានឆ្ងាយ ឬធ្វើការទំនាក់ទំនងធំទូលាយ យើងអត់មានទេ។ ប៉ុន្តែខ្ញុំស្គាល់ឈ្មោះនេះ ស្គាល់ដោយសារតែកងសន្តិសុខនៅប្រចាំសាលាកែប្រែអូរកន្សែងហ្នឹង ដែលប្រាប់ខ្ញុំថាកង ប្រធានកងពលឈ្មោះ សារឿង តែប៉ុណ្ណោះ ឯអ្នកដទៃទៀតគឺអត់បានស្គាល់គ្នាទេ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំចង់សុំសួរលោកពាក់ព័ន្ធជាមួយនឹង ដោយសារលោកបានមានប្រសាសន៍ថា លោកគ្រាន់តែបាននៅក្នុងមន្ទីរសន្តិសុខនុ៎ង អ៊ីចឹងខ្ញុំចង់ ខ្ញុំចង់សួរលោកពាក់ព័ន្ធជាមួយនឹងការអនុវត្តវិញ។ ថាតើនៅក្នុងការអនុវត្តនៅក្នុងមន្ទីរសន្តិសុខហ្នឹង ចំពោះសន្តិសុខទាំងអស់ដែលបានអនុវត្ត ជាពិសេសគឺពាក់ព័ន្ធជាមួយវិន័យ ទាក់ទងទៅនឹងការគ្រប់គ្រងអ្នកទោសអីហ្នឹង តើការអនុវត្តរបស់គេយ៉ាងម៉េចដែរ លោក?

**ឆ៖** ដូចខ្ញុំនិយាយពីខាងដើមអ៊ីចឹង វិន័យរបស់គេដូចជាបទបញ្ជាផ្ទៃក្នុងណាមួយអ៊ីចឹង។ អ៊ីចឹងបានសេចក្តីថា អ្នកដែលជាប់នៅក្នុងសាលាកែប្រែរបស់អូរកន្សែងនេះ គេគ្រាន់តែផ្តោតទី១ កុំរត់, ទី២

កុំលួច។ ឯចម្លើយគឺតាមការឃើញនឹងភ្នែករបស់ខ្ញុំគឺថា សួរហើយឆ្លើយ តែការធ្វើទារុណកម្មត្រង់ៗ មិនត្រង់ គឺខ្ញុំអត់បានដឹងទេ។ គ្រាន់តែថា ប្រហែលជាមិនត្រង់ទេ បានគេវ៉ៃ ឬក៏គេធ្វើបាប។

[១៤:១១:៤២]

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់សំណួរខ្ញុំឡើងវិញ ប្រហែលជាខ្ញុំសួរមិនបានច្បាស់លាស់។ ខ្ញុំចង់ជម្រាបសួរលោកថា ពេលនុ៎ងលោកកំពុងតែនៅក្នុងទិដ្ឋភាពមួយទាក់ទងទៅនឹងគុកអូរកន្សែង។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើផ្អែងតាមការកត់សម្គាល់របស់លោក ពាក់ព័ន្ធជាមួយនឹងការអនុវត្តរបស់មន្ត្រីជាពិសេសគឺពាក់ព័ន្ធជាមួយនឹង គេហៅសន្តិសុខ។ សន្តិសុខនៅទីនោះហ្នឹង តើការអនុវត្តរបស់គេហ្នឹងសន្តិសុខហ្នឹង គាត់គោរពទៅតាមបញ្ជាថ្នាក់លើដែរ ឬក៏យ៉ាងណា ឬមួយក៏មានការអនុវត្តដោយបំពានទៅលើបញ្ជាដែរ ឬក៏យ៉ាងម៉េចដែរ លោក តាមការសង្កេតរបស់លោកជាក់ស្តែង?

**ឆ៖** បាទ សូមជម្រាបថា សន្តិសុខ តើគោរពតាមបទបញ្ជារបស់ថ្នាក់លើ ឬមួយក៏ឆ្មៃប្រឌិតខ្លួនឯង នៅក្នុងសាលាកែប្រែរបស់អូរកន្សែងនោះ ខ្ញុំអត់បានដឹងជាបទបញ្ជារបស់ខាងលើ ជាមួយសន្តិសុខយ៉ាងណា ហើយការឆ្មៃប្រឌិតធ្វើយ៉ាងណាមកពីបញ្ជា ឬមួយក៏សន្តិសុខហ្នឹងធ្វើខ្លួនឯង អាហ្នឹងខ្ញុំអត់បានដឹងទេ។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមប្តូរពាក់ព័ន្ធជាមួយនឹង ទាក់ទងទៅនឹងចំណុចការចាប់ខ្លួនវិញម្តង។ លោកបានឆ្លង -- លោកត្រូវបានគេចាប់ទៅដាក់នៅគុកអូរកន្សែង។ ដំបូងខ្ញុំចង់សុំសួរលោកថា លោកមានបានសង្កេតមើលទេ តើពេលដែលលោកចូលអូរកន្សែងដំបូងហ្នឹង មានអ្នកទោសនៅក្នុងអូរកន្សែងហ្នឹង ចំនួនប៉ុន្មាននាក់ដែរ? លោកអាចប៉ាន់ប្រមាណ ខ្ញុំអត់ត្រូវការព័ត៌មានជាក់លាក់ ចំនួនជាក់លាកទេ តែខ្ទង់ថាចំនួនប្រហែលប៉ុន្មាន ច្រើន ឬក៏តិច ឬក៏យ៉ាងម៉េចដែរ លោក?

**ឆ៖** ពេលដែលខ្ញុំចូលទៅ ខ្ញុំឆ្លងបាន ឆ្លងកាត់បានផ្ទះមួយ ហើយក៏ការមើលក៏មិនប៉ានមើលចំផង គ្រាន់តែដៀងចុងភ្នែក។ ខ្ញុំមើលទៅតាមចន្លោះជញ្ជាំងហ្នឹង ឃើញអ្នកដេកនៅនឹងដី ហើយដែលជាប់អាខ្នោះធ្វើអំពីដែកសរសៃហ្នឹង គឺប្រហែលជាជាង១០នាក់ នៅដេកនៅនឹងដី។

[១៤:១៣:៥៦]

**ស៖** សូមអរគុណ។ អ៊ីចឹងមានន័យថា លោកមិនបានដើរក្នុង -- លោកមិនបានក្រឡេកមើលទិដ្ឋភាពជុំវិញក្រៅពីបន្ទប់ហ្នឹងមួយទេ។ តើអ៊ីចឹងមែនទេ លោក?

**ឆ៖** បាទ ព្រោះថាផ្ទះហ្នឹងវានៅតាមផ្លូវដើរ។ អ៊ីចឹងបើសិនជាយើងធ្វើអ្វីខុស គឺយើងខ្លាចខ្លួន

ដែរ ព្រោះដំណើររបស់ត្រូវការការពារពីសន្តិសុខជាប់បួនប្រាំនាក់សងខាងហើយ សុទ្ធតែកាំភ្លើង អា.កា ដូច្នេះយើងមិនប៊ានធ្វើអីឲ្យខុសពីការណែនាំរបស់គេទេ។

**ស៖** សូមអរគុណ។ តើលោករស់នៅក្នុងអូរកន្សែងហ្នឹង រយៈពេលប៉ុន្មានឆ្នាំដែរ លោក?

**ឆ៖** បាទ សំណួរនេះ ខ្ញុំបានប្រាប់ពីព្រឹកហើយ។ ខ្ញុំជាកម្មករសហជីព គេចាប់ខ្ញុំនៅថ្ងៃទី១៦ ខែ៦ ឆ្នាំ១៩៧៧ រហូតដល់ខែ១២ ឆ្នាំ១៩៧៨ គឺការវាយប្រហារពីកងទ័ពវៀតណាមមកខ្លាំងពេក នៅពេលយប់ ក៏នាំគ្នារត់ចេញរប៉ាត់រប៉ាយទៅ។

**ស៖** សូមអរគុណ។ អ៊ីចឹងមានន័យថា លោករស់នៅទីនោះហាក់បីដូចជាយូរដែរ អ៊ីចឹងខ្ញុំចង់សូមសួរថា ក្នុងអំឡុងពេលដែលលោករស់នៅទីនុ៎ងហ្នឹង តើមានៗការចល័តរវាងអ្នកទោស មានន័យថា មានអ្នកគេនាំអ្នកទោសថ្មីចូលមកដែរឬក៏អត់ ឬក៏ជួនកាលមានអ្នកទោសដែលគេចូលមកហើយ ត្រូវគេបញ្ជូនបញ្ចេញទៅវិញ ឬមួយក៏មានការផ្លាស់ប្តូរអ្នកទោសអ៊ីចឹងដែរ ឬៗក៏យ៉ាងម៉េច? ហើយបើមានការផ្លាស់ប្តូរហ្នឹង តើគេធ្វើការផ្លាស់ប្តូររយៈពេលប៉ុន្មានដង?

**ឆ៖** បាទ បើតាមខ្ញុំដឹងថា អ្នកទោសនៅក្នុងសាលាកែប្រែអូរកន្សែងនេះ ដូចគ្មានចល័តទៅកន្លែងណាទៀតទេ ព្រោះពេលយប់វាបញ្ចេញ ហៅឈ្មោះបញ្ចេញអ៊ីចឹង អស់បីបួននាក់អ៊ីចឹង ស្អែកឡើងមកបីបួននាក់វិញ។ អ៊ីចឹងការចល័ត ហាក់ដូចជាគ្មានទេ។

[១៤:១៦:២២]

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់ឡើងវិញ អ៊ីចឹងមានន័យថា ពេលយប់ត្រូវគេបញ្ជូនចេញបីបួននាក់ ហើយព្រឹកឡើងគេបញ្ជូនចូលបីបួននាក់ទៀត។ អ៊ីចឹងអ្នកដែលគេបញ្ជូនចេញបីបួននាក់ហ្នឹង និងអ្នកដែលគេបញ្ជូនចូលបីបួននាក់ហ្នឹង ជាមនុស្សតែ -- ជាបុគ្គលតែមួយ ឬមួយក៏ជាបុគ្គលផ្សេងគ្នាដាច់ដោយឡែក អ្នកដទៃ ជាបុគ្គលផ្សេងគ្នា?

**ឆ៖** បាទ ខ្ញុំដូចខ្ញុំជម្រាបជូនពីខាងដើមហើយ ខ្ញុំថា ឲ្យពេលយប់ គេបើកទ្វារនៅផ្ទះណាមួយ ហើយគេហៅឲ្យចេញដើម្បីទៅរៀននៅកន្លែងអង្គការ អាហ្នឹងបានសេចក្តីថា មនុស្សហ្នឹងគឺត្រូវតែបាត់ម្តង។ ប៉ុន្តែអ្នកចូលមកវិញ វាមិនមែនចូលរាល់ថ្ងៃទេ បួនប្រាំថ្ងៃឃើញម្នាក់ពីរនាក់ មិនមែនថាចេញប្រាំចូលប្រាំទេ។

**ស៖** សូមអរគុណ។ តើការចេញចូលហ្នឹងមានច្រើនដងដែរឬទេលោក តាំងពីលោកចូលទៅអូរកន្សែង រហូតដល់ពេលលោកត្រូវចាកចេញពីអូរកន្សែង?

**ឆ៖** បាទ មិនសូវជាញាប់ប៉ុន្មានទេ។

**ស៖** ខ្ញុំសូមសួរលោកពាក់ព័ន្ធចំណុចហ្នឹងដែរ ថាតើលោកមានចាប់អារម្មណ៍ដែរឬទេ ថាអំឡុងពេលណា ដែលៗអ្នកទោសមានចំនួនអ្នកទោសជាច្រើន ត្រូវបានគេបញ្ជូលទៅក្នុងអូរកន្សែងហ្នឹង មានចំនួនទ្រង់ទ្រាយធំដែរ ឬក៏អត់ដែលមានសោះ ឬក៏យ៉ាងម៉េច លោក?

**ឆ៖** បាទ ដូចខ្ញុំជម្រាបប្រាប់ពីព្រឹកហើយ ថាដែលមានទ្រង់ទ្រាយធំ ខ្ញុំឃើញតែម្តងគត់ ដែលខ្ញុំថា ជនជាតិចារ៉ាយហ្នឹង ក្រៅពីហ្នឹង គឺអត់មានទ្រង់ទ្រាយធំទេ។

[១៤:១៨:២៨]

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមសួរលោក ពាក់ព័ន្ធជាមួយនឹងការឃុំឃាំងវិញ។ ដោយសារតែមុនហ្នឹងលោកក៏បានបំភ្លឺពាក់ព័ន្ធជាមួយការឃុំឃាំងដែរ ក៏ប៉ុន្តែខ្ញុំវាហាក់បីដូចជាមានភាពមិនសូវច្បាស់លាស់ អ៊ីចឹងសូមឲ្យលោកធ្វើការបញ្ជាក់ឡើងវិញ អំពីស្ថានភាពនៅក្នុងមន្ទីរឃុំឃាំងឲ្យបានច្បាស់បន្តិចមក ថាតើក្នុងអំឡុងពេលនុ៎ង អ្នកទោសនុ៎ងគាត់ ការរស់នៅរបស់អ្នកទោសនុ៎ង យ៉ាងម៉េចដែរលោក? ទាំងរូបលោកផ្ទាល់ ក៏ដូចជាអ្នកទោសដទៃទៀតណ៎ា តើគាត់ទទួលបានលក្ខខណ្ឌយ៉ាងម៉េចដែរ សូមលោកជួយបំភ្លឺមក។

**ឆ៖** បាទ សូមជម្រាបជូនថា ការរស់នៅក្នុងមន្ទីរឃុំឃាំងរបស់អូរកន្សែងនេះ គឺពេលថ្ងៃ គេឲ្យយើងចេញធ្វើពលកម្ម។ ពេលយប់ គឺមិនឲ្យដើរឆ្វេកឆ្វាច ចូលនឹងកន្លែងដាក់ច្រវាក់ ហើយនៅស្ងៀមស្ងាត់។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមសួរលោកបន្ថែម បញ្ជាក់បន្ថែមទៅលើការសួរចម្លើយវិញតែម្តង។ តើការសួរចម្លើយវិញ ចំពោះការសួរចម្លើយទៅលើអ្នកទោសវិញ តើអ្នកទោសទាំងអស់ហ្នឹងគឺរាល់អ្នកទោសទាំងអស់ដែលជាប់នៅក្នុងអូរកន្សែងទាំងអស់ គឺត្រូវបានសួរចម្លើយគ្រប់ៗគ្នា ឬក៏យ៉ាងម៉េចដែរលោក?

**ឆ៖** បាទ ចំពោះបញ្ហាហ្នឹងគឺខ្ញុំអត់បានដឹងច្បាស់ទេ មិនដឹងថាបានសួរទាំងអស់ ឬមួយក៏សួរមួយចំនួន គឺខ្ញុំអត់បានដឹងទេ។

[១៤:២០:២៨]

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរលោកថា តើពីបន្ទប់លោកមកកន្លែងសួរចម្លើយហ្នឹងមានចម្ងាយប៉ុន្មានដែរលោក?

**ឆ៖** បាទ ខ្ញុំប្រាប់ពីព្រឹកមិញហើយថាប្រមាណជា៥០ម៉ែត្រ ប៉ុន្តែវាគ្មានវាលទេ គឺពីកន្លែងអាផ្ទះដាក់អ្នកទោសទៅកន្លែងសួរចម្លើយ គឺបាំងដោយព្រៃ គឺភាគច្រើនគឺដើមកំភ្លា។

**ស៖** សូមអរគុណ។ អ៊ីចឹងបើសិនជាប្រវែង៥០ម៉ែត្រអ៊ីចឹង ៗរាល់ពេលដែលគេសួរចម្លើយអ្នកទោសម្តងៗហ្នឹង លោកមានឮសំឡេងនៅក្នុងការសួរចម្លើយដែរឬទេ?

**ឆ៖** ពី អំពីខ្លឹមសារសួរគឺខ្ញុំអត់បានឮទេ ព្រោះគេអត់ដែលសួរវ៉ោកវ៉ាក លាន់ឮការហៅបាចហាចទៅខាងក្រៅទេ គឺសួរហៅថាមួយម៉ាត់ៗ ហើយសំឡេងស្រាលប៉ុណ្ណឹងទេ គេអត់ទៅស្បូរខ្លាំងទេ។ ប៉ុន្តែពេលខ្លះក៏ឮសម្រែកពីកន្លែងសួរចម្លើយដែរ។

**ស៖** ខ្ញុំសូមឲ្យលោក -- ខ្ញុំសូមស្នើឲ្យលោកជួយរំឭកឡើងវិញមើល ថាតើពេលដែលលោកឮសម្រែកពីខាងកន្លែងសួរចម្លើយហ្នឹងប្រហែលជាប៉ុន្មានដងដែរលោក?

**ឆ៖** បាទ មិនអាចចាំបានទេ ប៉ុន្តែវាមិនច្រើនដងទេ។ ឲ្យ បើនិយាយពីចំនួនពិតប្រាកដគឺខ្ញុំបាទអត់ចាំបានទេ។

**ស៖** សូមអរគុណ។ លោកបានលើកឡើងអំពីរាល់ពេលយប់ ឬក៏ត្រូវបានគេយកអ្នកទោសចេញ។ អ៊ីចឹងខ្ញុំចង់សូមសួរលោកមួយទៀត លោកមានដែលធ្លាប់ដឹង ឬក៏ឮទាក់ទងនឹងការសម្លាប់ដែលមានការចាក់សំឡេង ចាក់សំឡេងជាឃោសនសព្ទអីផ្សេងៗអី លោកមានដែលដឹង ឬក៏ឮករណីហ្នឹងនៅក្នុង -- មានករណីបែបហ្នឹងនៅក្នុងមន្ទីរសន្តិសុខហ្នឹងដែរឬទេ?

[១៤:២៣:២៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីវ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនដឹងថាសំណួរនេះចេញមកពីប្រភពណា។ គាត់និយាយអំពីការសម្លាប់មនុស្សដែលគេនាំខ្លួនចេញយកទៅក្រៅនៅពេលយប់ ហើយគាត់បានឆ្លើយថាគាត់បានឮ ថាគេយកពួកគេចេញទៅក្រៅ ហើយមិនដែលឃើញត្រឡប់មកវិញទេ។ ដូច្នេះ មិនមានភ័ស្តុតាងអ្វីបញ្ជាក់ថាគេបានសម្លាប់អ្នកនោះឬទេ។ ហើយឯការចាក់ភ្លេងបំពងសំឡេងមកពីខាងក្រៅនោះ ក៏មិនដឹងថាជាភ្លេងអ្វីនោះដែរ។ ដូច្នេះខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។

**លោកស្រី ទី ស្រ៊ុនណា៖**

ខ្ញុំសូមឆ្លើយទាក់ទងទៅនឹងចំណុចហ្នឹងបន្តិច។ ពាក់ព័ន្ធជាមួយការដែលនាំអ្នកទោសចេញនៅពេលយប់ហ្នឹង គឺជាចម្លើយដែលសាក្សីគាត់បានឆ្លើយជាខ្លួនឯង តាំងពីព្រឹកក៏ដូចជាមុននឹងបន្តិចក៏គាត់បានឆ្លើយថា ជារឿងរាល់រសៀលនៅពេលយប់ហ្នឹងគឺត្រូវបានបាត់ -- អ្នកទោសត្រូវបានគេបញ្ជូនចេញ អ៊ីចឹងនាំគ្នាភ័យខ្លាចគ្រប់គ្នា។ ហើយចំណែកទាក់ទងទៅនឹងសំឡេងឃោសនសព្ទ ខ្ញុំនឹងរៀបចំសំណួរខ្ញុំឡើងវិញ លោកប្រធាន។

[១៤:២៥:០០]

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** ខ្ញុំសូមសួរលោកពាក់ព័ន្ធនឹងចំណុចផ្សេងទៀត ថាតើកន្លងមកអ្នកទោសដែលនៅក្នុងមន្ទីរសន្តិសុខហ្នឹង ក្រោយការសួរចម្លើយហើយ ត្រូវបានមានអ្នកទោសណាដែលត្រូវបានគេដោះលែងឲ្យមានសេរីភាពដែរឬទេ កន្លងមកលោក?

**លោក ផន ថុល៖**

**ឆ៖** បាទ ក្រោយពេលដែលសួរចម្លើយរួច ហាក់ដូចជា គ្មានមនុស្សណាដែលនៅក្នុងសាលាកែប្រែអូរកន្សែងនេះ ឲ្យមានសេរីភាពទេ។

**ស៖** សូមអរគុណ។ ពាក់ព័ន្ធជាមួយចំណុចមួយដែលលោកព្រះរាជអាជ្ញាបានសួរលោកពាក់ព័ន្ធជាមួយនឹងនារីដែលត្រូវបានគេវះខ្លងយកប្រមាត់។ ខ្ញុំចង់សូមសួរលោកថា ពេលដែលគេវះខ្លងយកប្រមាត់ហើយ គាត់ត្រូវបានយកប្រមាត់ហ្នឹង -- តាញ៉ុក ត្រូវបានយកប្រមាត់ហ្នឹងទៅព្យួរនៅរោងបាយ ពេលដែលគេព្យួរប្រមាត់នៅរោងបាយហ្នឹង ពេលនុ៎ងមានមនុស្សច្រើននៅទីនោះ ឬក៏អត់ទេ លោក?

**ឆ៖** បាទ ខ្ញុំសូមស្មានម្តងទៀត ពេលដែលវាយកប្រមាត់ទៅព្យួរនៅលើចង្ក្រានបាយ ខ្ញុំស្មានម៉ោងមិនហួសពីប្រាំបួនទេ។ ដូច្នេះអ្នកទោសមួយចំនួននៅក្នុងផ្ទះ ហើយអ្នកទោសមួយចំនួនត្រូវគេបញ្ចេញឲ្យទៅធ្វើពលកម្មនៅខាងក្រៅ។ រីឯចង្ក្រានបាយគឺមានសុទ្ធតែអ្នកដាំបាយពីរទៅបីនាក់ប៉ុណ្ណោះទេ។

[១៤:២៧:០៤]

**ស៖** សូមអរគុណ។ ចុះចំពោះលោកវិញ ដែលលោកឃើញដោយផ្ទាល់ហ្នឹង ថាតើលោកមានអារម្មណ៍យ៉ាងម៉េចដែរ នៅពេលដែលគេយកប្រមាត់ពីមនុស្សស្រីយកមកព្យួរឲ្យលោកមើលអ៊ីចឹង ចំពោះ

អារម្មណ៍របស់លោកយ៉ាងម៉េចដែរ? ហើយរឿងហ្នឹងត្រូវបានដឹងឮដល់អ្នកដទៃដែរឬក៏អត់ អ្នកទោសដទៃទៀតដែរឬក៏អត់?

**ឆ៖** បាទ រឿងហ្នឹងលាក់មិនជិតទេ ព្រោះស្រីៗដែលនៅចង្ក្រានបាយហ្នឹង និយាយតៗគ្នា ឮពេញកន្លែងសាលាកែប្រែហ្នឹង។

**ស៖** សូមអរគុណ។ ក្រោយពីរឿងហ្នឹងត្រូវបានខ្ចរខ្ចាយ ត្រូវបានឮដល់អ្នកដទៃ តើពួកគេដែលអ្នកទោសនៅក្នុងហ្នឹង គាត់មានអារម្មណ៍យ៉ាងម៉េចដែរទាក់ទងទៅនឹងបញ្ហាដែលមានការសម្លាប់ -- វះខ្ចងស្ត្រីយកប្រមាត់ដូចនេះ?

**ឆ៖** បាទ មើលទឹកមុខអ្នកដែលចូលទៅហូបបាយ ហើយអ្នកដែលនៅក្នុងចង្ក្រានហ្នឹង ហាក់ដូចជាមានភាពមួយ គឺថាក្តុកក្តួលក្នុងចិត្ត ហើយភិតភ័យនៅក្នុងខ្លួន។

**ស៖** សូមអរគុណ។ ខ្ញុំចង់សូមសួរលោកពាក់ព័ន្ធជាមួយរណ្តៅសាកសពវិញម្តង។ លោកបានលើកថា ក្រៅពី -- លោកបានឃើញរណ្តៅសាកសពបេ-៥២។ អ៊ីចឹងខ្ញុំចង់សូមសួរលោកថា តើលោកមានបានប្រទះឃើញរណ្តៅសាកសពផ្សេងទៀតដែរឬទេ ក្រៅពីរណ្តៅ បេ-៥២ហ្នឹង?

**ឆ៖** បាទ សូមជម្រាបជូនថា ខ្ញុំបានឃើញតែរណ្តៅមួយហ្នឹងទេ ប៉ុន្តែចំពោះសាកសពដទៃទៀតដែលស្លាប់ គឺភាគច្រើន ច្រើនយកទៅដាក់នៅក្នុងត្រង់សេជំនាន់សង្គ្រាម។

[១៤:២៩:២២]

**ស៖** សូមអរគុណ។ តើត្រង់សេដែលគេយក -- សាកសពដែលគេយកទៅដាក់នៅត្រង់សេជំនាន់សង្គ្រាមហ្នឹង តើត្រង់សេហ្នឹងមានចំនួនច្រើន ឬក៏តិច ឬក៏មានប៉ុន្មានដែរ ដែលលោកបានជួបប្រទះ?

**ឆ៖** បាទ ត្រង់សេនុ៎ង ជាមូលដ្ឋានកន្លែងទ័ពរបស់ លន់ នល់ ហៅថា ប៉េ.សេ.អូ គឺទីប្រចាំការរបស់វា។ អ៊ីចឹង គឺនៅក្នុងផ្ទះនីមួយៗសុទ្ធតែមានត្រង់សេដើម្បីការពារខ្លួន ហើយដល់តែពួកទាហាននេះរត់ចេញអស់ នៅក្រោមដើមខ្នុរហ្នឹង គឺភាគច្រើនត្រង់សេហ្នឹងតែម្តង។

**ស៖** ពាក់ព័ន្ធជាមួយនឹងស្ត្រី និងកុមារវិញ តើលោកមានដែលដឹង ឬក៏ឮអំពីការសម្លាប់ ឬក៏ការទុក្ខបុកម្នេញទៅលើស្ត្រី និងកុមារនៅក្នុងអូរកន្សែងហ្នឹងដែរឬទេ?

**ឆ៖** បាទការធ្វើការទារុណកម្មចំពោះស្ត្រី និងកុមារ ខ្ញុំមិនបានឃើញទេ។ ខ្ញុំបានគ្រាន់តែបានជម្រាបជូនខាងដើមអ៊ីចឹង ខ្ញុំគ្រាន់តែបានឃើញគេបណ្តើរ មានស្ត្រី ស្ត្រីមានផ្ទៃពោះ និងកុមារ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរសំណួរចុងក្រោយមួយពាក់ព័ន្ធជាមួយនឹងអំឡុងពេលដែលកងទ័ពវៀតណាមចូលមកដល់ណ៎ា។ លោកបាន -- ខ្ញុំចង់សូមសួរថា មុនពេល ឬក៏អំឡុងពេលដែលកងទ័ពវៀតណាមចូលមកដល់ហ្នឹង តើចំនួនអ្នកទោសនៅក្នុងអូរកន្សែងហ្នឹងមានប្រហែលជា -- នៅសេសសល់ប្រហែលជាប៉ុន្មាននាក់ដែរ?

[១៤:៣១:៣០]

**ឆ៖** បាទ មិនដឹងជាប៉ុន្មានទេ ព្រោះផ្ទះខ្លះយើងអត់ដឹង ផ្ទះខ្លះចំហ។ អ៊ីចឹងយើងដឹងតែផ្ទះចំហមួយផ្ទះបួនប្រាំនាក់ មួយផ្ទះបួនប្រាំនាក់។ រួចឯលី ឯផ្ទះដែលបិទ គឺយើងអត់បានដឹងទេ។ ប៉ុន្តែដល់ពេលប្រលែងចេញយប់ គឺបណ្ដោយ ក៏យើងមិនបានរាប់ដែរ ម្នាក់ៗគឺស្ទុះរួចខ្លួន ដើម្បីជីវិត។

**ស៖** សូមអរគុណ។ តាមការសង្កេតរបស់លោកហ្នឹង អ្នកដែលស្ទុះរត់ចេញរួចយកជីវិតហ្នឹង បើតាមការសង្កេតហ្នឹង តិចឬក៏ច្រើន ត្រឹមតែពីរបីនាក់ទេ ឬក៏យ៉ាងម៉េច?

**ឆ៖** ពេលដែលចេញហ្នឹង គឺមេសាលាកែប្រែហ្នឹង គឺឲ្យចេញផ្លូវច្រកតែមួយចំនួនតែ២០ជាងនាក់ ទៅ៣០នាក់។

**ស៖** តើចំនួន២០ ទៅ៣០នាក់ដែលចេញក្នុងច្រកតែមួយហ្នឹង ក្នុងពេលតែមួយ ឬក៏មានពេលវេលា ឬក៏ថ្ងៃ ឬក៏តែម្ដងហ្នឹង ឬក៏មានការបញ្ចេញផ្សេងៗ ខុសៗថ្ងៃគ្នាទៀត ពេលដែលមុនវៀតណាមមកដល់ភ្លាមៗហ្នឹង?

**ឆ៖** បាទចេញពេលតែមួយទេ គឺទៅទាំងក្រុមទាំងអស់គ្នាតែម្ដង។

**ស៖** សូមអរគុណ។ តើ ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិច ថាតើពេលដែលពួកគាត់ចាកចេញពីអូរកន្សែងទៅ មានហេតុការណ៍អ្វីកើតឡើងចំពោះពួកគាត់ដែរ ឬក៏យ៉ាងណាដែរលោក?

**ឆ៖** បាទ ពេលចេញដំណើរពីអូរកន្សែងនៅតាមផ្លូវទៅព្រំប្រទល់ខេត្តស្ទឹងត្រែង តាមកាត់ព្រៃនេះ នៅតាមដងផ្លូវមានបញ្ហាខ្លះៗ។ ឧទាហរណ៍ដូចជាអ្នកទោសដែលដើរមិនរួច អ្នកទោសដែលមានជំងឺ គេមិនឲ្យយកទៅទេ។

**ស៖** សូមអរគុណ។ អ្នកទោសដែលគាត់ដើរអត់រួច គេមិនឲ្យយកទៅហ្នឹង តើគេទុកគាត់នៅកន្លែងណា ឬមួយក៏គេមានវិធានការអីចំពោះពួកគាត់អត់?

[១៤:៣៤:១០]

**ឆ៖** បាទ មួយចំនួនគឺគេបោសសម្អាតតាមផ្លូវចោល។

**ស៖** សូមអរគុណ។ តើការបោសសម្អាតហ្នឹងមានន័យម៉េចលោក? នៅក្នុងខ្លឹមសាររបស់លោកចង់មានន័យ -- លោកចង់មានន័យដូចម្តេច?

**ឆ៖** បាទខ្ញុំចង់និយាយថា ការដើរមិនរួចនេះ គឺគេទុកចោលនឹងកន្លែង ហើយមួយចំនួនទៀតគឺគេកម្ទេចចោលទៅ។ ហើយដើរមិនរួចមួយចំនួនដែលហើមជើងហើមដៃអី អាហ្នឹងគេទុកចោលមួយកន្លែង គេដើរហួសទៅ។ គេអត់រង់ចាំ ព្រោះនិយាយរួមថា ពេលដែលកងទ័ពវៀតណាមចូលមកដល់ទឹកដីខេត្តរតនគិរីហើយ ទាំងអស់គ្នាភ័យស្លន់ស្លោ អ៊ីចឹងគេមិនរង់ចាំអ្នកជំងឺហ្នឹងទេ។

**ស៖** សូមអរគុណ។ ចុះចំពោះអ្នកដែលគេយកទៅជាមួយហ្នឹង អាចមានហេតុការណ៍អីកើតឡើងចំពោះគាត់ដែរ ឬក៏យ៉ាងម៉េចដែរ លោក?

**ឆ៖** បាទ ពេលទៅដល់មាត់ទន្លេ មាត់ទន្លេសេសាន មាត់ទន្លេសេកុង បានគេថា កងទ័ពវៀត-ណាមចេញពីខេត្តស្ទឹងត្រែង ទប់នៅកន្លែងហ្នឹង។ អ៊ីចឹងគឺទាំងទ័ព ទាំងសាលាកែប្រែ គឺរត់យកតែប្រាសអាយុ។ រីឯពួកខ្ញុំដែលទៅតាមវា ក៏រត់យកតែប្រាសអាយុដែរ គឺបែកគ្នាត្រឹមកន្លែងកងទ័ពបំបែក នៅកន្លែងទន្លេសេសានតែម្តង។

[១៤:៣៦:០៨]

**លោកស្រី ទី ស្រ៊ីនណា៖**

ខ្ញុំសូមអស់សំណួរ និងសូមថ្លែងអំណរគុណចំពោះការឆ្លើយដ៏ក្បោះក្បាយរបស់លោក។ សូមអរគុណ។ ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះក៏សមស្របសម្រាកដែលហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និង ឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី ខ្វះប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥៦នាទី)*

[១៤:៥៦:២៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី។ ដំបូងនេះ ផ្តល់ទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំសូមសួរបន្តនូវអ្វីដែលលោកបានឆ្លើយកាលពីព្រឹកមិញ គឺថ្ងៃដែលគេចាប់ខ្លួនលោក លោកថា គេចាប់ខ្លួននៅថ្ងៃទី១៦ ខែមិថុនា ៧៧។ ហើយលោកចាំកាលបរិច្ឆេទនេះច្បាស់លាស់មែនទែន។ សហព្រះរាជអាជ្ញារងក៏បានសួរលោក ឲ្យលោករៀបរាប់ថា ហេតុអ្វីបានជាលោកចាំថ្ងៃខែឆ្នាំគេចាប់លោកនេះច្បាស់លាស់ម្ល៉េះ។ ហើយខ្ញុំក៏សួរម្តងទៀតដែរ លោក ថាហេតុអីបានជាលោកចាំច្បាស់ម្ល៉េះ ថាគេចាប់ខ្លួនលោកនៅចំថ្ងៃទី១៦ មិថុនា ៧៧?

[១៤:៥៨:១៦]

**លោក ផន ថុល៖**

**ឆ៖** បាទ សូមជម្រាបជូនថា ខ្ញុំធ្វើការនៅក្នុងសហជីពនេះ គឺថ្ងៃខែ គឺខ្ញុំចាំរហូត។ ដូច្នេះអ្វីដែលគេធ្វើមកលើរូបខ្ញុំ គឺខ្ញុំនៅតែចងចាំរហូតមកដល់ថ្ងៃនេះ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺគេចាប់ខ្លួនលោកហ្នឹង មួយថ្ងៃបន្ទាប់ពីថ្ងៃកំណើតរបស់លោក ដោយសារហេតុផលនេះឬ ដែលលោកចាំថ្ងៃខែឆ្នាំដែលគេចាប់លោកច្បាស់លាស់យ៉ាងហ្នឹង ឬក៏មានហេតុផលផ្សេង?

**ឆ៖** បាទ មិនមានអីផ្សេងទេ គឺខ្ញុំចាំខ្លួនខ្ញុំច្បាស់លាស់ នៅក្នុងអារម្មណ៍របស់ខ្ញុំ គឺខ្ញុំចាំជាប់នឹងថ្ងៃហ្នឹងតែម្តង។

**ស៖** សូមអរគុណលោកសាក្សី។ គេបានចាប់ខ្លួនលោកនៅថ្ងៃទី១៦ មិថុនា ៧៧ តើគេបានសួរ<ចម្លើយ>លោកប៉ុន្មាន<ម៉ោង> ឬក៏ប៉ុន្មានថ្ងៃដែរ លោកនៅចាំទេ?

**ឆ៖** បាទ សូមជម្រាបជូនថា គេសួរខ្ញុំបានតែម្តងទេ ហើយក្នុងពេលសួរនេះគឺរយៈពេលប្រហែលជា៣០នាទីតែប៉ុណ្ណឹង។

**ស៖** ហើយនៅថ្ងៃ១៧, ១៨ មិថុនា ៧៧ ហ្នឹងគេមានសួរចម្លើយលោកទេ លោកចាំទេ?

[១៥:០០:១៤]

**ឆ៖** បាទ សូមជម្រាបថា ពេលដែលគេយកទៅភ្លាម គឺគេអត់សួរចម្លើយទេ គឺគេយកទៅដាក់ច្រវាក់ពីរទៅបីថ្ងៃបានគេសួរចម្លើយ។ គេយកខ្ញុំទៅសួរចម្លើយ។

**ស៖** ហើយក្រោយពេលគេសួរលោកប្រហែលជាកន្លះម៉ោង ៣០នាទីហ្នឹង គេក៏បានបញ្ជូនលោកទៅបន្ទប់ឃុំខ្លួនលោកវិញ។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ចុះប្រពន្ធរបស់លោកវិញ លោកដឹងថា គេមានសួរចម្លើយប្រពន្ធលោកហ្នឹង នៅថ្ងៃតែមួយដែលគេសួរចម្លើយលោកហ្នឹងដែរ ឬក៏យ៉ាងណា?

**ឆ៖** បាទ សំណួរនេះហាក់ដូចជាច្រំដែល ខ្ញុំបានជម្រាបពីព្រឹកហើយថា រវាងប្តីនិងប្រពន្ធ មិនអាចដឹងរឿងរ៉ាវពីគ្នាទៅវិញទៅមកបានទេ។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែនៅពេលនោះ ក្រោយមកប្រហែលជាប្រពន្ធរបស់លោកធ្លាប់បានប្រាប់លោក អ៊ីចឹងហើយបានជាខ្ញុំសួរសំណួរនេះឡើងវិញ។ អ៊ីចឹងលោកមិនដឹងទេ អំពីការសួរចម្លើយប្រពន្ធរបស់លោក?

**ឆ៖** បាទ ខ្ញុំអត់បានដឹងផង។

[១៥:០១:៥៤]

**ស៖** នៅពេលដែលគេសួរចម្លើយលោក តើមានអ្វីកើតឡើងបន្តមកទៀត គេបញ្ជូនលោកឲ្យចេញទៅធ្វើការ<ភ្លាមៗ> ឬក៏គេឃុំខ្លួនយើងមួយរយៈសិន?

**ឆ៖** បាទ ក្រោយពេលសួរចម្លើយរួច គេមិនឲ្យទៅធ្វើការភ្លាមទេ គឺគេយកទៅដាក់កន្លែង

ដដែលវិញ អស់មួយរយៈសិន។

**សៈ** ខ្ញុំសូមអានសម្រង់មួយដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5172 ERNជាភាសាអង់គ្លេស 00272588, ខ្មែរ 00189255 និងបារាំង 00272595។ លោកបានឆ្លើយប្រាប់មន្ត្រីស៊ើបអង្កេតដូចតទៅ៖ “សម្រាប់ខ្ញុំនៅពេលដែលខ្ញុំនៅក្នុងពន្ធនាគារ២ឆ្នាំ គឺខ្ញុំមិនដែលធ្វើអ្វីឲ្យខុសវិន័យនោះទេ។ គេបានដាក់គុកខ្ញុំ ឃុំឃាំងខ្ញុំប្រហែលជាមួយខែ <ពេលហ្នឹងគេដាក់ខ្នោះខ្ញុំក្នុងគុក> ហើយគេមិនឲ្យខ្ញុំចេញមកខាងក្រៅបន្ទប់ឃុំឃាំងទេ។ ពីរទៅបីខែក្រោយមក ទើបគេឈប់ដាក់ច្រវាក់ខ្ញុំ ឲ្យខ្ញុំដេកធម្មតា ព្រោះខ្ញុំមិនធ្វើសកម្មភាពអ្វីទេ។” តើលោកនៅនឹកឃើញទេថា គេបានឃុំឃាំងលោក<ដោយដាក់ខ្នោះ>ហ្នឹងមួយខែ ហើយពីរបីខែក្រោយមក គេឈប់ឃុំឃាំងខ្លួនលោកហ្នឹង<ដោយដាក់ខ្នោះ>នៅក្នុងពន្ធនាគារនោះទៀតហើយ អ៊ីចឹងមែនទេ?

**ឆៈ** បាទ ខ្ញុំសូមជម្រាបជូនថា វិន័យនៅក្នុងសាលាកែប្រែ គេប្រាប់យើងហើយ ទី១ កុំរត់, ទី២ កុំលួច កុំធ្វើសកម្មភាពអ្វីដែលខុសពីការណែនាំរបស់គេ។ អ៊ីចឹងខ្លួនខ្ញុំ គឺខ្ញុំអត់ធ្វើអ្វីឲ្យខុសពីបទបញ្ជាផ្ទៃក្នុងរបស់សាលាកែប្រែទេ។ ហើយក្រោយមកបានគេដោះលែងខ្ញុំ ឲ្យខ្ញុំចេញធ្វើពលកម្មនៅខាងក្រៅ ដូចអ្នកទោសធម្មតាដែលគេជាប់មុនខ្ញុំ។

**សៈ** ខ្ញុំសូមសួរលោក តាមរបៀបផ្សេងវិញ។ នៅពេលណាដែលគេបញ្ជាឲ្យលោកចេញទៅធ្វើការនៅក្នុងបរិវេណមន្ទីរអប់រំកែប្រែអូរកន្សែង? នៅពេលណាដែលគេដោះខ្នោះលោកចេញ គេឲ្យលោកចេញទៅធ្វើការនៅខាងក្រៅនោះ?

[១៥:០៤:៥៣]

**ឆៈ** បាទ ខ្ញុំអត់បានចាំថ្ងៃទេ ប៉ុន្តែគ្រាន់តែចាំថា ក្រោយពេលដែលគេបានសួរចម្លើយខ្ញុំរួច គេទុកខ្ញុំមួយរយៈ។ រួចហើយអស់មួយរយៈ យើងមិនដឹងថាប៉ុន្មានខែទេ គេបានបញ្ចេញខ្ញុំឲ្យធ្វើពលកម្មដកស្មៅ ដាំដំឡូង។ ពេលថ្ងៃចេញក្រៅ ពេលយប់គេយកមកដាក់នៅកន្លែងដដែលវិញ។

**សៈ** តើ<>ប្រពន្ធរបស់លោក ហើយនិងលោកហ្នឹង គេដោះខ្នោះឃ្នាងហ្នឹងចេញនៅពេលដំណាលគ្នា ប្រហាក់ប្រហែលគ្នាដែរ ឬក៏យ៉ាងណា?

**ឆៈ** បាទ សូមជម្រាបថា ផ្នែកនារីគេអត់មានដាក់ទេនៅសាលាកែប្រែអូរកន្សែង។ គេដាក់តែបុរសទេ។ គេគ្រាន់ថាឲ្យនារីដេកដោយឡែក មានផ្ទះនារី ឯបុរសនៅផ្ទះដោយឡែក ហើយគេដាក់ខ្នោះនិងដាក់ច្រវាក់។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែមានពេលមួយគេបានបញ្ជាឲ្យលោកចេញទៅធ្វើការ ដូចជាដាំដំឡូងជាដើមនៅក្នុងបរិវេណ<នោះ> តើលោកចេញទៅធ្វើការនៅក្នុងបរិវេណមន្ទីរឃុំឃាំងនេះពេលដំណាលគ្នា ឬក៏ប្រហាក់ប្រហែលគ្នានឹងប្រពន្ធលោកដែរ ឬក៏យ៉ាងណា?

**ឆ៖** បាទ សូមជម្រាបថា ផ្នែកនារីមានភាពធូរស្រាលជាងបុរស គឺពេលទៅដល់អ៊ីចឹង គេអត់មានដាក់ខ្នោះដាក់ច្រវាក់អីទេ គេឲ្យនៅក្នុងផ្ទះពីរទៅបីថ្ងៃ គេឲ្យជម្រះស្មៅធម្មតានៅជុំ -- នៅក្នុងបរិវេណសាលាឃុំឃាំងហ្នឹងតែម្ដង។

[១៥:០៧:១៩]

**ស៖** ខ្ញុំនឹងត្រឡប់មកសួរលោកបន្ថែមទៀតអំពីកិច្ចការនៅក្នុងបរិវេណមន្ទីរសន្តិសុខនេះ។ ឥឡូវនេះខ្ញុំសូមចូលទៅនិយាយពីពេលវេលា ដែលលោកបានឃើញជនជាតិចារ៉ាយតាមប្រហោងជញ្ជាំងអគារផ្ទះដែលគេឃុំឃាំងលោកហ្នឹង។ តើលោកបានឃើញជនជាតិចារ៉ាយហ្នឹងក្នុងរយៈប៉ុន្មានថ្ងៃ ឬក៏ក្នុងរយៈពេលប៉ុន្មានសប្ដាហ៍ ឬក៏ប៉ុន្មានខែ ទើបបានឃើញជនជាតិចារ៉ាយដែលយកទៅឃុំខ្លួនដែរហ្នឹងនេះបើគិតពីថ្ងៃទី១៦ ខែមិថុនា ៧៧ ពេលដែលគេចាំខ្លួនលោកចូលទៅដល់មន្ទីរឃុំឃាំងលើកដំបូងហ្នឹង?

**ឆ៖** សូមជម្រាបថា ខ្ញុំអត់គិតដល់ដំណាក់ហ្នឹងទេ អត់គិតរឿងថ្ងៃខែ ឬម៉ោងណាទេ ខ្ញុំគ្រាន់តែដឹងថា ពេលដែលខ្ញុំចូលទៅដល់មុន ហើយក៏មិនដឹងប៉ុន្មានថ្ងៃដែរ ក៏ឃើញគេនាំជនជាតិចារ៉ាយហ្នឹងចូលទៅតាមក្រោយ ដាក់ឡានទម្លាក់នៅខាងមុខផ្ទះដែលខ្ញុំគេដាក់ច្រវាក់ហ្នឹង។

**ស៖** ខ្ញុំយល់ហើយ ថាលោកពិបាកនឹងចាំថារយៈពេលប៉ុន្មានថ្ងៃ គិតពីពេលនេះទៅពេលនោះ ក៏ប៉ុន្តែថាតើ<>វានៅថ្ងៃតែមួយ ឬក៏មួយថ្ងៃក្រោយមក ឬក៏ប៉ុន្មានខែក្រោយមកទើបបានលោកឃើញជនជាតិចារ៉ាយហ្នឹង គិតពីពេលគេចាប់ខ្លួនលោកហ្នឹង លោកយល់សំណួរខ្ញុំទេ?

**ឆ៖** បាទ យល់។ ប្រមាណជាជិតមួយខែ បានជនជាតិចារ៉ាយចូលមកក្នុងកន្លែងទីឃុំឃាំងក្រោយខ្ញុំ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីជនជាតិចារ៉ាយហ្នឹងនៅពេលបន្តិចទៀតនេះ។ ឥឡូវនេះខ្ញុំសួរអំពីការសួរចម្លើយរបស់លោក។ លោកបានឆ្លើយជូនសហព្រះរាជអាជ្ញារងថា លោកត្រូវបានគេសួរលោកអំពីវិធីសាស្ត្រប្រើប្រាស់នៅឯចម្ការកៅស៊ូ។ តើគេមានសួរលោកអំពីសកម្មភាពផ្សេងទៀត គឺពាក់ព័ន្ធទៅនឹង "ឃ្មួន" សកម្មភាពឃ្មួន នៅក្នុងចម្ការកៅស៊ូនោះដែរទេ?

[១៥:១០:១៦]

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ខ្ញុំចម្លើយនៅដដែលៗទេ។ គេមិនសួរពីសកម្មភាពអីទេ។ គេចោទខ្ញុំថា ខ្ញុំប្រើបច្ចេកទេសរបស់សក្តិភូមិ យើងមិនប្រើបច្ចេកទេសរបស់កសិករ តែប៉ុណ្ណឹងទេ។ បានគេយកខ្ញុំទៅកែប្រែនៅសាលាហ្នឹង។

**ស៖** ប្រពន្ធមុនរបស់លោកហ្នឹង ក៏បានឆ្លើយជូនមន្ត្រីស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃផងដែរគឺ E3/9357។ នៅក្នុងសំណួរចម្លើយលេខ៤ គាត់បានឆ្លើយដូចតទៅនេះ ខ្ញុំនឹងអានឱ្យលោកស្តាប់៖ "ពួកគេបានហៅយើងទៅសួរចម្លើយម្តងម្នាក់ៗ គេសួរខ្ញុំថា តើស្រុកកំណើតខ្ញុំនៅឯណា? ហើយគេបានសង្កត់ធ្ងន់សួរថា តើខ្ញុំមានទំនាក់ទំនងអ្វីជាមួយយួន ឬក៏អត់? ខ្ញុំបានឆ្លើយថា ខ្ញុំមិនដែលទាក់ទងអ្វីជាមួយយួនទេ។" តើភរិយាមុនរបស់លោកមានបានប្រាប់លោកថា គេសួរចម្លើយគាត់ថា មានទាក់ទងអីជាមួយនឹងយួនដែរឬទេ? គាត់មានប្រាប់លោកទេ?

**ឆ៖** បាទ អត់មានទេ។ ក្រោយគេសួរចម្លើយគាត់ ខ្ញុំក៏អត់ដឹងថា គេសួរចម្លើយពីរឿងអីដែរ ហើយគាត់ក៏មិនដែលបានប្រាប់ខ្ញុំដែរ ព្រោះយើងអត់បានជួបគ្នា។

**ស៖** ខ្ញុំចង់សួរបញ្ជាក់ឱ្យបានច្បាស់លាស់ ដោយអានចម្លើយរបស់គាត់។ អ៊ីចឹងពេលដែលខ្ញុំអានសម្រង់នេះ នៅពេលដែលគេសួរប្រពន្ធមុនរបស់លោកហ្នឹងថា មានទំនាក់ទំនងអីជាមួយនឹងយួនអ៊ីចឹងឯលោកវិញ តើគេមានសួរថា<>លោកមានទំនាក់ទំនងអីជាមួយនឹងយួន ដូចគាត់ដែរឬទេ?

[១៥:១២:៤២]

**ឆ៖** បាទ នេះជាសំណួរច្រំដែល ខ្ញុំប្រាប់ហើយប្រាប់ទៀតថា គេអត់មានសួរខ្ញុំពីរឿងយួន រឿងចិនអីទេ។ គេនិយាយតែពីរឿងបច្ចេកទេសតែប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមបង្ហាញជូនឯកសារនូវឯកសារដែលសាក្សីគាត់មិនធ្លាប់បានដឹង គឺឯកសារ E3/240។ ឯកសារនេះមានតែពីរទំព័រទេ។ ទំព័រជាភាសាខ្មែរ00001266 ដល់67, បារាំង00282550 ដល់ 51, អង់គ្លេស 00897667-8។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណលោកប្រធាន។ ដើម្បីឲ្យបានច្បាស់លាស់ តើលោកអាចជម្រាបបានទេថាឯកសារហ្នឹងជាចម្លើយសារភាពមកពីស-២១ មែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកចៅក្រម ឡាវែន៍ មិនមែន។ នេះគឺជាសារទូរលេខ ដែលផ្ញើនៅថ្ងៃទី១៥ មិថុនា ៧៧ ផ្ញើចេញពីមនុស្សម្នាក់ឈ្មោះ វី។ សារទូរលេខនេះមិនដឹងថាផ្ញើទៅឲ្យអ្នកណាទេ។ តែឯកសារនេះ និយាយអំពីការចាប់ខ្លួនជនជាតិចារ៉ាយមួយក្រុមនៅឯភូមិភាគឦសាន។ អ៊ីចឹងឯងបានជាខ្ញុំសុំបង្ហាញឯកសារនេះ ឲ្យសាក្សីមើល។

[១៥:១៤:៥៧]

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំមិនជំទាស់ទៅនឹងឯកសារនេះទេ ក៏ប៉ុន្តែ<ខ្ញុំចង់>បញ្ជាក់ថា មេធាវីការពារក្ដីថា មិនដឹងផ្ញើជូនទៅអ្នកណាទេ សារទូរលេខនេះ។ ក៏ប៉ុន្តែនៅចុងក្រោយនេះ មានចម្លងជូនថា អ៊ំ, អ៊ំនួន, <> បងវន, បងខៀវ។ <នេះដើម្បីកំណត់ត្រាប្រតិចារឹក>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនជំទាស់ទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញារងនេះទេ។ ដូច្នេះលោកប្រធាន តើអនុញ្ញាតឲ្យខ្ញុំបង្ហាញឯកសារនេះ ជូនទៅសាក្សីមើលទេ?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

*(សាក្សីកំពុងពិនិត្យមើលឯកសារ)*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកមានបានពិនិត្យមើលឯកសារនេះហើយឬនៅ? ខ្ញុំសូមសួរលោកនៅត្រង់ទំព័រទី២ ត្រង់ចំណុចលេខ២។ ខ្ញុំនឹងអានឲ្យលោកស្ដាប់។ ខ្ញុំអានជាភាសាអង់គ្លេស ដែលឯកសារនេះ គឺនិយាយដូចតទៅ៖ “គេបានសម្រេចថា សមមិត្ត <ធី> ត្រូវចាត់វិធានការ<ដោយសម្ងាត់>ចំពោះ<ពួកអាបង្កប់>ស៊ីរូងផ្ទៃក្នុង នៅចម្ការកៅស៊ូ ក៏ដូចជា<កងចល័ត ដែលដកពីយោធា>ពីឆ្នាំ៧៤។ បណ្ដាញនេះរួមមាន ១)គឺជាខ្សែរបស់ អាសួណា <មួយចំនួនដែលទាក់ទង> អាអ៊ិន តាំ <និង> អាចេង ហេង។ <២)> អ្នកមកពីស្ទឹងត្រែង។ ៣) គឺខ្សែ ឡុង ដែលទាក់ទង អាកែវ មកពីហាណូយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទី៤) ខ្សែពួក អាថយ។ ៥) ខ្សែ តាមចម្លើយ អាលូ ខាង១០៧។” ដូច្នេះសំណួររបស់ខ្ញុំសួរ ចំពោះនឹងលេខ៣ គឺខ្សែ ឡុង ដែលទាក់ទងជាមួយ អាកែវ មកពីហាណូយ។ តើឈ្មោះ ឡុង នេះលោកធ្លាប់ដែលឮ ធ្លាប់ដែលស្គាល់ដែរទេ?

[១៥:១៩:១៩]

**លោក ផន ថុល៖**

**ផ៖** សូមជម្រាបថា អ្វីដែលលោកមានប្រសាសន៍ ខ្ញុំអត់យល់ទាំងអស់ ព្រោះខ្ញុំអត់មានការពាក់ព័ន្ធស្អីចូលក្នុងហ្នឹងទេ។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី ដែលថាលោកមិនដឹងអំពីឯកសារនេះទេ តែសំណួរខ្ញុំសួរថា តើលោកធ្លាប់ឮមនុស្សម្នាក់ឈ្មោះ ឡុង នៅចំចំណុចលេខ៣នេះ ដែលថាខ្សែ ឡុង ទាក់ទងជាមួយ អាកែវ មកពីហាណូយនេះ?

**ផ៖** បាទ អត់ដែរផង អត់ដែលស្គាល់ឈ្មោះ ឡុង ហ្នឹងផង។

**ស៖** ចុះឈ្មោះទី២ នៅបន្ទាត់ទី៣នេះ ឈ្មោះ កែវ មកពីហាណូយ លោកធ្លាប់ដែលឮមនុស្ស<>ម្នាក់ឈ្មោះ កែវ មកពីហាណូយនុ៎ងដែរទេ?

**ផ៖** បាទ កែវ ហ្នឹងក៏មិនដែលឮដែរ ព្រោះខ្ញុំកំពុងចាប់អារម្មណ៍ថា អ្នកណាដែលមកពីហាណូយហ្នឹងឈ្មោះអីខ្លះហ្នឹង វាៗឈ្មោះ កែវ ឈ្មោះ ឡុង ហ្នឹងខ្ញុំអត់ដែលបានឮទេ។

**ស៖** តើនៅពេលនោះ គឺពីឆ្នាំ៧៥ ដល់៧៦ ដឹងថា តើលោកដឹងថា ពីឆ្នាំ៧៥ទៅ៧៦ អ្នកណាជាមេភូមិភាគឦសានដែរទេ?

**ផ៖** និយាយរួមថា ខ្ញុំរស់នៅអត់គិតគូរដល់ថ្នាក់នុ៎ងផង។ អត់មានគិតគូរថា អ្នកនេះភូមិភាគអ្នកនេះថ្នាក់តំបន់ អត់មានគិតគូរ។ គិតគូរតែពីព្រឹកទៅធ្វើស្រែ ល្ងាចឡើងមកផ្ទះវិញ។

**ស៖** ចុះតើលោកធ្លាប់ឮឈ្មោះសមមិត្ត យ៉ា ដែរទេ ឬក៏<ឈ្មោះពិតគឺ> ណៃ សារ៉ាន់ ធ្លាប់ឮទេ?

**ផ៖** បាទបើឈ្មោះ យ៉ា ខ្ញុំដែលឮ ប៉ុន្តែមិនដែលជួបគ្នា តែ ណៃ សារ៉ាន់ ខ្ញុំអត់ដែលទេ។ អ៊ីចឹងឈ្មោះ យ៉ា គឺធ្លាប់ឮតែឈ្មោះ តែមិនដឹងមនុស្សនៅឯណា។

[១៥:២៣:០៣]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវហ្នឹងខ្ញុំត្រឡប់ទៅអ្វីដែលលោកទើបនឹងឆ្លើយ។ លោក

ជឿជាក់ថា ប្រហែលមួយខែក្រោយពីពេលគេចាប់ខ្លួនលោក លោកក៏បានឃើញជនជាតិចារ៉ាយមួយក្រុមនៅក្នុងបរិវេណមន្ទីរសន្តិសុខអូរកន្សែង។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ អាហ្នឹងវាជារឿងពិត។

**ស៖** តើឲ្យជាក់លាក់មែនទែនទៅ នៅពេលណាដែរដែលលោកបានឃើញរណ្តៅជាមួយនឹងសាកសពហើមស្អុយនៅក្នុងចម្ការខ្នុរ ហើយ<និងសម្ភារៈប្រើប្រាស់ ឬខោអាវ>ដែលលោកគិតថា អាចជាសាកសពរបស់ជនជាតិចារ៉ាយទាំងនេះហើយ? តើពេលដែលលោកឃើញហ្នឹង ឃើញនៅពេលណា?

**ឆ៖** សូមជម្រាបថា ឃើញនៅពេលដែលខ្ញុំទៅធ្វើការនៅចម្ការខ្នុរ។

**ស៖** តើលោកចាប់ផ្តើមធ្វើការនៅក្នុងចម្ការខ្នុរនុ៎ងពេលណា មកពីពេលណាមក?

**ឆ៖** នៅពេលដែលគេឲ្យខ្ញុំចេញទៅធ្វើការនៅខាងក្រៅ ក្រោយពីបោចស្មៅ ដាំដំឡូង ដាំពោតរួចហើយ គឺគេឲ្យខ្ញុំទៅយាមនៅចម្ការខ្នុរ ដើម្បីកុំឲ្យប្រជាពលរដ្ឋចូលនៅក្នុងបរិវេណចម្ការខ្នុរហ្នឹង។

**ស៖** ឥឡូវខ្ញុំសួរលោកតាមរបៀបផ្សេងវិញ។ តើរយៈពេលប៉ុន្មាន ចាប់ពីពេលដែលលោកឃើញជនជាតិចារ៉ាយនៅមន្ទីរសន្តិសុខអូរកន្សែង ទៅដល់ពេលដែលលោកឃើញ<សាកសពស្អុយហើម>នៅក្នុងចម្ការខ្នុរនុ៎ង? គឺខ្ញុំសួរចាប់ពីពេលដែលលោកបានឃើញជនជាតិចារ៉ាយមួយក្រុម នៅក្នុងមន្ទីរសន្តិសុខអូរកន្សែង និងពេលដែលលោកបានឃើញ<>សាកសពស្អុយហើមនៅក្នុងចម្ការខ្នុរ?

**ឆ៖** បាទ បើតាមខ្ញុំស្មានក្នុងខ្លួនខ្ញុំ ថាមិនហួសពីមួយអាទិត្យទេ។

[១៥:២៥:០៤]

**ស៖** តើលោកអាចជម្រាបប្រាប់ខ្ញុំបន្តិចបានទេថា ដោយយោងទៅលើចម្លើយរបស់លោក ថាលោកត្រូវបានគេដាក់គុកប្រហែលជាមួយខែ ដាក់ខ្នោះឃ្នាងប្រហែលមួយខែ។ ហើយបន្ទាប់មក គេក៏ឈប់ដាក់ខ្នោះលោកទៅ រយៈពេលពីរបីខែ<>។ ហើយនៅក្នុងចម្លើយដដែលនេះ លោកឆ្លើយថា រហូតទៅដល់ជិតរំដោះ<ឆ្នាំ៧៩> ទើបបានគេឲ្យលោកដេកនៅខាងក្រៅ<កន្លែងឃុំខ្លួន> អត់ដាក់ខ្នោះឃ្នាងទេ <និងអត់បានចាក់សោពីខាងក្រៅទេ>។ ខ្ញុំ<>នៅតែមិនយល់ថា <តើវាអាចទៅរួចដោយរបៀបណា ដែលលោក>ឃើញ<>សាកសព<ស្អុយហើមទាំងអស់>ហ្នឹង គឺមានរយៈពេល<មួយខែ និង>មួយអាទិត្យ <ក្រោយពីការចាប់ខ្លួនរបស់លោក>ហ្នឹង។ សូមលោកពន្យល់កន្លែងហ្នឹងឲ្យលម្អិតបន្តិចបានទេ។

**ឆ៖** បាទ សូមជម្រាបថា ពេលដែលខ្ញុំឃើញជនជាតិចារ៉ាយគេនាំចុះពីឡានហ្នឹង ហើយគេ

យកចេញទៅ បានបួនប្រាំថ្ងៃ គេយកចេញទៅ មិនហួសពីមួយអាទិត្យទេ ខ្ញុំទៅចម្ការខ្នុរហ្នឹង ក៏ឃើញដីហ្នឹង ហើមតែម្តងទៅ។

**ស៖** ឯកសារដែលខ្ញុំទើបតែបង្ហាញលោកនេះ បើទោះណាជាលោកមិនដែលធ្លាប់បានឃើញឯកសារនេះក្តី ក៏ឯកសារនេះបាននិយាយអំពីថា ឯកសារនេះបានរាយការណ៍ថាមាន<កងទ័ព>វៀតណាម<មួយក្រុម ដែលមាន>ប្រហែលជា២០៩នាក់ រួមទាំងជនជាតិចារ៉ាយ<ជាច្រើនផង ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៤ ខែមិថុនា។ ខ្ញុំមិនដឹងថាវាត្រឹមត្រូវ ឬក៏អត់ទេ ប៉ុន្តែ>ប្រហែលជា<ក្រុម>ជនជាតិចារ៉ាយ<តែមួយ ដែលលោកកំពុងតែនិយាយ>។ តើហេតុអ្វីបានជាលោកបានឃើញ<សាកសពជនជាតិចារ៉ាយហ្នឹងលឿន>ម្ល៉េះ <ក្រោយការចាប់ខ្លួនរបស់លោក> ពីព្រោះថា<>នៅពេលហ្នឹងគឺថា គេកំពុងតែដាក់ខ្នោះជើងលោកនៅឡើយហ្នឹង?

[១៥:២៧:៤១]

**ឆ៖** បាទ នេះជាសំណួរច្រំដែល។ ខ្ញុំបាទបានប្រាប់ពីព្រឹកហើយ ខ្ញុំថាខ្ញុំមើលតាមជញ្ជាំង។ រីឯដាក់អ្នកទោសនៅក្នុងសាលាកែប្រែរបស់អូរកន្សែងនេះ មិនមែនជាផ្ទះថ្ម ឬផ្ទះក្តារទេ ផ្ទះឫស្សី ហើយឫស្សីនោះវាបែកទៅទៀត វាបាក់ទៅទៀត វាពុកទៅទៀត អ៊ីចឹងយើងមើលគ្នាឃើញ ក៏ប៉ុន្តែវាគ្រាន់តែមិនប៊ានិយាយគ្នា ចោទឆ្លើយគ្នា ប៉ុន្តែអាចមើលឃើញទាំងអស់ ជុំវិញបរិវេណខ្លួនឯងដែលនៅហ្នឹងផ្ទះហ្នឹង។

**ស៖** អ៊ីចឹងខ្ញុំសួរលោកតាមរបៀបផ្សេងវិញ។ តើវាអាចទេ ដែលថាពេលដែលលោកឃើញដីហើមនៅកប់សាកសពនៅក្នុងចម្ការខ្នុរហ្នឹង អាចថារហូតដល់ជិតដំណាច់ឆ្នាំ១៩៧៨ ឯណោះ? អ៊ីចឹងបើខ្ញុំយល់ថាអ៊ីចឹង ត្រឹមត្រូវដែរ ឬក៏អត់ទេ?

**ឆ៖** សំណួរនេះ ខ្ញុំមិនដឹងជាឆ្នាំណាទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែជម្រាបជូនថា ក្រោយពីឃើញជនជាតិចារ៉ាយចុះហើយ ប្រហែលជាមិនដល់មួយអាទិត្យផង ស្រាប់តែបាត់ជនជាតិហ្នឹងអស់។ ក្រោយមកទៀត ខ្ញុំទៅធ្វើការនៅចម្ការខ្នុរ ស្រាប់តែឃើញដីហ្នឹងហើម ហើយសម្លៀកបំពាក់ ព្រមទាំងពិល ហើយនិងស្បែកជើង ឈាមនៅប្រលាក់ខោអាវ។

**ស៖** តើលោកធ្លាប់ដែលឮអ្នកយាមមន្ទីរសន្តិសុខនិយាយអំពីកាំភ្លើងខ្លី កាំភ្លើងវែង គ្រាប់បែក <ដែរ> ត្រូវបានរកឃើញពីក្នុងចំណោមជនជាតិចារ៉ាយ ដែល<លោកបានឃើញនោះដែរឬទេ>?

**ឆ៖** បាទ អត់បានទេ អត់បានឮទេ។

[១៥:២៩:៤១]

**ស៖** ឥឡូវនេះខ្ញុំសូមចូលទៅប្រធានបទថ្មីមួយទៀត ដែលនៅពេលមួយនោះលោកបានឆ្លើយថា លោកត្រូវបានអ្នកធ្វើការនៅមន្ទីរសន្តិសុខអូរកន្សែងទុកចិត្តលោក។ តើបុគ្គលិកមន្ទីរសន្តិសុខអូរកន្សែងហ្នឹងគេទុកចិត្តលោកហ្នឹង គឺចាប់ទុកចិត្តលោកពីពេលណាមក? ហើយគេប្រាប់លោកហ្នឹងនៅពេលណាមកដែរ?

**ឆ៖** បាទ សូមជម្រាបថាគេមិនប្រាប់ខ្ញុំទេ គេនិយាយប៉ុន្តែខ្ញុំឮ ហើយគេទុកចិត្តខ្ញុំគឺខ្ញុំសូមជម្រាបដដែលៗថា មកពីខ្ញុំមិនធ្វើសកម្មភាពអ្វីដែលគេប្រាប់គឺយើងមិនធ្វើ នេះហើយគេទុកចិត្តខ្ញុំ។ បើសិនជាខ្ញុំធ្វើខុសពីបទបញ្ជាផ្ទៃក្នុងរបស់សាលាកែប្រែ ខ្ញុំអត់បាននៅដល់ថ្ងៃនេះទេ។

**ស៖** ខ្ញុំយល់ហើយនៅខាងក្រៅបន្ទប់ឃុំឃាំងហ្នឹង ប៉ុន្តែគឺៗគេចាប់ទុកចិត្តលោកហ្នឹងតាំងពីពេលដែលលោកនៅក្នុងបរិវេណអូរកន្សែងឯណោះ។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ អូរកន្សែង និងកន្លែងឃុំឃាំងហ្នឹង អូរកន្សែងវាជាឈ្មោះ ប៉ុន្តែអាកន្លែងឃុំឃាំងហ្នឹងវាជាទីតាំង អ៊ីចឹងទីតាំងហ្នឹងវានៅក្នុងអាអូរកន្សែងហ្នឹងតែម្ដង សូមជម្រាបជូន។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ បរិវេណមន្ទីរសន្តិសុខអូរកន្សែងហ្នឹងមានទំហំ២០០ម៉ែត្របួនជ្រុងអាចធំជាងទីលានបាល់ទាត់ពីរដងកន្លះ។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងជាប៉ុន្មានម៉ែត្រទេ ប៉ុន្តែថាគ្រាន់តែវាធ្វើរបងពីឫស្សី ហើយនិងដាក់ចម្រូងខ្នារហ្នឹង គឺមិនដឹងជាប៉ុន្មានម៉ែត្រទេ វាធ្វើបួនជ្រុងហ្នឹង ប៉ុន្តែឲ្យដឹងចំនួនម៉ែត្រ គឺខ្ញុំមិនដឹងថាជាប៉ុន្មានម៉ែត្រទេ។

[១៥:៣២:១១]

**ស៖** នៅពេលមួយនោះ គឺថាគេឈប់ដាក់ខ្នោះលោកទៀតហើយ គេអនុញ្ញាតចេញធ្វើការនៅក្នុងបរិវេណនោះ។ តើលោកបានធ្វើការនៅក្នុងបរិវេណអូរកន្សែងនោះអស់រយៈពេលប៉ុន្មានដែរ មុនពេលដែលគេអនុញ្ញាតឲ្យលោកចេញទៅធ្វើការ<២គីឡូម៉ែត្រ>នៅខាងក្រៅ គឺនៅចម្ការខ្នុរ?

**ឆ៖** បាទ ខ្ញុំមិនដឹងជាប៉ុន្មានដែរ ប៉ុន្តែថាពេលដែលខ្ញុំគេដោះពីច្រវាក់ចាក់សោរចេញហ្នឹង គេឲ្យធ្វើនៅខាងក្នុងមួយរយៈ។ រួចហើយធ្វើខាងក្នុងហើយ បានគេឲ្យខ្ញុំចេញទៅខាងក្រៅ ដាំដំឡូង ដាំពោត ហើយនិងយាមចម្ការខ្នុរ។

**ស៖** តើនៅពេលណាដែលគេអនុញ្ញាតឲ្យលោកចេញទៅខាងក្រៅបរិវេណនោះ?

**ឆ៖** ពេលវេលាខ្ញុំមិនដឹងថាថ្ងៃណា ថ្មើរណាទេ ប៉ុន្តែថាក្រោយពេលដែលខ្ញុំធ្វើខាងក្នុងគេទុកចិត្តហើយ ខ្ញុំមិនធ្វើសកម្មភាពអ្វីខុសពីបទបញ្ជាផ្ទៃក្នុងរបស់សាលាកែប្រែទេ គេឲ្យខ្ញុំចេញទៅខាងក្រៅ។

**ស៖** តើលោកធ្វើការអ្វីដែរនៅក្រៅបរិវេណ?

**ឆ៖** សំណួរនេះច្រំដែលទៀតហើយ។ ខ្ញុំប្រាប់ហើយ គឺបោចស្មៅ ដំឡូង បោចស្មៅពោតនឹងដៃ។

**ស៖** តើការងាររបស់លោកមានរួមបញ្ចូលទាំងការងារយាមនៅចម្ការដែរឬទេ?

**ឆ៖** ជម្រាបថាពេលដែលបោចស្មៅអស់ បោចស្មៅដំឡូងអស់ ដាំពោតរួចហើយ គឺគេឲ្យខ្ញុំទៅយាមនៅចម្ការខ្នុរ។

**ស៖** ខ្ញុំចាប់អារម្មណ៍ជាមួយនឹងចម្លើយដែលថាយាមចម្ការខ្នុរហ្នឹង។ តើលោកចាប់ផ្ដើមការងារយាមចម្ការហ្នឹងរយៈពេលប៉ុន្មាន<ខែ>ដែរ<បន្ទាប់ពីការចាប់ខ្លួន>?

[១៥:៣៤:៥៦]

**ឆ៖** ខ្ញុំអត់ដឹងរយៈពេលប៉ុន្មានទេ គឺពេលដែលខ្នុរកំពុងផ្លែ កំពុងទុំហ្នឹង គឺគេចាត់តាំងខ្ញុំឲ្យទៅការពារខ្នុរហ្នឹង គឺកុំឲ្យប្រជាពលរដ្ឋចូលក្នុងបរិវេណចម្ការខ្នុរហ្នឹង។

**ស៖** តើលោកដឹងទេថា ខ្នុរទុំនៅពេលណាដែរ នៅក្នុងខេត្តរតនគិរីហ្នឹង ខ្នុរទុំនៅពេលណាដែរ?

**ឆ៖** បាទ ចម្លើយ សំណួរនេះ សូមសើចបន្តិចហើយ សូមទោស។ ខ្នុរទុំនៅពេលណា។ ខ្នុរទុំនៅពេលចាស់ នៅរដូវប្រាំង។

**ស៖** សូមអរគុណ។ ប៉ុន្តែតើរដូវប្រាំងហ្នឹង តើខែណាដែរ ខែកុម្ភៈ មីនា ឬក៏មេសាដែរ?

**ឆ៖** បាទ ខែដែលខ្នុរទុំហ្នឹង គឺខែកុម្ភៈ និងខែមីនា ខ្នុរកំពុងទុំ។

**ស៖** អ៊ីចឹងពេលណាប្រាកដទៅដែលថា លោកឃើញសាកសពស្អុយ ហើម ប្រេះហើមនោះ?

**ឆ៖** ពេលប្រាកដ ឲ្យខ្ញុំប្រាកដថា វានៅពេលណាហ្នឹង ខ្ញុំអត់ប្រាកដបានទេ គឺគ្រាន់តែថាពេលដែលខ្នុរវាកំពុងផ្លែ ហើយនិងកំពុងទុំ គេយក -- ខ្ញុំបានឃើញរណ្ដៅគ្រាប់បែកហ្នឹងវាប្រេះហើម។

**ស៖** អ៊ីចឹង តើប្រហែលជានៅម្ដុំពេលចូលឆ្នាំខ្មែរមែនទេ?

**ឆ៖** បាទ សូមជម្រាបថា មិនមែនចូលឆ្នាំខែ៣ ខែ២ហ្នឹងទេ។ ចូលឆ្នាំខ្មែរគឺខែ៤ ខែមេសា ថ្ងៃ១៣ ខែមេសា គឺខែ៤។

**ស៖** ខ្ញុំដឹងលោកសាក្សី។ លោកនិយាយថា ខ្នុរទុំខ្លាំងនៅពេលដែលលោកឃើញខ្មោចស្អុចប្រេះ

ហ្នឹង។ អ៊ីចឹងបានន័យថា លោកឃើញហ្នឹង គឺលោកឃើញសាកសពហ្នឹងប្រហែលជានៅក្នុងអំឡុង<ថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨> គឺនៅពេលចូលឆ្នាំខ្មែរហ្នឹង មិនមែនទេ?

[១៥:៣៨:១៤]

**ឆ៖** បាទ ខ្ញុំមិនបានចាំដែរ។ មិនកំណត់ក្នុងចិត្តចាំដូចជាឯកសារដែរ ព្រោះថា ខ្ញុំគ្រាន់តែដឹងថា ខ្លួនខ្ញុំពេលដែលទៅឃុំមខ្នុរអ៊ីចឹង ខ្ញុំឃើញរណ្ដៅហ្នឹងវាប្រេះ ហើយប្រេះហើយវាធុំក្លិន ខ្ញុំសន្មតខ្លួនឯងថា ជារណ្ដៅខ្មោចតែម្ដង។

**ស៖** អ៊ីចឹងខ្ញុំអាចនិយាយបានទេថា លោកឃើញសាកសពហើមប្រេះហ្នឹងប្រហែលជាប្រាំពីរ ប្រាំបីខែ ឬក៏ប្រាំបួនខែក្រោយពេលដែលគេចាប់ខ្លួនលោក តើអ៊ីចឹងមែនទេ?

**ឆ៖** មិនមែនក្រោយប្រាំពីរប្រាំបីខែ ក្រោយចាប់ខ្លួនខ្ញុំទេ។ ខ្ញុំសូមជម្រាបម្ដងហើយថា ពេលដែលខ្ញុំចូលទៅប្រហែលបានជាមួយខែ ខ្ញុំឃើញប្រជាពលរដ្ឋហ្នឹង គេចាប់មកមិនដល់មួយអាទិត្យផងគេយកទៅ ហើយគេឲ្យខ្ញុំទៅឃុំមខ្នុរទៅ ក៏ខ្ញុំឃើញរណ្ដៅហ្នឹងវាហើមដី ប្រេះដីហ្នឹងទៅ។

**ស៖** ឥឡូវហ្នឹងយើងនៅនិយាយតទៀតទៅអំពីចម្ការខ្នុរហ្នឹង។ ពេលព្រឹកនេះ លោកនិយាយថា លោកឃើញគេសម្លាប់មនុស្សមួយចំនួននៅពេលដែលលោកនៅឃុំមចម្ការខ្នុរហ្នឹង តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អាហ្នឹងខ្ញុំឃើញមែន។ ខ្ញុំឃើញផ្ទាល់ភ្នែក។

**ស៖** តើលោកឃើញមនុស្សប៉ុន្មាននាក់ដែរ? ខ្ញុំចង់និយាយពីមនុស្សដែលគេសម្លាប់នៅចម្ការខ្នុរហ្នឹង លោកឃើញប៉ុន្មាននាក់ដែរ?

**ឆ៖** មនុស្សពីរនាក់។

[១៥:៤០:២២]

**ស៖** ខ្ញុំសួរលោកបែបនោះ ព្រោះថានៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក គឺខ្មែរមានលេខ 00189254, អង់គ្លេសមានលេខ 00272587 និងបារាំងមានលេខ 00272595។ លោកបាននិយាយថា៖ "ខ្ញុំបានឃើញអ្នកទោសកងពលម្នាក់ ត្រូវកងការពារពីរនាក់សែងយកមកវៃចោលនឹងត្បូងចប បែកលលាដ៍ក្បាល។" ដូច្នេះខ្ញុំចង់សួរថា តើម្នាក់ឬក៏ពីរនាក់ គឺមនុស្សដែលលោកឃើញគេសម្លាប់ហ្នឹង? តើមនុស្សដែលគេសម្លាប់ហ្នឹង ម្នាក់ឬក៏ពីរនាក់?

**ឆ៖** សូមជម្រាបថា សែងទៅពីរនាក់ ម្នាក់ស្លាប់ហើយ ប៉ុន្តែម្នាក់ទៀតមិនទាន់ស្លាប់ទេ អ៊ីចឹងគេសម្លាប់នឹងត្បូងចប ញាត់ទៅក្នុងត្រង់សេ។

**ស៖** ប៉ុន្តែនៅក្នុងចម្លើយដើមរបស់លោក ៗអត់មាននិយាយអំពីមនុស្សទី២ទេ។ លោកនិយាយតែ<>អ្នកទោសកងពល<ម្នាក់ប៉ុណ្ណោះ>។ ដូច្នេះខ្ញុំមិនដឹងថា តើមួយណាដែលស្លាប់? តើលោកឃើញគេសម្លាប់ទាំងពីរ ឬក៏ម្នាក់ស្លាប់ហើយ លោកឃើញម្នាក់ទៀតទើបសម្លាប់?

**ឆ៖** សម្លាប់តែម្នាក់ដែលមិនទាន់អស់ជីវិតទេ។

**ស៖** តើលោកធ្វើយ៉ាងម៉េចបានដឹងថា អ្នកដែលគេស្វែងយកទៅវ៉ៃចោលនឹងត្បូងចបហ្នឹង ជាអ្នកទោសកងពល?

**ឆ៖** ព្រោះនៅនឹងខ្លួនហ្នឹង គឺវាបញ្ជាក់ឲ្យយើងដឹងថា វាជាទាហានដោយមានសម្លៀកបំពាក់ គឺខោហ្នឹងតែម្តង។

[១៥:៤២:៥៦]

**ស៖** តើលោកអាចពន្យល់បានទេ តើគេស្លៀកពាក់ឯកសណ្ឋានយោធាមែនទេ?

**ឆ៖** សូមជម្រាបមិនមែនឯកសណ្ឋានទេ គឺខ្លួនទទេ ហើយខ្លួនហើមទៀត ហើយនៅសល់តែខោទេ យកទៅហ្នឹង។

**ស៖** ប្រហែលជាលោកនិយាយពីមនុស្សទី២ ប៉ុន្តែចំពោះមនុស្សទី១ លោកថាឃើញសម្លាប់ ហើយដែលលោកថា ម្នាក់ហ្នឹងដូចជាអ្នកទោសកងពល។ ដូច្នេះខ្ញុំចង់ដឹងថា នៅពេលដែលសម្លាប់គាត់ហ្នឹង គាត់មានពាក់ខោអាវយោធាអីដែរឬទេ?

**ឆ៖** បាទ អ្នកដែលសម្លាប់ហ្នឹងគឺស្លៀកតែខោខ្លីទេ។ ហើយសូមជម្រាបពេលដែលសែងទៅហ្នឹង គឺសែងទៅទាំងពីរ។

**ស៖** ខ្ញុំចង់សួរលោកថា ហេតុអ្វីបានលោកប្រាប់អ្នកស៊ើបអង្កេតថា លោកឃើញផ្ទាល់អ្នកទោសកងពលម្នាក់ត្រូវបានសម្លាប់? ខ្ញុំចង់ដឹងថា ហេតុអ្វីលោកអាចសន្និដ្ឋានថា លោកបានឃើញផ្ទាល់អ្នកទោសកងពលម្នាក់នោះ?

**ឆ៖** បាទ សំណួរនេះ ខ្ញុំហាក់ដូចជាអត់យល់ទេ ដែលខ្ញុំបាទប្រាប់ថាកងពលដែលគេសម្លាប់ហ្នឹង គឺមិនបានឃើញផ្ទាល់ទេ។ ខ្ញុំគ្រាន់តែបានឆ្លើយពីព្រឹកមិញថា អ្នកដែលសួរចម្លើយយកទៅដាក់នៅនឹងគ្រែ ហើយសរសេរប្រវត្តិរូបខុស គេយកទៅកាប់ដង្កៀបនោះ នោះគឺជាកងទ័ពដែរ ប៉ុន្តែព្រឹកឡើងទៅបាត់ មិនដឹងយកទៅណា នោះខ្ញុំអត់ដឹងទេ។

[១៥:៤៥:១៥]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំ ឥឡូវខ្ញុំនិយាយបន្តិចឡើងវិញឲ្យច្បាស់។ នៅព្រឹកនេះ នៅពេលដែលលោកឆ្លើយជាមួយនឹងសំណួររបស់ព្រះរាជអាជ្ញា គឺលោកនិយាយពីមនុស្សជាច្រើនដែលត្រូវបានសម្លាប់នៅចម្ការខ្នុរ។ ខ្ញុំសួរលោក ឥឡូវនេះថាប៉ុន្មាន លោកថាមានពីរ។ ហើយបន្ទាប់មកទៀត ខ្ញុំសួរដេញដោលដោយលើកចម្លើយរបស់លោក ដែលលោកនិយាយអំពីការសម្លាប់អ្នកទោសតែម្នាក់។ ប៉ុន្តែអ្នកដែលលោកនិយាយនៅក្នុងចម្លើយរបស់លោក គឺថាជាអ្នកទោសកងពលម្នាក់ត្រូវកងការពារពីរនាក់សែង យកមកវាយចោលនឹងត្បូងចប បែកលលាដ៍ក្បាល រួចញាត់ចូលត្រង់សេនៅក្នុងចម្ការខ្នុរ។ ដូច្នេះខ្ញុំចង់សួរលោកថាតើហេតុអ្វីបាននៅពេលនុ៎ង ហើយនិងពេលឥឡូវនេះ ដែលលោករៀបរាប់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយហ្នឹង គឺជាអ្នកទោសកងពល? ហេតុអ្វីបានលោកប៊ានសន្និដ្ឋានថា ជាអ្នកទោសកងពល?

**ឆ៖** បានខ្ញុំសន្មតថា កងពល ដូចខ្ញុំប្រាប់ហើយ គឺស្លៀកខោខ្លី អាខោខ្លីរបស់ក៏ទាហាន។ អ៊ីចឹងខោខ្លីវាខុសគ្នានឹងប្រជាពលរដ្ឋធម្មតា។ តែទោះអ្នកនោះជាអ្នកណាក៏ដោយ គឺអាហ្នឹងខ្ញុំអត់ដឹងទេ គ្រាន់តែខ្ញុំសន្និដ្ឋានខ្លួនខ្ញុំថា ដូចជាកងពលអ៊ីចឹង។

**ស៖** ខ្ញុំចង់ដឹងថា ហេតុអីបានជាលោកប៊ានសន្និដ្ឋានថាគាត់ហ្នឹងជាអ្នកទោស?

**ឆ៖** សំណួរតើហេតុអ្វីបានជាខ្ញុំសន្និដ្ឋានជាអ្នកទោស ព្រោះអ្នកដែលនៅក្នុងសាលាកែប្រែហ្នឹង គឺសុទ្ធតែជនជាប់ទោសទាំងអស់។ ហើយអ្នកដែលគេសែងចេញនេះ គឺសែងចេញពីផ្ទះហ្នឹងតែម្តង ផ្ទះដែលដាក់ច្រវាក់ហ្នឹងតែម្តង។

[១៥:៤៧:៤៩]

**ស៖** ប៉ុន្តែចម្ការខ្នុរហ្នឹង គឺមានចម្ងាយប្រហែលជា២គីឡូម៉ែត្រ ២គីឡូម៉ែត្រពីអូរកន្សែង។ អាចថា លោកធ្លាប់ឃើញគាត់ពីមុន ហើយលោកឃើញនៅក្នុងផ្ទះដែលគេដាក់ខ្នោះហ្នឹង <ឬក៏ឃើញគាត់ធ្វើការនៅអូរកន្សែង> ប៉ុន្តែលោកដូចជាមិនបាននិយាយឲ្យបានលម្អិត។ ដូច្នេះខ្ញុំចង់ឲ្យរកឃើញឲ្យច្បាស់ថា ហេតុអ្វីបានជាលោកប៊ានសន្និដ្ឋានថា អ្នកទោសហ្នឹងជាអ្នកទោសអូរកន្សែង?

**ឆ៖** ព្រោះសូមជម្រាបថា កងសន្តិសុខដែលសែងទៅហ្នឹង ជាកងសន្តិសុខរបស់អូរកន្សែង អ៊ីចឹងវាមិនមានអ្នកណា ក្រៅពីអ្នកទោសនៅអូរកន្សែងហ្នឹងទេ។

**ស៖** អ៊ីចឹងលោកថាអ្នកទោសកងពលហ្នឹង គឺដោយសារតែខោ<ខ្លី>របស់គាត់តែមួយមុខហ្នឹងទេ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺខោខ្លី ពណ៌ទាហាន។

**សៈ** តើលោកចាំឈ្មោះអ្នកកងសន្តិសុខអូរកន្សែងនុំងដែរឬទេ?

**ផៈ** ខ្ញុំអត់ចាំទេ ព្រោះវាច្របូកច្របល់ មិនដឹងអ្នកណាអ្នកណី អ៊ីចឹងឲ្យចាំ ឲ្យឈ្មោះឲ្យអស់ គឺ ខ្ញុំអត់ចាំទេ ហើយអ្នកសែងហ្នឹង ក៏ខ្ញុំអត់ចាំដែរ។

**សៈ** អ៊ីចឹងមិនមែន ទីន ឬក៏ ញ៉ុក ទេ។ តើអ៊ីចឹងមែនទេ?

**ផៈ** បាទ មិនមែនទេ បើពួកហ្នឹងខ្ញុំស្គាល់។

**សៈ** អ៊ីចឹងលោកចាំឈ្មោះ កងសន្តិសុខអូរកន្សែងតែពីរនាក់នេះទេ តើអ៊ីចឹងមែនទេ?

**ផៈ** បាទ ចាំ។

**សៈ** អ៊ីចឹងលោកអាចប្រាប់បានទេថា ហេតុអីបានជាលោកដឹងថា កងការពារដែលសែងអ្នក ទោសយកទៅហ្នឹងជាកងការពារអូរកន្សែងដែរ?

[១៥:៥១:០៨]

**ផៈ** ព្រោះខ្ញុំចំណាំមុខ ហើយនៅក្នុងហ្នឹងវាដើរចេញចូលយាម ចេញចូលខាងក្រៅ ខាងក្នុងគឺ បានសេចក្តីថា យើងសម្គាល់លើមុខ។

**សៈ** ចុះមនុស្សដទៃទៀតដែលលោកនិយាយថា ស្លាប់រួចហើយ តើលោកសន្និដ្ឋានថា អ្នកដែល ស្លាប់រួចហើយហ្នឹង ក៏ជាអ្នកទោសកងពលដែរមែនទេ?

**ផៈ** បាទ នៅជាមួយគ្នា វាទៅសែងទៅទាំងពីរនាក់។

**សៈ** ខ្ញុំចង់សួរថាតើម្នាក់ទៀតហ្នឹងជាអ្នកទោសកងពលដែរមែនទេ គឺចង់និយាយថា គាត់ ស្លៀកខោខ្លីដូចម្នាក់ទៀតដែលលោកឃើញហ្នឹង តើអ៊ីចឹងមែនដែរទេ?

**ផៈ** សូមជម្រាប អ្នកស្លៀកខោខ្លីហ្នឹងតែម្នាក់ទេ។

**សៈ** ចុះម្នាក់ទៀត ម្នាក់ទៀតហ្នឹង គាត់ស្លៀកអីដែរ?

**ផៈ** សែងទាំងស្រាតទៅតែម្តង។

**សៈ** អ៊ីចឹងធ្វើម៉េចបានលោកអាចហ៊ានសន្និដ្ឋានថា ម្នាក់ទៀតដែលគេសែងទាំងស្រាតហ្នឹង ជា អ្នកទោសកងពលដែរ?

**ផៈ** ខ្ញុំគ្រាន់តែសន្និដ្ឋានថា សន្និដ្ឋានស្មានទេ ខ្ញុំថាប្រហែលជាកងពលហើយ ព្រោះនៅអាផ្ទះ នោះ គេច្រើនដាក់កងពលដែលមានការពាក់ព័ន្ធ ហើយត្រូវគេយកមកសាលាកែប្រែ។

**សៈ** ខ្ញុំមិនច្បាស់នៅឡើយ។ តើលោកធ្លាប់ឃើញពួកគាត់ទាំងពីរហ្នឹងមុន ពីពេលមុនហ្នឹងនៅ

ក្នុងគុកដែរឬទេ ឬក៏លោកមិនដែលឃើញពួកគាត់ពីមុនមកទេ?

**ឆ៖** ពេលដែលខ្ញុំចូលទៅដល់ គឺអ្នកទាំងពីរហ្នឹងនៅជាប់ច្រវាក់ ហើមខ្លួនហើយ។

[១៥:៥៤:០០]

**ស៖** តើលោកឃើញហ្នឹង ឃើញនៅពេលណាដែរ?

**ឆ៖** ឃើញពេលដែលខ្ញុំចូលទៅគេដាក់ច្រវាក់ជើងហ្នឹងតែម្តង។ ប៉ុន្តែគ្រាន់តែថា ផ្ទះវានៅដោយខ្លួនពីគ្នា។ គេនៅខាងកើត ខ្ញុំនៅខាងលិច ប៉ុន្តែជញ្ជាំងយើងមើលឃើញផ្ទះទៅដល់ផ្ទះគេ។

**ស៖** ប្រហែលជាខ្ញុំនឹងសួរលោកបន្ថែមទៅលើប្រធានបទនេះនៅថ្ងៃស្អែក ប៉ុន្តែឥឡូវនេះខ្ញុំនឹងលើកយកហេតុការណ៍មួយទៀតគឺទាក់ទងឈ្មោះ ទីន។ លោកមិនបានឃើញ ទីន សម្លាប់មនុស្សទេ ប៉ុន្តែគ្រាន់តែថា ឈ្មោះ ទីន ហ្នឹងឲ្យលោកជួយកប់ខ្មោចមនុស្ស<ម្នាក់>។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកធ្វើយ៉ាងណាបានដឹងថា អ្នកដែលគេបាញ់ហ្នឹងជាជនជាតិ<ភាគតិច>ដែលលួចរត់ទៅរកបាយហូបនៅផ្ទះភូមិហ្នឹង? តើអ៊ីចឹង តើលោកដឹងដោយរបៀបណា?

**ឆ៖** ដឹងដោយរបៀបស្គាល់គ្នា។

**ស៖** តើគេជាអ្នកណាដែរ?

**ឆ៖** បាទ គេជា<អ្នកភូមិហ្នឹង>។

**ស៖** តើអ្នកភូមិប្រាប់លោកនៅពេលណាដែរ?

**ឆ៖** មិនមែនអ្នកភូមិប្រាប់ខ្ញុំទេ ប៉ុន្តែបើសិនជាកម្មករសហជីព គឺខ្ញុំស្គាល់ ព្រោះខ្ញុំស្គាល់កម្មករសហជីព ប៉ុន្តែអ្នកហ្នឹងគឺជាអ្នកប្រជាពលរដ្ឋមកពីតាមភូមិទេ។

[១៥:៥៦:៣៥]

**ស៖** ប៉ុន្តែគាត់ត្រូវគេឃុំនៅអូរកន្សែង តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គេឃុំនៅអូរកន្សែង ដោយពេលដែលគេឲ្យធ្វើការនៅខាងក្រៅហើយ គាត់លួចរត់ទៅរកបាយបងប្អូននៅខាងលើហ្នឹង នៅភូមិជិតហ្នឹងដើម្បីយកមកហូប។

**ស៖** តើ ទីន ឃើញអ្នកទោសរត់ទៅហ្នឹងនៅពេលណាដែរ?

**ឆ៖** អត់មានឃើញរត់ទេ ក្រោយពេលដែលគេត្រួតពិនិត្យទៅគឺគេបាត់មនុស្សម្នាក់។ បើតាមឲ្យថាឃើញពេលរត់ គឺអត់ឃើញពេលរត់ទេ។ ដល់បាត់មនុស្សទៅ គេចាប់ផ្តើមវាយកម្លាំងព័ទ្ធជុំវិញ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កន្លែងសាលាកែប្រែហ្នឹង ដែលពេលប្រហែលជាម៉ោងថ្ងៃជិតត្រង់ហើយ បានឃើញវាដើរមក អាហ្នឹងក៏គេធ្វើឃាតវាតែម្តងទៅ។

**ស៖** លោកដឹងទេ ហេតុអ្វីបានជាអ្នកទោសហ្នឹងត្រឡប់មកមន្ទីរសន្តិសុខវិញ?

**ឆ៖** ខ្ញុំអត់បានសួរវាទេ ប៉ុន្តែខ្ញុំគ្រាន់តែថា ដឹងថាវារត់ចូលមកកន្លែងសន្តិសុខវិញត្រូវគេសម្លាប់។

**ស៖** អ៊ីចឹងហេតុអ្វីបាន ទីន ឲ្យលោកជួយកប់ខ្មោចនោះ?

**ឆ៖** ព្រោះក្រោយពេលបាញ់សម្លាប់ហើយ គឺវាស្រែកហៅឲ្យទៅជួយកប់។

**ស៖** <>តើ ទីន មានប្រាប់លោកពីមូលហេតុដែលគាត់បាញ់ម្នាក់ហ្នឹងទេ?

[១៥:៥៨:៥៥]

**ឆ៖** សូមជម្រាបថាមិនដែលសន្តិសុខរាយការណ៍ជូនអ្នកទោសទេ នៅកន្លែងនុ៎ង គឺអ្វីដែលធ្វើខុសពីបទបញ្ជា គឺគេសម្លាប់ហើយ។

**ស៖** តើ ទីន មានសិទ្ធិអំណាចអ្វីដែលនៅអូរកន្សែងនោះ?

**ឆ៖** ទីន វាជាសន្តិសុខ។

**ស៖** តើអ្នកណាជាអ្នកបញ្ជាឲ្យ ទីន បាញ់អ្នកទោស? ហើយអ្នកណាជាអ្នកបញ្ជាឲ្យ ទីន ប្រើលោកឲ្យកប់ខ្មោចនោះ លោកដឹងទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ អារឿងបញ្ជាឲ្យបាញ់ ខ្ញុំក៏អត់ដឹងដែរ ប៉ុន្តែអ្នកបញ្ជា ទីន ថាឲ្យកប់ខ្មោច អាហ្នឹងក៏ខ្ញុំអត់ដឹងដែរ គឺគ្រាន់តែស្រែកថា មកជួយកប់អានេះផង អាហ្នឹងទៅជួយកប់ទាំងអស់គ្នាទៅដើម្បីកុំវាស្អុយមកដល់កន្លែងយើងរស់នៅ។

**ស៖** ចុះអ្នកដទៃទៀត អ្នកដែលបាញ់អ្នកទោសកងពលពីរនាក់ទៀត តើពួកគាត់មានទទួលបញ្ជាពីអ្នកណាផ្សេងដែរឬទេ?

**ឆ៖** សូមជម្រាបថា អានេះជារឿងផ្ទៃក្នុងរបស់សាលាកែប្រែ មិនមែនជារឿងរបស់ខ្ញុំទេ។ ខ្ញុំអត់ដឹងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ឥឡូវនេះខ្ញុំថា ចង់សួរអំពីបញ្ហាប្រមាត់ ប៉ុន្តែដោយសារតែយើងដល់ពេល ដូច្នេះខ្ញុំសូមអនុញ្ញាតលោកប្រធានបន្តនៅថ្ងៃស្អែកវិញ។

[១៦:០១:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០៣ ខែមីនា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ផន ថុល បញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-867 សូមភាគីជ្រាប និងអញ្ជើញចូលតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ផន ថុល ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ផន ថុល វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ ទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*